**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

## សារណាបញ្ចប់ការសិក្សា

# យន្តការទាក់ទាញការវិនិយោគលើវិស័យស្រូវអង្ករ ដើម្បីលើកកម្ពស់កម្រិតជីវភាពប្រជាជនកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **ធឿន សុភ័ក្រ្ត**
**ពីង ម៉ារ៉ាឌី**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **ឌុយ ចាន់ឌីណា**

ថ្នាក់បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍
ជំនាន់ទី៣

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# **សេចក្ដីថ្លែងអំណរគុណ**

នាងខ្ញុំទាំងពីររូប សូមលំឱនកាយ វាចាចិត្ត ក្រាបប្រណិប័តន៍ និងសូមសម្ដែងនូវការដឹងគុណយ៉ាងជ្រាវជ្រៅ ព្រមទាំងសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់បំផុតចំពោះលោកឪពុក អ្នកម្ដាយ ដែលបានផ្ដល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា និងផ្ដល់ជាកម្លាំងកាយចិត្ត ស្មារតី ធនធានសម្ភារដល់រូបយើងខ្ញុំ ជាពិសេសឧបត្ថម្ភសព្វគ្រប់បែបយ៉ាងទាំងអស់ដោយមិនគិតពីសេចក្ដីនឿយហាត់ ទាំងកម្លាំងកាយ កម្លាំងចិត្ត ក្នុងការអប់រំណែនាំ រៀបចំ តម្រង់ទិសរហូតដល់យើងខ្ញុំមានលទ្ធផលដូចសព្វថ្ងៃ។

នាងខ្ញុំទាំងពីរ ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្ដម **លុយ ចណ្ណា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ជាពិសេស សូមថ្លែងអំណរគុណដល់សាស្ត្រាចារ្យណែនាំផ្ទាល់ បណ្ឌិត **ឌុយ ចាន់ឌីណា** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ខិតខំយកចិត្តទុកដាក់ ពន្យល់ ណែនាំ និងកែលម្អ សម្រាប់ដំណើរការសរសេរសារណារបស់យើងខ្ញុំទាំងពីរនាក់ លើប្រធានបទ៖ **«យន្តការទាក់ទាញការវិនិយោគលើវិស័យស្រូវអង្ករ ដើម្បីលើកកម្ពស់កម្រិតជីវភាពប្រជាជនកម្ពុជា»** រហូតទទួលបានជោគជ័យ។

ជាទីបញ្ចប់ យើងខ្ញុំសូមលើកហត្ថបួងសួងដល់អស់ទេវតា និងវត្ថុស័ក្ដសិទ្ធក្នុងលោកសូមជួយថែរក្សាដល់លោកអ្នកមានគុណ រួមទាំងសាស្ត្រាចារ្យទាំងអស់ និងសូមប្រសិទ្ធពរជ័យ សិរីមង្គល វិបុលសុខ ព្រមទាំងពុទ្ធពរ ទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយការសិក្សាថ្នាក់បរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍ រយៈពេល៤ឆ្នាំកន្លងមកនេះ យើងខ្ញុំពិតជាបានទទួលនូវចំណេះដឹងថ្មីៗជាច្រើនពាក់ព័ន្ធនឹងជំនាញសេដ្ឋកិច្ច និងមុខវិជ្ជាគាំទ្រផ្សេងៗ ក្នុងន័យនេះដើម្បីបន្សល់ទុកនូវស្នាដៃ និងចែករំលែកចំណេះដឹងខ្លះៗ យើងខ្ញុំបានធ្វើការស្រាវជាវលើឯកសារពាក់ព័ន្ធនានា ដើម្បីចងក្រងជាសារណា ក្រោមប្រធានបទ **«យន្តការទាក់ទាញការវិនិយោគលើវិស័យស្រូវអង្ករ ដើម្បីលើកកម្ពស់កម្រិតជីវភាពប្រជាជនកម្ពុជា»** ដែលធ្វើឡើងជាការស្រាវជ្រាវកម្រិតបឋម។

ដូចដែលយើងបានដឹងហើយថាប្រទេសកម្ពុជាយើង ជាប្រទេសដែលមានប្រជាជនភាគច្រើនប្រកបរបរកសិកម្ម ជាពិសេសគឺដំណាំស្រូវ ប៉ុន្តែយើងឃើញថាដំណើរការ និងការផលិត កែច្នៃដំណាំស្រូវនៅក្នុងប្រទេសកម្ពុជានៅមានកម្រិតនៅឡើយ ហេតុនេះទើបយើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទនេះ ក្នុងគោលបំណងបង្កើននូវចំណេះដឹង និងសិក្សាទៅលើគោលនយោបាយនានា ក្នុងការទាក់ទាញការវិនិយោគទាំងក្នុង និងក្រៅប្រទេស ដើម្បីលើកកម្ពស់ផលិតផលស្រូវអង្ករនៅកម្ពុជា ដែលជាកត្តាចូលរួមចំណែកយ៉ាងសំខាន់ក្នុងការជួយកសាងអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។

ជាទីបញ្ចប់នេះ យើងខ្ញុំសង្ឃឹមថាអ្នកសិក្សាស្រាវជ្រាវ និងមិត្តអ្នកអានទាំងអស់នឹងទទួលបានចំណេះដឹងមួយផ្នែកពីសារណាមួយនេះ។ ទោះបីជាយ៉ាងណាយើងខ្ញុំសូមអភ័យទោសទុកជាមុនរាល់កំហុសខុសឆ្គង និងកង្វះខាតទាំងឡាយដែលកើតឡើងចំពោះការចងក្រង និងការសរសេរសារណាមួយនេះឡើង។ យើងខ្ញុំសូមទទួលនូវរាល់មតិរិះគន់ក្នុងន័យស្ថាបនាទាំងឡាយ ដើម្បីឱ្យយើងខ្ញុំដឹងពីចំណុចខ្សោយ ក៏ដូចជាកែលម្អឱ្យមានភាពល្អប្រសើរបន្ថែមទៀត និងសូមថ្លែង អំណរគុណសម្រាប់ការចំណាយពេលវេលាក្នុងការអានអត្ថបទស្រាវជ្រាវនេះ។

# មាតិកា

**ទំព័រ**

អក្សរកាត់ ........ v
បញ្ជីតារាង ........ vi
បញ្ជីរូបភាព ........ vii

## សេចក្តីផ្តើម

១. លំនាំបញ្ហា ........ ១
២. ចំណោទបញ្ហា ........ ២
៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ ........ ២
៤. ទំហំ និងដែនកំណត់ ........ ៣
៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣
៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៣
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤

## ជំពូកទី១

## ការសិក្សាលើទ្រឹស្តី និងទស្សនទានដែលពាក់ព័ន្ធ

១.១ និយមន័យ ........ ៥
១.១.១ និយមន័យនៃយន្តការ ........ ៥
១.១.២ និយមន័យនៃការវិនិយោគ ........ ៥
១.២ ទ្រឹស្តីនៃការវិនិយោគ ........ ៦
១.២.១ ទ្រឹស្តីនីអូក្លាស៊ីកនៃការវិនិយោគ (Neoclassical theory of investment) ........ ៦
១.២.២ ទ្រឹស្តីបង្កើនល្បឿននៃការវិនិយោគ (Accelerator Theory of Investment) ........ ៦
១.៣ ការវិនិយោគ និងកំណើនសេដ្ឋកិច្ច ........ ៧
១.៣.១ កំណើនសេដ្ឋកិច្ចគឺជាអ្វី? ........ ៧
១.៣.២ ឥទ្ធិពលនៃការវិនិយោគទៅលើកំណើនសេដ្ឋកិច្ច ........ ៧
១.៣.៣ តួនាទីការវិនិយោគចំពោះកំណើនសេដ្ឋកិច្ច ........ ៨
១.៤ ការវិនិយោគលើវិស័យកសិកម្ម ........ ៨
១.៤.១ មូលហេតុនៃការវិនិយោគលើវិស័យកសិកម្ម ........ ៩

១.៤.២ ទស្សនៈវិស័យរបស់អ្នកវិនិយោគទៅលើវិស័យកសិកម្ម....................................................៩
១.៤.៣ ក្របខ័ណ្ឌគោលនយោបាយសម្រាប់ការវិនិយោគក្នុងវិស័យកសិកម្ម ....................... ១០
១.៥ កសិកម្ម និងកំណើនសេដ្ឋកិច្ច.............................................................................. ១៣
១.៥.១ កសិកម្មជាសកម្មភាពសេដ្ឋកិច្ច......................................................................... ១៣
១.៥.២ កសិកម្មជាជីវភាពរស់នៅ.................................................................................. ១៣
១.៥.៣ កសិកម្មជាអ្នកផ្ដល់សេវាបរិស្ថាន ..................................................................... ១៤
១.៥.៤ ការកើនឡើងនូវអត្រាអ្នកមានការងារធ្វើ ........................................................... ១៤
១.៥.៥ ការកើនឡើងនូវហេដ្ឋារចនាសម្ព័ន្ធ .................................................................. ១៤
១.៥.៦ ការជួយផ្គត់ផ្គង់វត្ថុធាតុដើម ............................................................................ ១៤
១.៦ ទ្រឹស្ដីមូលដ្ឋាននៃស្តង់ដានៃការរស់នៅ .................................................................. ១៥
១.៧ កំណើនសេដ្ឋកិច្ច និងស្តង់ដានៃការរស់នៅ ............................................................ ១៦

## ជំពូកទី២

## ស្ថានភាព និងតួនាទីនៃការវិនិយោគលើដំណាំស្រូវនៅកម្ពុជា

២.១ ស្ថានភាពវិស័យកសិកម្ម ..................................................................................... ១៩
២.២ ស្ថានភាពផលិតកម្មដំណាំស្រូវនៅកម្ពុជា ចន្លោះឆ្នាំ២០០៨-២០១៨ ................................២២
២.២.១ ស្ថានភាពទូទៅនៃផលិតកម្មដំណាំស្រូវ ...............................................................២២
២.២.២ ស្ថានភាពនៃការនាំចេញផលិតកម្មដំណាំស្រូវ .......................................................២៣
២.២.៣ ទីផ្សារគោលដៅ ..............................................................................................២៥
២.២.៤ តម្លៃការនាំចេញ ...............................................................................................២៧
២.៣ ស្ថានភាពនៃការវិនិយោគលើវិស័យស្រូវអង្ករនៅក្នុងសេដ្ឋកិច្ចកម្ពុជាចន្លោះឆ្នាំ២០០៨-២០១៨ ២៨
២.៣.១ ការវិនិយោគលើម៉ាស៊ីនកិនស្រូវ ឃ្លាំងស្តុក និងឡសម្ងួត ........................................២៨
២.៣.២ ការគាំទ្រលើការវិនិយោគ ម៉ាស៊ីនកិនស្រូវ ឃ្លាំងស្តុក និងឡសម្ងួត .........................២៩
២.៤ ការវិនិយោគដំណាំស្រូវ និងសេដ្ឋកិច្ចកម្ពុជា .......................................................... ៣២
២.៤.១ ដំណាំស្រូវក្នុងកំណើនសេដ្ឋកិច្ច ........................................................................ ៣២
២.៤.២ ដំណាំស្រូវក្នុងលើកកម្ពស់ជីវភាពប្រជាជន...........................................................៣៣

## ជំពូកទី៣

## យន្តការនានាក្នុងការទាក់ទាញការវិនិយោគលើវិស័យស្រូវអង្ករនៅកម្ពុជា


៣.១ គោលនយោបាយលើកទឹកចិត្តរបស់រាជរដ្ឋាភិបាល ........ ៣៥

៣.១.១ ច្បាប់វិនិយោគ ........ ៣៥

៣.១.២ ការលើកលែងពន្ធអាករ........ ៣៦

៣.១.៣ ការលើកទឹកចិត្តផ្នែកពន្ធដារ ........៣៧

៣.១.៤ គោលនយោបាយជំរុញការវិនិយោគ........ ៣៨

៣.១.៥ ការឧបត្ថម្ភធនរបស់រាជរដ្ឋាភិបាល ........ ៣៩

៣.២ ការកសាង និងលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធ........ ៤០

៣.២.១ ស្ថានភាពទូទៅនៃហេដ្ឋារចនាសម្ព័ន្ធ........ ៤០

៣.២.២ ហេដ្ឋារចនាសម្ព័ន្ធ និងវិស័យកសិកម្ម ........ ៤១

៣.៣ ទីផ្សារនាំចេញសម្រាប់វិស័យស្រូវអង្ករ........ ៤៣

៣.៣.១ ចក្ខុវិស័យ និងយុទ្ធសាស្ត្រជំរុញការនាំចេញអង្ករ........ ៤៣

៣.៣.២ ផលិតកម្មពូជស្រូវស្រាលសំខាន់ៗសម្រាប់ការនាំចេញអង្ករ........ ៤៥

៣.៣.៣ ស្តង់ដាអង្ករសម្រាប់អង្ករស និងអង្ករក្រអូប ........ ៤៥

៣.៣.៤ ការចូលរួមពី អង្គការសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងទីភ្នាក់ងារអភិវឌ្ឍន៍បារាំងក្នុងការនាំចេញ ........ ៤៦

៣.៤ វិស័យហិរញ្ញវត្ថុ ........ ៤៦

៣.៤.១ វិស័យហិរញ្ញវត្ថុលើដំណាំស្រូវនៅកម្ពុជា ........ ៤៦

៣.៤.២ វិស័យហិរញ្ញវត្ថុចូលរួមទាក់ទាញការវិនិយោគលើដំណាំស្រូវនៅកម្ពុជា ........ ៤៧

៣.៥ ការអភិវឌ្ឍធនធានមនុស្ស និងការស្រាវជ្រាវអភិវឌ្ឍន៍កសិកម្ម ........ ៤៩

៣.៥.១ ការអភិវឌ្ឍធនធាន........ ៤៩

៣.៥.២ ការអភិវឌ្ឍ និងស្រាវជ្រាវកសិកម្ម ........ ៥១

៣.៦ ការលើកម្ពស់ការផ្តល់សេវាគាំទ្រ និងធាតុចូលវិស័យកសិកម្ម........ ៥២

៣.៦.១ វិធានការទាក់ទងនឹងផលិតកម្មស្រូវ ........ ៥២

៣.៦.២ ប្រព័ន្ធកសិកម្មតាមកិច្ចសន្យា ........ ៥៣

៣.៦.៣ ការដាក់ប្រើប្រាស់សេវាកម្មព័ត៌មានទីផ្សារពាណិជ្ជកម្ម ........ ៥៣

៣.៦.៤ ការលុបចោលអង្គភាពភ្នាក់ងារកម្ពុជានាវាចរ (កាំសាប)........................................ ៥៤
៣.៧ ការកែទម្រង់ការគ្រប់គ្រងដីធ្លី ........................................................................................ ៥៥
៣.៧.១ ការគ្រប់គ្រង និងប្រើប្រាស់ដីកសិកម្ម .................................................................... ៥៦
៣.៧.២ ការប្រើប្រាស់ដីក្នុងការគ្រប់គ្រងធនធានទឹក .......................................................... ៥៧
៣.៨ ការពង្រឹងសហគមន៍កសិកម្ម .......................................................................................... ៥៧
៣.៨.១ អំពីសហគមន៍កសិកម្ម ......................................................................................... ៥៧
៣.៨.២ ការជំរុញពង្រឹងសហគមន៍កសិកម្មនៅក្នុងផលិតកម្មដំណាំស្រូវ .............................. ៥៨

## ជំពូកទី៤

## វិភាគពីភាពខ្លាំង បញ្ហាប្រឈម និងដំណោះស្រាយ

៤.១ ភាពខ្លាំង........................................................................................................................ ៦២
៤.១.១ ការបង្កើតសហព័ន្ធស្រូវអង្ករ.................................................................................. ៦៣
៤.១.២ ការធ្វើទំនើបកម្មកសិកម្ម ........................................................................................ ៦៤
៤.១.៣ ការបង្កើតឡសម្ងួតស្រូវស្នាដៃកូនខ្មែរលើកដំបូង .................................................... ៦៤
៤.២ បញ្ហាប្រឈម................................................................................................................... ៦៥
៤.២.១ ទីផ្សារ និងតម្លៃក្នុងវិស័យស្រូវអង្ករ ....................................................................... ៦៦
៤.២.២ ថ្លៃដើមក្នុងផលិតកម្ម ............................................................................................. ៦៧
៤.២.៣ ហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធធារាសាស្ត្រ .............................................................. ៦៨
៤.៣ ដំណោះស្រាយ................................................................................................................. ៦៩
៤.៣.១ ការឆ្លើយតបនឹងបញ្ហាទីផ្សារ និងតម្លៃ..................................................................... ៦៩
៤.៣.២ វិធានការពាក់ព័ន្ធនឹងថ្លៃដើមនៅក្នុងផលិតកម្មស្រូវអង្ករ ........................................... ៧៣
៤.៣.៣ វិធានការពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធធារាសាស្ត្រ ............................... ៧៤

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

១. សេចក្តីសន្និដ្ឋាន ........................................................................................................... ៧៦
២. អនុសាសន៍ ...................................................................................................................... ៧៧
ឯកសារយោង
ឧបសម្ព័ន្ធ

# អក្សរកាត់

| | | |
|---|---|---|
| AWM | = | Agriculture Water Management |
| MOWRM | = | Ministry of Water Resource and Meteorology |
| SAW | = | Strategy for Agriculture and Water |
| D&D | = | Decentralization and De-concentration |
| JICA | = | Japan International Cooperation Agency |
| ASEAN | = | Associetion of Southeast Asia Nations |
| GDP | = | Gross Domestic Product |
| GNP | = | Gross National Product |
| IRRI | = | International Rice Research Institute |
| CIAP | = | Cambodia-IRRI-Australia Project |
| CARDI | = | Cambodian Agricultural Research and Development Institute |
| EBA | = | Everything But Arm |
| FO | = | Farming Organization |
| RICE SDP | = | Rice Commercialization Sector Development Program |
| IISD | = | International Institute for Sustainable Development |
| RDB | = | Rural Development Bank |
| RGC | = | Royal Government of Cambodia |
| AC | = | Agriculture Community |
| IFC | = | International Financial Corporation |
| SNC | = | Supreme National Economic Council |
| AFD | = | Agency Francis De Development |
| ADB | = | Asia Development Bank |

# បញ្ជីតារាង

តារាងទី១៖ ផលិតកម្មដំណាំស្រូវចន្លោះឆ្នាំ២០០៨-២០១៨

តារាងទី២៖ បរិមាណអង្ករកម្ពុជាដែលបាននាំចេញទៅទីផ្សារអន្តរជាតិចន្លោះឆ្នាំ២០០៩-២០១៩

តារាងទី៣៖ ទីផ្សារគោលដៅនាំចេញអង្ករសំខាន់ៗរបស់កម្ពុជាក្នុងឆ្នាំ២០១៨

តារាងទី៤៖ តម្លៃ និកំណើននៃការនាំចេញអង្ករកម្ពុជា ចន្លោះឆ្នាំ២០១០-២០១៦

តារាងទី៥៖ ភ្នាក់ងារពាក់ព័ន្ធដែលបានចូលរួមក្នុងវេទិកាពាណិជ្ជកម្មស្រូវ

តារាងទី៦៖ ចំនួនសហគមន៍ដែលត្រូវបានបង្កើតនៅបណ្តាឆ្នាំ គិតត្រឹមឆ្នាំ២០១៨

# បញ្ជីរូបភាព


រូបភាពទី១៖ GDPពីកសិកម្មចន្លោះឆ្នាំ២០១០-២០១៨

រូបភាពទី២៖ បរិមាណអង្ករកម្ពុជាដែលបាននាំចេញទៅកាន់ទីផ្សារអន្តរជាតិចន្លោះ២០០៩-២០១៨

រូបភាពទី៣៖ ទីផ្សារគោលដៅនាំចេញអង្ករសំខាន់ៗរបស់កម្ពុជាក្នុងឆ្នាំ២០១៨

រូបភាពទី៤៖ តម្លៃ និងកំណើននៃការនាំចេញអង្កររបស់កម្ពុជា២០១០-២០១៦

រូបភាពទី៥៖ កត្តាចូលរួមកាត់បន្ថយភាពក្រីក្រចន្លោះឆ្នាំ២០០៤-២០១១

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ស្រូវ គឺជាដំណាំមួយដ៏សំខាន់នៅក្នុងជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ដោយដំណាំនេះបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងសេដ្ឋកិច្ច វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់របស់ជាតិសាសន៍យើងតាំងតែពីអតីតកាលដ៏យូរលង់ណាស់មកហើយ ។ ភស្តុតាងជាច្រើនបានបញ្ជាក់ថា ទាំងពេលបច្ចុប្បន្ន និងពេលអតីតកាល ស្រូវគឺជាដំណាំសេដ្ឋកិច្ចរបស់ជាតិ ។ ជាក់ស្តែងនាសម័យអង្គរអាស្រ័យដោយមានការចូលរួមចំណែកដ៏ចម្បង និងសំខាន់ពីដំណាំស្រូវ ទើបធ្វើឱ្យប្រទេសកម្ពុជានាសម័យនោះបានឈានដល់យុគមាស និងជាអាណាចក្រដ៏ខ្លាំងជាងគេនៅអាស៊ីអាគ្នេយ៍។

ជាមួយគ្នានេះដែរ នាពេលបច្ចុប្បន្ននេះដំណាំស្រូវនៅតែដើរតួនាទីយ៉ាងសំខាន់នៅក្នុងការកសាងអភិវឌ្ឍន៍ជាតិ ជាក់ស្តែងនៅក្នុងយុទ្ធសាស្ត្រដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលត្រង់ ចតុកោណទី៤ មុំទី១ បានដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រគឺពង្រឹងតួនាទីវិស័យកសិកម្ម ក្នុងការបង្កើតការងារ ការធានាសន្តិសុខស្បៀង ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍ជនបទ។

ដោយសារតែស្រូវដើរតួនាទីយ៉ាងសំខាន់ដូច្នេះហើយ ទើបប្រជាជនកម្ពុជាភាគច្រើនយកចិត្តទុកដាក់លើដំណាំស្រូវជាខ្លាំង ហើយផ្ទៃដីប្រមាណ ៧៥% ត្រូវបានប្រើប្រាស់សម្រាប់ការដាំដំណាំស្រូវ។ រីឯផលិតកម្ម ដំណើរការ និងទីផ្សារស្រូវក៏បានផ្តល់ការងារដល់ប្រជាជនប្រមាណ ៣លាននាក់ ឬ២០%នៃប្រជាជនដែលមានវ័យគ្រប់គ្រាន់សម្រាប់បំពេញការងារ។ ផ្ទុយទៅវិញ មួយផ្នែកធំនៃស្រូវដែលបានផលិតនៅក្នុងប្រទេសកម្ពុជា ត្រូវបាននាំចេញទៅប្រទេសថៃ និងវៀតណាម ដើម្បីកិនរួចត្រូវបានបែងចែកសម្រាប់បំពេញតម្រូវការនៅក្នុងស្រុក ឬនាំចេញទៅបណ្តាប្រទេសផ្សេងៗទៀត។ បញ្ហាទាំងនេះបានបង្កឱ្យបាត់បង់ឱកាសយ៉ាងច្រើនសម្រាប់រោងម៉ាស៊ីនកិនស្រូវ និងពាណិជ្ជករនៅកម្ពុជាក្នុងការនាំចេញផ្ទាល់ និងការបង្កើតការងារដល់ប្រជាជនក្នុងស្រុកជាច្រើន ។[1]

ចំពោះបញ្ហានេះរាជរដ្ឋាភិបាល អង្គការ និងស្ថាប័នពាក់ព័ន្ធ ក៏បានយកចិត្តទុកដាក់ផងដែរ ដោយបានបង្កើតជាយន្តការ ឬគោលនយោបាយនានាក្នុងគោលដៅទាក់ទាញការវិនិយោគលើ

[1] ធនាគារជាតិ នៃកម្ពុជា, ការផ្តល់ហិរញ្ញប្បទានដល់វិស័យកសិកម្ម (២០១៦) ទំព័រ៣។

វិស័យស្រូវអង្ករដោយក្នុងនោះមានការបង្កើតច្បាប់នៃការវិនិយោគ ការបន្ធូរបន្ថយពន្ធ ផែនការសម្រាប់ផលិតកម្មស្រូវ គោលនយោបាយលើកទឹកចិត្តជាដើម។ ការទាក់ទាញអ្នកវិនិយោគលើ វិស័យស្រូវអង្ករ គឺជាឱកាសមួយដែលឈានទៅរកការលើកកម្ពស់ដល់ផលិតកម្មស្រូវ ឱ្យកាន់តែល្អប្រសើរ ព្រមទាំងជំរុញដល់ការនាំចេញស្រូវអង្ករ និងជួយលើកទឹកចិត្តកសិករក៏ដូចជាបង្កើតការងារដល់ប្រជាជនទូទៅបន្ថែមទៀតជាច្រើនផ្នែក ដូច្នេះកម្រិតជីវភាពប្រជាជននឹងមានភាពប្រសើរឡើង ហើយសេដ្ឋកិច្ចជាតិក៏កាន់តែរីកចម្រើន។

## ២. ចំណោទបញ្ហា

វិស័យកសិកម្ម គឺជាវិស័យអាទិភាពដ៏សំខាន់សម្រាប់សេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែនារយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ យើងសង្កេតឃើញថាវិភាគទានក្នុងការចូលរួមក្នុងកំណើនសេដ្ឋកិច្ចរបស់វិស័យកសិកម្មហាក់ដូចជាមានការចូលរួមក្នុងទំហំតូច ដូច្នេះទើបពួកយើងចង់ធ្វើការសិក្សាស្រាវជ្រាវ និងស្វែងយល់ពីគោលនយោបាយ និងគុណសម្បត្តិនានាដែលប្រទេសកម្ពុជាមាន ដើម្បីទាក់ទាញការវិនិយោគបន្ថែមទៀតលើវិស័យនេះ ជាពិសេសគឺវិស័យស្រូវអង្ករផ្ទាល់តែម្តង។

យន្តការទាក់ទាញការវិនិយោគលើវិស័យស្រូវអង្ករ គឺជាយន្តការមួយដ៏សំខាន់ក្នុងការចូលរួមឱ្យកម្ពុជាបង្កើនការអភិវឌ្ឍន៍វិស័យស្រូវអង្ករ ក៏ដូចជាលើកកម្ពស់ជីវភាពប្រជាជនកម្ពុជាស្របពេលដែលប្រជាជនមានការជួបប្រទះនូវបញ្ហារាំងស្ទះមួយចំនួនចំពោះដំណើរនៃការដាំដុះ បច្ចេកទេស និងបញ្ហាទីផ្សារសម្រាប់ទិន្នផលស្រូវដែលទទួលបានហើយ។ ទាក់ទិននឹងបញ្ហាទាំងនេះបង្កើតបានជាសំណួរមួយចំនួនដូចខាងក្រោម៖

- តើការវិនិយោគលើដំណាំស្រូវអង្ករបានផ្តល់អត្ថប្រយោជន៍អ្វីខ្លះ សម្រាប់ប្រជាជនកម្ពុជា និងសេដ្ឋកិច្ចជាតិទាំងមូល?
- តើរាជរដ្ឋាភិបាលបង្កើតគោលនយោបាយ និងយន្តការអ្វីខ្លះសម្រាប់ទាក់ទាញការវិនិយោគលើវិស័យស្រូវអង្ករ?

- តើប្រសិទ្ធភាពនៃការអនុវត្តយន្តការនានា លើវិស័យស្រូវអង្ករសម្រេចបានកម្រិតណា និងមានចំណុចខ្វះខាតអ្វីខ្លះ?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទ "**យន្តការទាក់ទាញការវិនិយោគលើវិស័យស្រូវអង្ករ ដើម្បីលើកកម្ពស់កម្រិតជីវភាពប្រជាជនកម្ពុជា**" នេះគឺដើម្បីស្វែងយល់អំពី ៖

១. សិក្សាពីស្ថានភាពទូទៅនៃការវិនិយោគលើវិស័យស្រូវអង្ករនៅកម្ពុជា

២. ការចូលរួមរបស់វិស័យស្រូវអង្ករ ក្នុងការជួយលើកកម្ពស់កម្រិតជីវភាពប្រជាជន និងសេដ្ឋកិច្ចជាតិនៅកម្ពុជា

៣. យន្តការនានាដើម្បីទាក់ទាញការវិនិយោគលើវិស័យស្រូវអង្ករនៅកម្ពុជា

៤. បញ្ហាប្រឈម និងដំណោះស្រាយនានានៅក្នុងវិស័យស្រូវអង្ករ

៥. ការផ្តល់អនុសាសន៍ចំពោះការស្រាវជ្រាវ

## ៤. ទំហំ និងដែនកំណត់

ការសិក្សាស្រាវជ្រាវនេះ ផ្តោតទៅលើតែយន្តការទាក់ទាញការវិនិយោគលើវិស័យស្រូវអង្ករ និងអត្ថប្រយោជន៍ដែលជួយលើកកម្ពស់កម្រិតជីវភាពប្រជាជនកម្ពុជា តាមរយៈផលនៃការវិនិយោគ និងផលិតកម្មស្រូវក្នុងចន្លោះឆ្នាំ២០០៨ ដល់ឆ្នាំ២០១៨។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ មានសារៈសំខាន់ដូចខាងក្រោម ៖

- ផ្តល់ជាចំណោះដឹងដល់អ្នកអាន ដើម្បីស្វែងយល់ពីយន្តការទាក់ទាញការវិនិយោគលើវិស័យស្រូវអង្ករ ជីវភាពប្រជាជន និងសេដ្ឋកិច្ចជាតិ
- ផ្តល់ព័ត៌មានសម្រាប់អ្នកវិនិយោគ ដែលមានបំណងចង់មកវិនិយោគលើវិស័យស្រូវអង្ករនៅកម្ពុជា
- ផ្តល់ជាចំណោះដឹង និងចែករំលែកទិន្នន័យមួយចំនួនដល់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយក្នុងការសិក្សាស្រាវជ្រាវបន្ត
- សិក្សាពីកង្វះខាត និងបញ្ហាប្រឈមនានា ព្រមទាំងដំណោះស្រាយ ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបនឹងទិដ្ឋភាពពិតជាក់ស្តែង ឬតក្កក្នុងការសិក្សាស្រាវជ្រាវ ក្រុមយើងខ្ញុំធ្វើការសិក្សាស្រាវជ្រាវប្រមូលទិន្នន័យតាមបណ្តាឯកសារ គេហទំព័រ សៀវភៅ និងអត្ថបទចងក្រងនានានៅតាមស្ថាប័នដែលពាក់ព័ន្ធមួយចំនួន ចំពោះទិន្នន័យទាំងនោះក្រុមយើងខ្ញុំ បានធ្វើការដកស្រង់តែយន្តការពាក់ព័ន្ធក្នុងការជំរុញ និងទាក់ទាញការវិនិយោគលើវិស័យស្រូវអង្ករ និងលទ្ធផលនៃការលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាជនកម្ពុជា និងអត្ថប្រយោជន៍សម្រាប់សេដ្ឋកិច្ចជាតិ។

ជាក់ស្តែងវិធីសាស្ត្រប្រមូលទិន្នន័យ កំណត់តាមប្រភពទិន្នន័យពីរបែបគឺ ទិន្នន័យបឋម(Primary Data) និងទិន្នន័យបន្ទាប់បន្សំ (Secondary Data)។ ចំពោះការសិក្សាស្រាវជ្រាវលើប្រធានបទនេះ គឺយើងបានធ្វើការប្រមូលទិន្នន័យតែតាមរយៈប្រភពទិន្នន័យបន្ទាប់បន្សំ (Secondary Data) តែប៉ុណ្ណោះ។

ទិន្នន័យបន្ទាប់បន្សំ គឺសំដៅទៅលើប្រភេទនិន្នន័យស្រាវជ្រាវដែលប្រមូលព័ត៌មានពីបណ្តាសៀវភៅ ឯកសារនានា ដែលយ៉ាងហោចណាស់បានដកស្រង់យកចេញពីជំហាននៃព្រឹត្តិការណ៍ ឫពិសោធន៍ និងឯកសារសំខាន់ៗដូចខាងក្រោម ៖

- សៀវភៅនៅក្នុងបណ្ណាល័យ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- សៀវភៅគោលនយោបាយ
- ផែនការយុទ្ធសាស្ត្រ
- ច្បាប់ និង
- គេហទំព័រជាដើម។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីសម្រួលដល់ការសិក្សាស្រាវជ្រាវនេះ យើងខ្ញុំបានធ្វើការរៀបចំសារណានេះជាបួនជំពូក រួមមាន ៖

**សេចក្តីផ្តើម**

នៅក្នុងជំពូកនេះ និយាយពីលំនាំដើម ចំណោទបញ្ហា ដែនកំណត់ សារៈសំខាន់ និងវិធីសាស្ត្រក្នុងការសិក្សាស្រាវជ្រាវអត្ថបទនេះ។

**ជំពូកទី១៖** ការសិក្សាលើទ្រឹស្តី និងទស្សនទានដែលពាក់ព័ន្ធ

**ជំពូកទី២៖** ស្ថានភាព និងការចូលរួមនៃការវិនិយោគលើវិស័យស្រូវអង្ករនៅក្នុងសេដ្ឋកិច្ចកម្ពុជា

**ជំពូកទី៣៖** យន្តការនានា ក្នុងការទាក់ទាញការវិនិយោគលើស្រូវអង្ករនៅកម្ពុជា

**ជំពូកទី៤៖** ភាពខ្លាំង បញ្ហាប្រឈម និងដំណោះស្រាយ

**សេចក្តីសន្និដ្ឋាន និងអនុសាសន៍**

# ជំពូកទី១

# ការសិក្សាលើទ្រឹស្តី និងទស្សនទានដែលពាក់ព័ន្ធ

## ១.១ និយមន័យ

### ១.១.១ និយមន័យនៃយន្តការ

**តាមន័យជាតិសព្ទ** **យន្ត** ៖ គឺជាគ្រឿងចក្រ ឬកត្តាជំរុញដោយកម្លាំងធ្វើឱ្យមានដំណើរការ

**ការ** ៖ កិច្ច ឬអំពើដែលត្រូវធ្វើ

**យន្តការ** គឺជាទង្វើក្នុងការជំរុញឱ្យមានដំណើរការអ្វីមួយដោយឥទ្ធិពលនៃតួអង្គពាក់ព័ន្ធ។

**តាមន័យវចនានុក្រមCambridge** ៖ យន្តការ គឺជាវិធីនៃការធ្វើអ្វីមួយជាពិសេសការប្រើប្រាស់សម្រាប់ផែនការដែលបានគ្រោងទុក ឬជាផ្នែកមួយនៃប្រព័ន្ធផ្សេងៗ។

**តាមន័យដូច** ៖ យន្តការ គឺជានីតិវិធី ដំណើរការ ប្រព័ន្ធ ប្រតិបត្តិការ វិធីសាស្ត្រ បច្ចេកទេស ការងារ មធ្យោបាយ ទីភ្នាក់ងារ ឆានែល ឬ រចនាសម្ព័ន្ធ ផ្សេងៗ ក្នុងការចូលរួមដើម្បីឱ្យមានដំណើរការកិច្ចការងារអ្វីមួយ។

### ១.១.២ និយមន័យនៃការវិនិយោគ[2]

**តាមន័យគតិយុត្ត** ៖ ការវិនិយោគ គឺជាប្រតិបត្តិការប្រើប្រាស់នូវឧបករណ៍គតិយុត្តដើម្បីធ្វើឱ្យសេដ្ឋកិច្ចក្នុងសង្គមដំណើរការបានល្អ។
វាអាចជាការបង្កើតឡើងតាមរយៈប្រើប្រាស់ទុន
ឬហ៊ុនដែលជាដើមទុនសម្រាប់បង្កើតគ្រោងសេដ្ឋកិច្ច
ដែលបានផ្តល់ឱ្យអ្នកវិនិយោគទុនបានទួលនូវផលចំណេញក្នុងគម្រោងរបស់អ្នកវិនិយោគទាំងនោះ ។

**តាមច្បាប់អន្តរជាតិ** ៖ ការវិនិយោគ គឺជាការជាប់កិច្ចសន្យារវាងវិនិយោគិនក្នុងប្រទេសមួយជាមួយនឹងវិនិយោគិនក្នុងប្រទេសមួយផ្សេងទៀត លើទឹកដីណាមួយតាមកិច្ចព្រមព្រៀងជាមុនទោះនៅទីណាក៏ដោយដោយអនុលោមតាមច្បាប់ និងបញ្ញត្តិរបស់ភាគីចុះកិច្ចសន្យា ។

**តាមន័យសេដ្ឋកិច្ច**៖ ការវិនិយោគ គឺជាការធ្វើប្រតិបត្តិការដើម្បីបង្កើតមូលធនដូចជាទ្រព្យក្នុងការរក្សាស្ថិរភាព សម្រាប់បម្រើសេចក្តីត្រូវការ និងភាពចាំបាច់នានាជាដើម។

---

[2] https://knowledgelegalkrn.blogspot.com/2017/04/blog-post_47.htm, published April 04, 2017.

តាមន័យនេះការវិនិយោគមានដូចខាងក្រោម៖

- ការបង្កើតជាសហគ្រាស បរទេសដែលមាន បុត្រសម្ព័ន្ធ ការិយាល័យតំណាង និងសាខា
- ការទិញសហគ្រាសដែលមានរួចជាស្រេច
- ចូលដើមទុនសម្រាប់សហគ្រាសបង្កើតថ្មី
- ចូលដើមទុនសម្រាប់សហគ្រាសដែលមានស្រាប់។

## ១.២ ទ្រឹស្តីនៃការវិនិយោគ[3]

### ១.២.១ ទ្រឹស្តីនីអូក្លាស៊ីកនៃការវិនិយោគ (Neoclassical theory of investment)

ទ្រឹស្តីនីអូក្លាស៊ីកនៃការវិនិយោគ គឺជាការសន្មត់ជាក់លាក់ទៅលើ ប្រាក់ចំណេញ(Profit) ឬប្រាក់ចំណូល(Revenue) ជាអតិបរមា។ ការសន្មត់ជាក់លាក់នេះ កើតឡើងតាមរយៈការវិនិយោគនៃមូលធនភាគហ៊ុនដែលល្អបំផុត(Optimal of Capital stock)។ ប្រាក់ចំណេញអតិបរមានៅក្នុងកំឡុងពេលនីមួយៗអាចជាទិន្នផលដ៏ល្អបំផុតរបស់មូលធនភាគហ៊ុន។

### ១.២.២ ទ្រឹស្តីបង្កើនល្បឿននៃការវិនិយោគ (Accelerator Theory of Investment)

ទ្រឹស្តីបង្កើនល្បឿននៃការវិនិយោគ មានទំនាក់ទំនងជាមួយគំនិតKeynesian ដែលជាគំនិតចម្បងក្នុងការសន្មត់តម្លៃថេរ។ គោលការណ៍បង្កើនល្បឿនក្នុងការវិនិយោគត្រូវបានលើកឡើងដំបូងដោយClark(1917) និងបានអនុវត្តន៍ដោយSamuelson(1939) នៅក្នុងកាន់វដ្តនៃអាជីវកម្ម។ គោលការណ៍នេះបញ្ជាក់ថា នៅពេលដែលប្រាក់ចំណូលកើនឡើង ការវិនិយោគនឹងកើនឡើងដូចគ្នា។ ត្រង់ចំណុចនេះមានន័យថា នៅពេលដែលប្រាក់ចំណូលរបស់បុគ្គលម្នាក់ៗកើនឡើង នាំឱ្យការប្រើប្រាស់កើនឡើង នោះបរិមាណទំនិញប្រើប្រាស់កើនឡើងដូចគ្នា ជាហេតុធ្វើឱ្យការផលិតទំនិញសម្រាប់ផ្គត់ផ្គង់មានការកើនឡើង។ ដូចនេះការបង្កើនល្បឿនក្នុងការវិនិយោគ គឺជាទំនាក់ទំនងគ្នារវាងកំណើននៃការវិនិយោគដែលកើតឡើងពីកំណើននៃប្រាក់ចំណូល។ ចំពោះសេដ្ឋកិច្ចជាតិ កាលណាប្រាក់ចំណូលជាតិមានការកើនឡើង នោះការវិនិយោគ

[3] Johan, Theories of Investment [ទ្រឹស្តីនៃការវិនិយោគ] (2013), 2-11.

នឹងមានសក្តានុពលវិជ្ជមានទៅតាមហ្នឹងដែរ ប៉ុន្តែវាអាចនឹងធ្លាក់ចុះប្រសិនបើប្រាក់ចំណូលជាតិ ឬទិន្នផលជាតិនៅតែថេរ។ តាមរូបមន្តៈ $K^*$=aY ឬ I=aY

($K^*$=មូលធនរបស់អ្នកវិនិយោគ, I=ការវិនិយោគ, a=មេគុណ និងY=ប្រាក់ចំណូលជាតិសរុប ឬផលិតផលក្នុងស្រុកសរុប)

## ១.៣ ការវិនិយោគ និងកំណើនសេដ្ឋកិច្ច

### ១.៣.១ កំណើនសេដ្ឋកិច្ចគឺជាអ្វី?

កំណើនសេដ្ឋកិច្ច គឺជាការកើនឡើងនូវផលិតកម្មទំនិញ និងសេវាកម្មសេដ្ឋកិច្ចដោយប្រៀបធៀបពីកំឡុងពេលមួយទៅកំឡុងពេលមួយទៀត។ ជាទូទៅកំណើនសេដ្ឋកិច្ចសរុប ត្រូវបានវាស់វែងតាមផលិតផលជាតិសរុប (GNP) ឬផលិតផលក្នុងស្រុកសរុប (GDP) បើទោះគេអាចប្រើប្រាស់វិធានជំនួសផ្សេងៗនៅពេលខ្លះក៏ដោយ។

យើងកំណត់ពីកំណើនសេដ្ឋកិច្ចនៅក្នុងសេដ្ឋកិច្ចមួយ ដោយការផ្លាស់ប្តូរទិសដៅនៃខ្សែកោងលទ្ធភាពផលិតកម្ម (Production Possible Curve or PPC)។ កំណើនសេដ្ឋកិច្ចត្រូវបានវាស់ដោយការកើនឡើងនៃទិន្នផលសរុបក្នុងស្រុក ឬផលិតផលក្នុងស្រុកសរុបពិតប្រាកដ (GDP) ឬផលិតផលជាតិសរុប (GNP) ។

កំណើនសេដ្ឋកិច្ចផ្តល់អត្ថប្រយោជន៍សំខាន់ៗដូចខាងក្រោម ៖

- ប្រាក់ចំណូលជាមធ្យមកើនឡើង
- កាត់បន្ថយអតិផរណា
- កាត់បន្ថយកម្ចីរបស់រាជរដ្ឋាភិបាល
- លើកកម្ពស់សេវាសាធារណៈ
- បង្កើនការវិនិយោគ
- បង្កើនការស្រាវជ្រាវ និងការអភិវឌ្ឍ
- អាចចំណាយបន្ថែមទៅលើការការពារបរិស្ថាន។

### ១.៣.២ ឥទ្ធិពលនៃការវិនិយោគទៅលើកំណើនសេដ្ឋកិច្ច

ការវិនិយោគមានឥទ្ធិពលទៅលើអត្រានៃកំណើនសេដ្ឋកិច្ច ព្រោះការវិនិយោគគឺជាសមាសធាតុនៃតម្រូវការសរុប (aggregate demand/AD)

ហើយការវិនិយោគរឹតតែមានឥទ្ធិពលសំខាន់ទៅលើផលិតភាពនៅក្នុងសេដ្ឋកិច្ច។ ដូច្នេះហើយប្រសិនបើមានកំណើននៃការវិនិយោគ នោះវាក៏មានសន្ទុះនៃតម្រូវការសរុបកើនឡើង និងមានកំណើនសេដ្ឋកិច្ចនៅក្នុងរយៈពេលខ្លី។

ការប្រសើរឡើងនៃអត្រាកំណើនសេដ្ឋកិច្ច អាចធ្វើឱ្យមានការកើនឡើងនៃការវិនិយោគ ប៉ុន្តែប្រសិនបើសេដ្ឋកិច្ចធ្លាក់ចុះនៅពេលណាមួយ ហើយអត្រាកំណើនសេដ្ឋកិច្ចធ្លាក់ចុះ នោះអ្នកធ្វើវិនិយោគនឹងបាត់បង់ចំណែកនៃការវិនិយោគដូចគ្នា។

### ១.៣.៣ តួនាទីការវិនិយោគចំពោះកំណើនសេដ្ឋកិច្ច

ជាទូទៅការវិនិយោគ គឺជាគ្រប់សកម្មភាពសេដ្ឋកិច្ចទាំងឡាយរួមមានការប្រើប្រាស់ធនធាននៅក្នុងផលិតកម្មទំនិញ និងសេវា។

សារៈសំខាន់នៃការវិនិយោគទៅលើកំណើនសដ្ឋកិច្ច មានលក្ខណៈដូចខាងក្រោម ៖

- ការវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធ
  គឺជាការវិនិយោគដ៏សំខាន់មួយនៅក្នុងប្រទេសដែលមានការអភិវឌ្ឍកម្រិតតាប(LDC) ពីព្រោះហេដ្ឋារចនាសម្ព័ន្ធធ្វើឱ្យលទ្ធភាពរបស់ ផលិតករក្នុងការប្រើប្រាស់បច្ចេកទេសទំនើប និងដំណើរការផ្សេងៗដើម្បីជំរុញសកម្មភាពផលិតកម្មរបស់ពួកគេ។
- ការវិនិយោគទៅលើការអប់រំ សំខាន់ទៅលើការបង្កឹកជំនាញផលិត និងបង្កើតផលិតភាពពលកម្មជាដើម។
- ការវិនិយោគទៅលើការស្រាវជ្រាវកសិកម្ម គឺជាការពង្រីក និងលើកស្ទួយសេវាកម្មក៏ដូចជាសម្របសម្រួល ក្នុងការផ្សព្វផ្សាយនូវសមិទ្ធផលវិទ្យាសាស្ត្រស្រាវជ្រាវដែលធ្វើឱ្យកំណើនផលិតកម្មកើនឡើងផងដែរ។

## ១.៤ ការវិនិយោគលើវិស័យកសិកម្ម

បរិស្ថាន និងបរិបទសម្រាប់ការវិនិយោគក្នុងវិស័យកសិកម្មបានផ្លាស់ប្តូរយ៉ាងខ្លាំងក្នុងរយៈពេល២០ឆ្នាំកន្លងមកនេះ។ ជំនួសឱ្យការវិនិយោគលើទស្សនៈដើម្បីបង្កើនផលិតកម្មស្បៀងអាហារ និងការផ្គត់ផ្គង់ស្បៀងអាហារពិភពលោក ការវិនិយោគលើវិស័យកសិកម្ម

ត្រូវបានបង្កើនការប្រកួតប្រជែង និងប្រាក់ចំណេញតាមខ្សែសង្វាក់ផលិតកម្មពីកសិករដល់អតិថិជន បង្កើននិរន្តរភាពសម្រាប់បរិស្ថាន និងធនធានធម្មជាតិ ក៏ដូចជាផ្តល់សិទ្ធិអំណាចដល់ប្រជាជននៅតាមជនបទនៅក្នុងបរិបទផ្លាស់ប្តូរនេះ។

### ១.៤.១ មូលហេតុនៃការវិនិយោគលើវិស័យកសិកម្ម[4]

មនុស្សជាង៨០០លាននាក់នៅទូទាំងពិភពលោក បានចូលដំណេកដោយមិនបានទទួលទានអាហារក្នុងនោះ៧០%ជាប្រជាជនរស់នៅជនបទ ដោយពឹងផ្អែកលើកសិកម្មសម្រាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគេ។ វិស័យកសិកម្មផ្តល់នូវការចិញ្ចឹមជីវិតដល់មនុស្សនៅទូទាំងពិភពលោកបានច្រើនជាងវិស័យផ្សេងទៀតគួរឱ្យកត់សម្គាល់គឺ ស្មើរតែច្រើនជាង៥០% នៃការងារសរុបក្នុងប្រទេសក្រីក្រ។ ការវិនិយោគលើវិស័យកសិកម្ម គឺអាចនិយាយបានថាមានឥទ្ធិពលកាត់បន្ថយភាពក្រីក្រយ៉ាងគួរឱ្យកត់សម្គាល់ ជាពិសេសក្នុងចំណោមប្រជាជនក្រីក្របំផុតជាងការវិនិយោគលើ វិស័យផ្សេងៗទៀត។

នេះជាមូលហេតុដែលការបង្កើនការវិនិយោគលើប្រព័ន្ធកសិកម្ម និងស្បៀងអាហារនៅក្នុងបណ្តាប្រទេសដែលមានប្រាក់ចំណូលទាប និងមធ្យមមានភាពចាំបាច់យ៉ាងខ្លាំង។ នៅពេលការ វិនិយោគត្រូវទិសដៅ វាគឺជាការវិនិយោគដែលអាចជួយបង្កើនផលិតកម្ម បង្កើតការងារ បង្កើនប្រាក់ចំណូល និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ច។ ប៉ុន្តែផ្ទុយទៅវិញ នៅពេលធ្វើការវិនិយោគខុស ទិសដៅ វាគឺជាផលប៉ះពាល់អវិជ្ជមានយ៉ាងធ្ងន់ធ្ងរដែលធ្វើឱ្យបញ្ហាវិសមភាពកើតមានឡើង ដូចជាធ្វើឱ្យប៉ះពាល់ដល់ជីវភាពរបស់កសិករខ្នាតតូច ជាពិសេសស្ត្រី រួមទាំងការបាត់បង់ដីធ្លី ទឹកប្រេង និងធនធានធម្មជាតិនានាទៀតជាច្រើន។

### ១.៤.២ ទស្សនៈវិស័យរបស់អ្នកវិនិយោគនៅលើវិស័យកសិកម្ម[5]

វិស័យកសិកម្មបានទាក់ទាញវិនិយោគិនសាធារណៈអន្តរជាតិ និងឯកជនអន្តរជាតិជាច្រើន។ កត្តាសំខាន់នៅពីក្រោយនិន្នាការនេះ គឺដោយសារមានការកើនឡើងនៃតម្លៃស្បៀងអាហារក្នុងរយៈពេលយូរអង្វែង នៅអំឡុងពេលមួយទសវត្សរ៍ចុងក្រោយនេះ

[4] https://www.iisd.org/topic/agriculture-water-and-investment, published 2015.

[5] United Nation, Press Realease of United Nation [សេចក្តីប្រកាសព័ត៌មានរបស់អង្គការសហប្រជាជាតិ] (2009), 10.

ជាការជំរុញឱ្យមានការរំពឹងទុកនៃការផលចំណេញខ្ពស់របស់វិនិយោគិន។ ជាទូទៅភាពមិនស្មើគ្នារវាងការផ្គត់ផ្គង់ និងតម្រូវការកំពុងត្រូវក្លាយជាកត្តាដ៏សំខាន់មួយក្នុងការរួមចំណែកដល់ការកើនឡើងនូវតម្រូវការផលិតផលកសិកម្ម ហើយក៏ជាឱកាសមួយក្នុងការលើកទឹកចិត្តដល់អ្នកវិនិយោគឈានចូលក្នុងវិស័យនេះផងដែរ។ កត្តាសំខាន់ទាំងនោះមានដូចជា ៖

- ប្រជាជននៅលើពិភពលោកត្រូវបានគេរំពឹងថានឹងកើនឡើងពី៦.៨ពាន់លាននាក់ ដល់ប្រមាណ៩ពាន់លាននាក់នាឆ្នាំ២០៥០ ភាគច្រើនរំពឹងទុកទៅលើបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែលកំពុងមានប្រជាជនប្រមាណ ៥.៦ពាន់លាននាក់ក្នុងបច្ចុប្បន្ន ត្រូវបានគេប៉ាន់ប្រមាណថានឹងឈានដល់៧.៨ពាន់លាននាក់ត្រឹមឆ្នាំ២០៥០។ ប្រជាជនថ្នាក់កណ្តាលក្នុងពិភពលោកត្រូវបានគេរំពឹងថានឹងកើនឡើងពី៤៣០លាននាក់ នៅក្នុងឆ្នាំ២០០០ កើនដល់១,១៥០ពាន់លាននាក់នៅឆ្នាំ២០៣០ ដោយប្រទេសចិន និងឥណ្ឌាជាចំណែកដ៏ធំបំផុត។
- ការកើនឡើងអំណាចនៃការទិញ របស់ប្រជាជននៅក្នុងប្រទេសដែលកំពុងងើបឡើងបាននាំឱ្យមានការកើនឡើងនូវតម្រូវការម្ហូបអាហារ និងការផ្លាស់ប្តូររបៀបនៃការប្រើប្រាស់ដូចគ្នាទៅលើតម្រូវការម្ហូបអាហារដែលមានជាតិប្រូតេអ៊ីនខ្ពស់ និងសាច់។
- បន្ទាប់ពីវិបត្តិស្បៀងអាហារឆ្នាំ២០០៨បានកើតឡើង បានប៉ះពាល់ដល់តម្រូវការបន្ថែមទៀតសម្រាប់ទំនិញកសិកម្ម និងតម្រូវការថាមពលរបស់មនុស្សម្នាក់។ ចំពោះតម្រូវការថាមពលត្រូវបានគេរំពឹងថានឹងកើនឡើងយ៉ាងខ្លាំង ក្នុងឆ្នាំក្រោយដែលទាមទារឱ្យមានការពង្រឹង និងពន្លឿនការផលិតស្បៀងអាហារ ដើម្បីធ្វើទប់ទល់ជាមួយការប្រកួតប្រជែងជាមួយប្រភពថាមពល និងការប៉ះពាល់ដល់អនុវិស័យផ្សេងៗដូចជាព្រៃឈើទាំងនេះ។

### ១.៤.៣ ក្របខ័ណ្ឌគោលនយោបាយសម្រាប់ការវិនិយោគក្នុងវិស័យកសិកម្ម

ក្របខ័ណ្ឌគោលនយោបាយសម្រាប់ការវិនិយោគក្នុងវិស័យកសិកម្ម (PFIA) មានគោលបំណងគាំទ្របណ្តាប្រទេសនានាក្នុងការវាយតម្លៃ និងបង្កើតគោលនយោបាយលើកកម្ពស់ការ វិនិយោគឯកជនក្នុងវិស័យកសិកម្ម ដើម្បីកំណើនសេដ្ឋកិច្ច ស្ថិរភាព និងការអភិវឌ្ឍប្រកបដោយ ចីរភាព។ ការទាក់ទាញការវិនិយោគឯកជនក្នុងវិស័យកសិកម្ម ពឹងផ្អែកលើគោលនយោបាយគ្រប់គ្រងផ្នែកផ្គត់ផ្គង់ដ៏ទូលំទូលាយ។ យុទ្ធសាស្ត្រនេះមានសក្តានុពលខ្លាំងក្លាសម្រាប់ការលើកកម្ពស់ការវិនិយោគកសិកម្មជាមួយភាគីពាក់ព័ន្ធជាច្រើនរួមមានម្ចាស់ក្រុមហ៊ុន សហគ្រាសខ្នាតតូច និងមធ្យម កសិករពាក់កណ្តាលពាណិជ្ជកម្ម សហករណ៍ឯកជនក្នុងស្រុក និងបរទេស សហគ្រាសពហុជាតិ និងសហគ្រាសរដ្ឋ។

- **គោលនយោបាយវិនិយោគៈ**

  យុទ្ធសាស្ត្រវិនិយោគកសិកម្មគួរកំណត់ពីឧបសគ្គចម្បងៗដល់ការវិនិយោគក្នុង និងក្រៅប្រទេសតាមខ្សែសង្វាក់ផលិតកម្មកសិកម្ម និងផ្តោតលើវិស័យ សំខាន់ៗ ដែលអាចរួមចំណែកបន្ថែមក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍វិស័យកសិកម្មជាតិ រួមទាំងសន្តិសុខស្បៀង។

- **ការលើកកម្ពស់ការវិនិយោគ និងការសម្របសម្រួលៈ** សកម្មភាពលើកកម្ពស់ការវិនិយោគ និងការសម្របសម្រួលវិនិយោគទុនដូចជាការផ្សព្វផ្សាយព័ត៌មាន និងការតស៊ូមតិគោលនយោបាយនៅក្នុងទីភ្នាក់ងារតែមួយ អាចមានប្រសិទ្ធភាពខ្ពស់ និងផ្តល់ឱកាសនៃការ ទាក់ទាញវិនិយោគិនទៅកាន់ប្រទេសរបស់ខ្លួនបាន។ ខណៈប្រទេសមួយបង្កើតបរិយាកាស វិនិយោគច្បាស់លាស់ នឹងជួយជំរុញការវិនិយោគ និងវិធានការសម្របសម្រួលដ៏សំខាន់មួយក្នុងការទាក់ទាញអ្នកនិយោគថ្មីៗ ជាពិសេសទីផ្សារតូចៗ និងដាច់ស្រយាល ឬក៏ បណ្តាប្រទេសដែលមានប្រវត្តិអស្ថិរភាពនយោបាយផ្សេងៗ។

- **ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ៖**

ហេដ្ឋារចនាសម្ព័ន្ធជនបទដែលមានការអភិវឌ្ឍយ៉ាងល្អរួមមានប្រព័ន្ធធារាសាស្ត្រល្អ ប្រព័ន្ធដឹកជញ្ជូន និងប្រព័ន្ធស្តុកទុកត្រឹមត្រូវ ព្រមទាំងមានការផ្គត់ផ្គង់អគ្គិសនី បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនងជិតស្និត នោះគឺជាកត្តាដ៏សំខាន់ក្នុងការទាក់ទាញអ្នកវិនិយោគឯកជននានាចូលមកក្នុងវិស័យកសិកម្ម និងបង្កើនការប្រកួតប្រជែងផ្នែកកសិកម្ម។

-**គោលនយោបាយពាណិជ្ជកម្ម៖** កាលណាពាណិជ្ជកម្មកសិកម្មក្នុងដំណើរការល្អ និងគួរឱ្យទុកចិត្តបាន នោះក៏អាចជំរុញការវិនិយោគផងដែរ តាមរយៈការសម្រួលទីផ្សារនាំចូល និងអាចរំពឹងបានថានឹងទទួលបានអត្ថប្រយោជន៍ត្រឡប់មកវិញខ្ពស់។ ពាណិជ្ជកម្មក្នុងស្រុកពឹងផ្អែកយ៉ាងខ្លាំងទៅលើគុណភាពនៃប្រព័ន្ធដឹកជញ្ជូន និងគោលនយោបាយធ្វើនិយតកម្ម ឬការយកពន្ធលើពាណិជ្ជកម្មនានា។

-**ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ៖** ទីផ្សារហិរញ្ញវត្ថុដែលមានភាពរឹងមាំ មានភាពប្រកួតប្រជែង និងសក្តានុពលក្នុងការកាត់បន្ថយចំណាយប្រតិបត្តិការប្រមូលប្រាក់សន្សំ និងបែងចែកហិរញ្ញប្បទានប្រកបដោយប្រសិទ្ធភាពដល់អ្នកវិនិយោគ គឺជាចំណាប់អារម្មណ៍មួយសម្រាប់ឱកាសវិនិយោគ និងគ្រប់គ្រងហានិភ័យបានដ៏ល្អសម្រាប់អ្នកវិនិយោគ។

-**ធនធានមនុស្ស ការស្រាវជ្រាវ និង ការបង្កើតថ្មី៖** គោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្សគួរតែពឹងផ្អែកលើការវាយតម្លៃដោយប្រុងប្រយ័ត្នប្រកបដោយជំនាញស្របតាមតម្រូវការរបស់អ្នកវិនិយោគគ្រប់ប្រភេទ ដែលអាចត្រូវបានកំណត់បានតាមរយៈការ បណ្តុះបណ្តាលបច្ចេកទេសតាំងពីលើវិស័យឧត្តមសិក្សា និងផ្តោតសំខាន់លើផលិតកម្មកសិកម្ម ក៏ប៉ុន្តែក៏ត្រូវតែជាធាតុនៃខ្សែសង្វាក់ផលិតកម្ម និងជាពិសេសការកែច្នៃកសិផល។

-**គោលនយោបាយពន្ធ៖** ពន្ធដារផ្តល់នូវការព្យាករណ៍ និងស្ថិរភាពលំហូរនៃប្រាក់ចំណូលក្នុងស្រុកដល់រាជរដ្ឋាភិបាល

ក្នុងការអនុញ្ញាតឱ្យពួកគេផ្តល់ហិរញ្ញប្បទានចំគោលដៅអភិវឌ្ឍន៍ និងផ្គត់ផ្គង់ទំនិញ ឬសាធារណៈផ្សេងៗ។ រាជរដ្ឋាភិបាលប្រឈមនឹងបញ្ហាប្រឈមនៃការធ្វើឱ្យមានតុល្យភាពល្អប្រសើរបំផុតរវាងការបង្កើតរបបពន្ធអាជីវកម្ម ការវិនិ-យោគ និងការបង្កើនប្រាក់ចំណូលគ្រប់គ្រាន់សម្រាប់ការផ្តល់សេវាសាធារណៈដែលធ្វើឱ្យសេដ្ឋកិច្ចមានភាពទាក់ទាញដល់វិនិយោគិន ។ ពន្ធក្នុងវិស័យកសិកម្មរួមមាន ពន្ធលើការនាំចូលលើទំនិញកសិកម្ម និងពន្ធនាំចេញទំនិញកសិកម្ម (ផ្នែកពាណិជ្ជកម្ម) លើប្រាក់ចំណូលលើតម្លៃបន្ថែម និងពន្ធជាក់លាក់ផ្សេងៗរបស់ប្រទេសនានា ។

- **ការគ្រប់គ្រងហានិភ័យ៖** អ្នកវិនិយោគផ្នែកកសិកម្មប្រឈមនឹងហានិភ័យផលិតកម្ម និងតម្លៃជាចំបង។ អាកាសធាតុមិនល្អ សត្វល្អិត ជំងឺ និងតម្លៃប្រែប្រួលអវិជ្ជមានប៉ះពាល់ដល់ការវិនិយោគ និងធ្វើឱ្យកម្រិតវិនិយោគធ្លាក់ចុះ។ រាជរដ្ឋាភិបាលអាចគាំទ្រការបង្កើតឧបករណ៍គ្រប់គ្រងហានិភ័យ ដើម្បីជួយអ្នកវិនិយោគដោះស្រាយហានិភ័យទាំងនេះជាមុន និងផែនការជាបន្តបន្ទាប់។
- **ទំនួលខុសត្រូវនៅក្នុងមុខជំនួញ៖** ការដឹកនាំអាជីវកម្មប្រកបដោយការទទួលខុសត្រូវតម្រូវឱ្យមានការគោរពចំពោះស្តង់ដាដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ និងការអនុលោមទៅតាមច្បាប់ក៏ដូចជាបទបញ្ញត្តិផ្សេងៗរបស់ប្រទេសមួយ។ ខណៈពេលដែលរដ្ឋនានាត្រូវគោរពតាមកាតព្វកិច្ចអន្តរជាតិរបស់ពួកគេ នោះសហគ្រាសក្នុង និងក្រៅប្រទេសត្រូវបានគេរំពឹងថាតែងតែកើតចេញពីកាតព្វកិច្ចរៀងៗខ្លួន។ ដើម្បីការពារផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ រាជរដ្ឋាភិបាលគួរតែធ្វើការជាមួយក្រុមហ៊ុន និងអង្គការសង្គមស៊ីវិលក្នុងការពិគ្រោះយោបល់គ្នាទៅវិញទៅមក ដើម្បីលើកកម្ពស់ការផ្សព្វផ្សាយការធ្វើអាជីវកម្មប្រកប ដោយទំនួលខុសត្រូវ។

-**ការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថានប្រកបដោយចីរភាព៖** ការអនុវត្តកសិកម្មខ្នាតតូច ដូចជាការដាំដុះលើដីមិនសមស្រប

ការប្រើប្រាស់ឧបករណ៍មិនបានត្រឹមត្រូវ ឬការប្រើប្រាស់បច្ចេកវិទ្យាកសិកម្មហួសកម្រិតពេក ជាហេតុធ្វើឱ្យប៉ះពាល់ដល់គុណភាពដី ការសឹករិចរិលនៃធនធានធម្មជាតិ ការបំពុលបរិស្ថាន ការបំផ្លាញព្រៃឈើ ហើយនាំឱ្យមានការកាត់បន្ថយផលិតភាពកសិកម្ម និងការគំរាមកំហែងដល់សន្តិសុខស្បៀង រយៈពេលវែងជាខ្លាំង។ នាពេលបច្ចុប្បន្ននេះវិស័យកសិកម្ម គឺជាអ្នកប្រើប្រាស់ប្រភពទឹកដ៏ធំបំផុតនៅលើពិភពលោក និងមានទំហំប្រមាណ៧០%នៃការប្រើប្រាស់ទឹកសាបនៅលើពិភពលោក។ ដូចនេះគោលនយោបាយនេះនឹងឆ្លើយតបជាមួយបញ្ហាទាំងនេះតាមរយៈសកម្មភាពជាច្រើន។

## ១.៥ កសិកម្ម និងកំណើនសេដ្ឋកិច្ច[6]

កសិកម្មអាចធ្វើការស្របគ្នាជាមួយវិស័យដទៃទៀត ដើម្បីបង្កើនកំណើនសេដ្ឋកិច្ចបានយ៉ាងឆាប់រហ័ស កាត់បន្ថយភាពក្រីក្រ និងទ្រទ្រង់ដល់បរិស្ថាន។ កសិកម្មរួមចំណែកដល់ការអភិវឌ្ឍតាមវិធីជាច្រើន ដូចជាសកម្មភាពសេដ្ឋកិច្ច ជីវភាពរស់នៅ ផ្តល់សេវាបរិស្ថាន បង្កើនអត្រាអ្នកមានការងារធ្វើ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការផ្គត់ផ្គង់វត្ថុធាតុដើម។

### ១.៥.១ កសិកម្មជាសកម្មភាពសេដ្ឋកិច្ច

កសិកម្មអាចជាប្រភពនៃកំណើនសេដ្ឋកិច្ចជាតិ ដែលជាអ្នកផ្តល់ឱកាសវិនិយោគក្នុងវិស័យឯកជន និងជាអ្នកដឹកនាំសំខាន់នៃកសិឧស្សាហកម្ម។ តាមរបាយការណ៍ធនាគារពិភពលោកឆ្នាំ២០០៨ បានកត់សម្គាល់ឃើញថា ឧស្សាហកម្ម និងសេវាកម្មមានទំនាក់ទំនងទៅនឹងវិស័យកសិកម្ម។ ផលិតផលកសិកម្មមានសារៈសំខាន់សម្រាប់សន្តិសុខស្បៀង ពីព្រោះវាជាប្រភពមួយនៃប្រាក់ចំណូលចម្បងរបស់ប្រជាជនក្រីក្រភាគច្រើននៅតាមជនបទ ។

### ១.៥.២ កសិកម្មជាជីវភាពរស់នៅ

វិស័យកសិកម្ម គឺជាប្រភពដ៏សំខាន់សម្រាប់ជីវភាពប្រជាពលរដ្ឋ នៅជនបទទូទាំងពិភពលោកប្រមាណ៨៦% ក្នុងចំណោមប្រជាជន៥,៥ពាន់លាននាក់

[6] https://futurism.media/how-agriculture-contributes-to-economic-development, 2018.

ក្នុងនោះមានជាង៣ពាន់លាននាក់បានរស់នៅតាមជនបទក្នុងឆ្នាំ២០០៨ ដែលជាចំនួនពាក់កណ្តាលនៃមនុស្សជាតិនៅពេលនោះ ដោយ២,៥ពាន់លាននាក់បានធ្វើកិច្ចការពាក់ព័ន្ធនឹងវិស័យកសិកម្ម ហើយប្រហែល១,៥ ពាន់លាននាក់ជាកសិករតូចតាច។ ដោយសារការរីកចម្រើនផ្នែកកសិកម្ម បានធ្វើឱ្យមានការថយចុះជាង៨០%ជាសកលនៃភាពក្រីក្រនៅតាមជនបទ។ ជាក់ស្តែងការថយចុះកាន់តែច្រើននៃចំនួនជនក្រីក្រនៅតាមជនបទនៅតំបន់អាស៊ីបូព៌ា និងមហាសមុទ្រប៉ាស៊ីហ្វិកដោយសារតែលទ្ធផលនៃការរីកចម្រើនផ្នែកកសិកម្មដែរ។ ក្នុងតំបន់អាស៊ីខាងត្បូង និងអនុតំបន់សាហារ៉ាអាហ្វ្រិក ការបង្កើនការអភិវឌ្ឍន៍កសិកម្មជាអាទិភាព ដើម្បីកាត់បន្ថយភាពក្រីក្រ។

### ១.៥.៣ កសិកម្មជាអ្នកផ្តល់សេវាបរិស្ថាន

ក្នុងការប្រើប្រាស់ធនធានធម្មជាតិ កសិកម្មអាចបង្កើតលទ្ធផលល្អសម្រាប់បរិស្ថាន។ កសិកម្មទាមទារប្រើប្រាស់ទឹកច្រើនបំផុត ប្រសិនបើការប្រើប្រាស់ទឹកខុសបច្ចេកទេស នោះនឹងនាំឱ្យមានបញ្ហាកង្វះទឹក។ កសិកម្មក៏ដើរតួដ៏សំខាន់ក្នុងការកាត់បន្ថយទឹកក្រោមដី ការបំពុលបរិស្ថានដោយការប្រើជីគីមី ដីខ្សោះជីជាតិ និងការប្រែប្រួលអាកាសធាតុសកល។ វិស័យកសិកម្មមានប្រមាណ៣០%នៃការបំភាយឧស្ម័នផ្ទះកញ្ចក់។ កសិកម្មគឺជាអ្នកផ្តល់សេវាបរិស្ថានដ៏សំខាន់វាប្រមូលផ្តុំកាបូន គ្រប់គ្រងទឹក ជម្រក និងថែរក្សាជីវចម្រុះ។ ការគ្រប់គ្រងទំនាក់ទំនងរវាងកសិកម្មការអភិរក្សធនធានធម្មជាតិ និងបរិស្ថានត្រូវតែជាផ្នែកសំខាន់មួយ នៃការប្រើប្រាស់កសិកម្មសម្រាប់ការអភិវឌ្ឍ។

### ១.៥.៤ ការកើនឡើងនូវអត្រាអ្នកមានការងារធ្វើ

តួនាទីសំខាន់ក្នុងវិស័យកសិកម្មគឺ ផ្តល់ឱកាសការងារដល់ប្រជាជនលើការងារផលិតផលកសិកម្ម និងការលក់នូវផលិតផលកសិឧស្សាហកម្ម។ ដើម្បីដំណើរការកិច្ចការនេះមានភាពល្អប្រសើរ ទាមទារឱ្យសហគ្រាសកំណត់នូវសង្វាក់ផលិតកម្ម កំណត់តួនាទីភារកិច្ចនៃកម្លាំងពលកម្មឱ្យបានច្បាស់លាស់ ដើម្បីធានាការផលិតឱ្យទាន់ពេលវេលា និងស្របតាមតម្រូវការក្នុងការផ្គត់ផ្គង់ក្នុងស្រុក និងសម្រាប់ធ្វើពាណិជ្ជកម្មក្រៅប្រទេស ។

### ១.៥.៥ ការកើនឡើងនូវហេដ្ឋារចនាសម្ព័ន្ធ

នៅពេលដែលប្រទេសមួយ ផ្តោតលើការជំរុញអភិវឌ្ឍន៍កសិកម្ម នោះវានឹងជួយជំរុញនូវកំណើនឧស្សាហកម្មខ្នាតតូចនៅក្នុងតំបន់នោះផងដែរ។ ដំណើរការផលិតនូវផលិតផលកសិកម្ម និងលក់នូវផលិតផលកសិឧស្សាហាកម្ម វាមានប្រតិបត្តិការពាក់ព័ន្ធគ្នាជាច្រើនដែលតម្រូវឱ្យមានការអភិវឌ្ឍផ្លូវថ្នល់ ឃ្លាំងស្តុក គ្រឿងបរិក្ខារវេចខ្ចប់ និងសេវាដឹកជញ្ជូនបន្ថែមលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធថ្មីៗ ។

### ១.៥.៦ ការជួយផ្គត់ផ្គង់វត្ថុធាតុដើម

កសិកម្មជួយផលិតវត្ថុធាតុដើម ដែលជាតម្រូវការសម្រាប់ឧស្សាហាកម្មផ្សេងៗទៀត ដែលវត្ថុធាតុដើមទាំងនេះ ត្រូវបានប្រើប្រាស់យ៉ាងច្រើនក្នុងសង្វាក់ផលិតកម្មកសិឧស្សាហាកម្ម។ ប្រសិនបើការផ្គត់ផ្គង់វត្ថុធាតុដើម មិនស្របតាមតម្រូវការនៃការបញ្ជាទិញនោះទេ វាអាចប៉ះពាល់ដល់ខ្សែសង្វាក់ផលិតកម្មទាំងមូល ដែលអាចជះឥទ្ធិពលដល់សេដ្ឋកិច្ច ហើយអាចបង្កឱ្យមានឧបសគ្គនៅក្នុងកំណើនសេដ្ឋកិច្ចរបស់ប្រទេសផងដែរ។ ជាលទ្ធផលបើសេដ្ឋកិច្ចរបស់ប្រទេសជាតិជួបបញ្ហា នោះអាចនឹងមានប៉ះពាល់ដល់ការចំណាយបន្ថែមទៀតសម្រាប់ប្រជាជន។

សរុបមកវិស័យកសិកម្មចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការបង្កើតប្រាក់ចំណូល មូលធនសម្រាប់ប្រទេសមួយ តាមមធ្យោបាយជាច្រើន ជាក់ស្តែងដូចកត្តាខាងលើ។ ដូច្នេះនៅពេលដែល វិស័យកសិកម្មមានការរីកចម្រើន វាជាកត្តាដ៏សំខាន់ក្នុងការរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសមួយ ពីព្រោះវាជាផ្នែកនៃការចាប់ផ្តើមដោះស្រាយបញ្ហានៅក្នុងវិស័យដទៃទៀត ជាពិសេស គឺបង្កើនប្រាក់ចំណូលសម្រាប់សេដ្ឋកិច្ច ដែលជាកត្តាជំរុញឱ្យមានកំណើនសេដ្ឋកិច្ច ។

## ១.៦ ទ្រឹស្តីមូលដ្ឋាននៃស្តង់ដានៃការរស់នៅ[7]

Plato (1983) បានកំណត់ថា "ស្តង់ដានៃការរស់នៅ" គឺជាកម្រិតដែលតម្រូវការរបស់មនុស្សត្រូវបានបំពេញ។

[7]MFIs, Theory Base Living Standard [ទ្រឹស្តីមូលដ្ឋាននៃស្តង់ដាសការរស់នៅ] (2007), 4.

ក្នុងនោះដែរគាត់បានរួមបញ្ចូលទាំងតម្រូវការសម្រាប់អាហារ ជម្រក និង សំលៀកបំពាក់។

Mark (1981) បានកំណត់ថា "ស្តង់ដានៃការរស់នៅ" មានន័យថាកម្រិតដែលប្រជាពលរដ្ឋអាចប្រមូលធនធាន និងដើម្បីបង្កើនជីវភាពរស់នៅរបស់ពួកគេតាមរយៈប្រាក់ចំណូលសម្រាប់ ម្ហូបអាហារ ផ្ទះសម្បែង ការអប់រំ។ ល។

Keynes (1936) បានកំណត់ថា "ស្តង់កានៃរស់នៅ" គឺកំណត់ភាពខុសគ្នារវាងកម្រិតនៃទ្រព្យសម្បត្តិដែលទទួលបាន។ Keynes បានអះអាងថាកម្រិតនៃការចំណាយរបស់មនុស្សត្រូវបានកំណត់ដោយប្រាក់ចំណូលរបស់គាត់។ ប្រាក់ចំណូលរបស់បុគ្គលម្នាក់ៗកាន់តែខ្ពស់ គាត់អាចប្រើប្រាស់បានកាន់តែច្រើនហើយដូច្នេះកម្រិតជីវភាពរស់នៅកាន់តែល្អប្រសើរ។

Narayan, Chambers et al (2000) បានកំណត់ទ្រឹស្តីស្តង់ដានៃការរស់នៅជាសកលដូចខាងក្រោម៖

- មានអាហារគ្រប់គ្រាន់
- មានទ្រព្យសម្បត្តិគ្រប់គ្រាន់
- បានធ្វើការដើម្បីទទួលបានប្រាក់ចំណូល
- មានសុខភាពល្អ
- មានការគោរពខ្លួនឯង និងសេចក្តីថ្លៃថ្នូរ
- មានសន្តិភាព និងភាពសុខដុម
- មានបរិយាកាសសុវត្ថិភាព
- មានទំនុកចិត្តលើអនាគត
- ផ្តល់សេរីភាពក្នុងការជ្រើសរើស និងធ្វើសកម្មភាព។

Narayan (2000) ស្តង់ដានៃការរស់នៅសំដៅទៅលើកម្រិតទ្រព្យសម្បត្តិ សុខមាលភាព សម្ភារ និងទំនិញដែលចាំបាច់ ដែលបានកំណត់សម្រាប់ថ្នាក់សេដ្ឋកិច្ច នៃសង្គមជាក់លាក់មួយ និងក្នុងតំបន់ភូមិសាស្ត្រជាក់លាក់មួយ។ ស្តង់ដានៃការរស់នៅពាក់ព័ន្ធនឹងកត្តាដូចជា ប្រាក់ចំណូល គុណភាព និងលទ្ធភាពនៃការងារ គុណភាព និងតំលៃសមរម្យនៃផ្ទះសម្បែង

ផលិតផលក្នុងស្រុកសរុប លទ្ធភាពទទួលបានការថែទាំសុខភាព គុណភាព និងលទ្ធភាពទទួលបានការអប់រំ អាយុកាលរំពឹងរស់ជាមធ្យម អត្រាកើតមានឱកាសនៃជំងឺ ថ្លៃទំនិញនិងសេវាកម្ម ហេដ្ឋារចនាសម្ព័ន្ធ កំណើនសេដ្ឋកិច្ច ស្ថិរភាពសេដ្ឋកិច្ចនិងនយោបាយ សេរីភាពនយោបាយ និងសាសនា រួមទាំងគុណភាពនៃបរិស្ថាន។

ស្តង់ដានៃការរស់នៅត្រូវបានវាស់វែង ដោយផ្អែកលើផលិតផលសរុបក្នុងក្នុងមនុស្សម្នាក់ៗ គឺជាផលិតផលក្នុងស្រុកសរុបរបស់ប្រទេសមួយដែលបែងចែកដល់ប្រជាជនរបស់ខ្លួន។ ផលិតផលក្នុងស្រុកសរុប គឺជាផលិតផលសរុបនៃទំនិញនិងសេវាកម្ម ដែលផលិតក្នុងមួយឆ្នាំដោយមនុស្សគ្រប់រូបនៅក្នុងព្រំដែនរបស់ប្រទេស។

## ១.៧ កំណើនសេដ្ឋកិច្ច និងស្តង់ដានៃការរស់នៅ[8]

កំណើនសេដ្ឋកិច្ច គឺជាការកើនឡើងនូវទំនិញនិងសេវាកម្ម ដែលបានផលិតក្នុងកំឡុងពេលជាក់លាក់ណាមួយនៅក្នុងសេដ្ឋកិច្ចនៃប្រទេសមួយ។ ការបង្កើនទំនិញ ដើមទុន កម្លាំងពលកម្ម បច្ចេកវិទ្យា និងធនធានមនុស្សជាកត្តារួមចំណែកដល់កំណើនសេដ្ឋកិច្ច។ ភាពប្រសើរឡើងនៃស្តង់ដានៃការរស់នៅ ឬកម្រិតជីវភាពកើនឡើង គឺជាលទ្ធផលដោយផ្ទាល់នៃកំណើនសេដ្ឋកិច្ច។ មនុស្សម្នាក់ៗមានការកើនឡើងក្នុងការប្រើប្រាស់ទំនិញនិងសេវាកម្ម ដោយសារតែផលិតកម្មក្នុងមនុស្សម្នាក់ៗ (ឬទិន្នផល) នៃទំនិញ និងសេវាកម្មបានកើនឡើង ដូច្នេះនៅពេលដែលយើងផលិតបានច្រើនយើងអាចប្រើប្រាស់បានច្រើនដូចគ្នា ។

**ខាងក្រោមនេះជាអត្ថប្រយោជន៍នៃកំណើនសេដ្ឋកិច្ច ៖**

**ការបង្កើនការប្រើប្រាស់**

នៅពេលមានកំណើនសេដ្ឋកិច្ចបានន័យថាអ្នកប្រើប្រាស់អាចទទួលបានផលប្រយោជន៍ពីការប្រើប្រាស់ទំនិញ និងសេវាកម្មកាន់តែច្រើន នេះសបញ្ជាក់ឱ្យឃើញថាមនុស្សអាចបំពេញនូវតម្រូវការចាំបាច់របស់ពួកគេបានគ្រប់គ្រាន់ ឬបង្កើនគុណភាពនៃការការប្រើប្រាស់ឱ្យកាន់តែល្អប្រសើរ ព្រមទាំងធ្វើឱ្យកម្រិតជីវភាពនៃការរស់នៅមានការកើនឡើង។

**ការកែលម្អសេវាកម្មសាធារណៈ:** ដោយសារចំណូលពន្ធកើនឡើង រាជរដ្ឋាភិបាលអាចបង្កើនចំណាយលើសេវាកម្មសាធារណៈសំខាន់ៗដូចជា សុខភាព

[8] https://www.intelligenteconomist.com/economic-growth/, published June 9, 2019.

និងការអប់រំឱ្យកាន់តែមានភាពប្រសើរឡើង។ ការកែលម្អការថែទាំសុខភាព អាចជួយបង្កើនគុណភាពជីវិតតាមរយៈការពារ ព្យាបាលជំងឺ និងការបង្កើនអាយុជីវិត។ ការអប់រំត្រូវបានគេមើលឃើញថាជាកត្តាសំខាន់មួយនៃ បណ្តុះបណ្តាលធនធានមនុស្ស កសាងសមត្ថភាព និងជំនាញដើម្បីឱ្យពួកគេក្លាយសសរទ្រូងដ៏ រឹងមាំរបស់ប្រទេសជាតិ។ ទាំងនេះបង្ហាញពីឱកាស និងផលប្រយោជន៍ជាច្រើនដែលប្រជាជនអាចទទួលបានពីសេវាសារណៈដែលជាផ្នែកមួយធ្វើឱ្យជីវភាព ក៏ដូចជាស្តង់ដានៃការរស់នៅប្រជាជនមានភាពល្អប្រសើរ។

**កាត់បន្ថយនិកម្មភាព និងភាពក្រីក្រ** កំណើនសេដ្ឋកិច្ចជួយកាត់បន្ថយភាពអត់ការងារធ្វើ តាមរយៈបង្កើតការងារ ដោយសារតែស្ថានភាពសេដ្ឋកិច្ចមានភាពវិជ្ជមាន តម្រូវការប្រើប្រាស់ឡើង នាំឱ្យការផលិតមានការកើន ហេតុនេះតម្រូវការនៃធនធានមនុស្ស ក៏មានការកើនឡើង។ និកម្មភាព គឺជាប្រភពដ៏សំខាន់មួយនៃបញ្ហាសង្គមនានាដូចជា ឧក្រិដ្ឋកម្មជាដើម ។ មិនតែប៉ុណ្ណោះ វារួមចំណែកដ៏ធំក្នុងការកាត់ភាពក្រីក្រ ដូច្នេះនៅពេលមានកំណើនសេដ្ឋកិច្ច បញ្ហានិកម្មភាព និងភាពក្រីក្រនឹងមានការធ្លាក់ចុះ ។

**បង្កើនការចំណាយលើការការពារបរិស្ថាន** ដោយសារផលិតផលក្នុងស្រុកសរុបខ្ពស់ជាងមុន ប្រទេសនឹងមានចំណូល និងធនធានបន្ថែមទៀតក្នុងការប្រើប្រាស់ដើម្បីលើកកម្ពស់ ការជំរុញការប្រើប្រាស់ធនធានកកើតឡើងវិញ ដែលជាផ្នែកមួយក្នុងការកាពារ ថែរក្សាបរិស្ថាន កាត់បន្ថយនូវការបំពុលនានា។

**បង្កើនការវិនិយោគ** កំណើនសេដ្ឋកិច្ចជំរុញឱ្យក្រុមហ៊ុនវិនិយោគមានបំណងចង់បង្កើតការវិនិយោគ ឬបង្កើនទុនវិនិយោគដើម្បីបំពេញតម្រូវការនាពេលអនាគត។ ការវិនិយោគនឹងបង្កើនវិសាលភាពសម្រាប់កំណើនសេដ្ឋកិច្ច បន្តទៀតនាពេលអនាគត រួមទាំងជាផ្នែកមួយដ៏សំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច។

**បង្កើនការស្រាវជ្រាវ និងអភិវឌ្ឍន៍** កំណើនសេដ្ឋកិច្ចខ្ពស់ នាំឱ្យការវិនិយោគទទួលបានផលចំណេញច្រើន ដែលជាកត្តាជំរុញបន្ថែមសម្រាប់ការស្រាវជ្រាផងនិងអភិវឌ្ឍន៍បន្ថែមទៅលើ វិស័យដែលពាក់ព័ន្ធផងដែរ។

ជាទូទៅការស្រាវជ្រាវ តែងធ្វើឡើងដើម្បីសិក្សាពីអ្វីបញ្ហា និងកង្វះខាតនានា ដើម្បីរិះរកដំណោះស្រាយ ឬស្វែងរកអ្វីដែលថ្មី និងបង្កជាលក្ខណៈងាយស្រួលជាមុន ហេតុនេះវាផ្តល់អត្ថប្រយោជន៍ជាច្រើន ដើម្បីជួយឱ្យសេដ្ឋកិច្ចនិងជីវភាពប្រជាជនមានការរីកចម្រើន។ កំណើនសេដ្ឋកិច្ចនាំឱ្យមានជីវភាពរស់នៅកាន់ល្អតែល្អប្រសើរ ពីព្រោះប្រសិនបើកំណើនសេដ្ឋកិច្ចនៅក្នុងស្រុកកើនឡើង មានន័យថាអាជីវកម្មអាចរកបានប្រាក់ចំណេញច្រើន ដូច្នេះឱកាសការងារ និងប្រាក់ឈ្នួលក៏មានការកើនឡើង មានន័យថាGDPក្នុងមនុស្សម្នាក់ និងក្នុងគ្រួសារកើនឡើង។ ដូច្នេះប្រាក់ចំណូល មានការកើនឡើង បានន័យថាពួកគេអាចទិញទំនិញ និងសេវាបន្ថែមទៀតជាមួយនឹងប្រាក់ចំណូលរបស់ពួកគេ ដែលនេះជាកត្តាបង្ហាញថាស្តង់ដានៃការរស់នៅរបស់ប្រជាជនមានការកើនឡើង។

សរុបមក កំណើនសេដ្ឋកិច្ចផ្តល់អត្ថប្រយោជន៍ជាច្រើនដែលកត្តាជំរុញឱ្យស្តង់ដានៃការរស់នៅរបស់ប្រជាជនមានភាពល្អប្រសើរ ដែលអត្ថប្រយោជន៍ទាំងនេះអាចមើលឃើញភាគច្រើននៅក្នុងប្រទេសកំពុងអភិវឌ្ឍ។ កំណើនសេដ្ឋកិច្ចសម្រួលក្នុងការដោះស្រាយបញ្ហាធ្ងន់ធ្ងរជាច្រើនដូចជាភាពក្រីក្រ និកម្មភាព និងបញ្ហាកង្វះខាតនូវតម្រូវជាការមូលដ្ឋានផងដែរ។

# ជំពូកទី២

# ស្ថានភាព និងតួនាទីនៃការវិនិយោគលើដំណាំស្រូវនៅកម្ពុជា

## ២.១ ស្ថានភាពវិស័យកសិកម្ម[9]

វិស័យកសិកម្មនៅតែមានតួនាទីសំខាន់ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ច ធានាសមធម៌ ធានាសន្តិសុខស្បៀង និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ។ ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលគឺការធ្វើទំនើបកម្មវិស័យ កសិកម្មកម្ពុជាតាមអភិក្រម និងក្នុងវិសាលភាពនិងល្បឿនថ្មី ដើម្បីប្រែក្លាយ វិស័យនេះពីដំណាក់កាលនៃការអភិវឌ្ឍតាមបែបវិបុលកម្ម (បើកទូលាយ) ពោលគឺពឹងផ្អែកជាសំខាន់លើធនធានមានស្រាប់ (ធនធានដីនិង ធនធានធម្មជាតិផ្សេងទៀត) និងពឹងផ្អែកលើការប្រើប្រាស់ធាតុចូលកសិកម្មតាមបែបប្រពៃណី ឈានទៅរកដំណាក់កាលថ្មីដែលផ្តោតផលិតកម្មតាមបែបប្រពលវប្បកម្ម ពោលគឺពឹងផ្អែកជាសំខាន់ លើការប្រើប្រាស់បច្ចេកទេស បច្ចេកវិទ្យាថ្មី ការស្រាវជ្រាវ និងការអភិវឌ្ឍយន្តូបនីយកម្ម ព្រមទាំងការបង្កើន សមត្ថភាពស្រោចស្រព ដើម្បីលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្មមុខដំណាំ និងផលិតផលកសិកម្មផ្សេងទៀត រួមទាំងការចិញ្ចឹមសត្វ និងវារីវប្បកម្មផង ដោយគិតគូរផងដែរអំពីភាពចាំបាច់ក្នុងការគ្រប់គ្រងដីធ្លីប្រកបដោយប្រសិទ្ធភាព និងការធានាចីរភាព បរិស្ថាននិងធនធានធម្មជាតិ។ ទន្ទឹមនេះការបន្តជំរុញការធ្វើពាណិជ្ជូបនីយកម្ម និងការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម នឹងជួយបង្កើនតម្លៃបន្ថែមនៃផលិតផលកសិកម្ម ក៏ដូចជាជួយបង្កើនចំណូលជូនកសិករ។

ការរួមចំណែករបស់កសិកម្មចំពោះកំណើនផលិតផលក្នុងស្រុកសរុប មានភាពប្រសើរឡើងវិញ ដោយសារកត្តាអាកាសធាតុមានភាពប្រសើរឡើងក្នុងអំឡុងពេលពីរឆ្នាំចុងក្រោយនេះ។ វិស័យកសិកម្មបានបានចូលរួមចំណែក១៨,១%នៃផ.ស.ស បានបន្តកើនឡើងក្នុងល្បឿនយឺត និងត្រូវបានប៉ាន់ស្មានថាមានកំណើនប្រមាណ១,៣% ទាបជាងឆ្នាំមុនបន្តិច១,៧% ដែលបណ្តាលមកពីផលប៉ះពាល់ដោយសារគ្រោះទឹកជំនន់ និងកង្វះខាតទឹកនៅតំបន់មួយចំនួនដែលធ្វើឱ្យប៉ះពាល់ដល់ដំណាំ។ គ្រោះទឹកជំនន់ទន្លេមេគង្គ

[9] ធនគារជាតិ នៃកម្ពុជា, របាយការណ៍ប្រចាំឆ្នាំ (២០១៨), ទំព័រ៦។

បណ្តាលមកពីការបាក់ទំនប់វារីអគ្គិសនីនៅប្រទេសឡាវ គួបផ្សំនឹងទឹកជំនន់ទឹកភ្លៀងដោយសារតែរដូវវស្សានេះមានតំបន់មួយចំនួន មិនសូវមានទឹកភ្លៀង ធ្វើឱ្យខូចខាតដីដាំដុះស្រូវប្រមាណ២៣០,៦៣ពាន់ហិកតា។ បរិមាណស្រូវនៅរដូវប្រាំងកើនប្រមាណ៦,៧% ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន ២,៥លានតោន ហើយទិន្នផលស្រូវប្រាំងបានកើនពី៤,៤៧ តោនក្នុងមួយហិកតានៅឆ្នាំ២០១៧ ដល់៤,៥១ តោនក្នុងមួយហិកតានៅឆ្នាំ២០១៨។ នៅឆ្នាំ២០១៩នេះ វិស័យកសិកម្មត្រូវបានរំពឹងថា កើនឡើងខ្ពស់ជាងឆ្នាំ២០១៨បន្តិច ក្នុងអាត្រា២%ដោយសារកំណើន លំហូរចូលនៃការវិនិយោគផ្ទាល់បរទេស យន្តតូបនីយកម្មកសិកម្ម និងគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍវិស័យនេះ។ វិស័យកសិកម្មទទួលបានការស្តារឡើងវិញជាលើកដំបូង ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះបន្ទាប់ពីអាកាសធាតុ មានភាពអំណោយផល និងការកើនឡើងវិញនូវតម្លៃកសិកម្ម ។ ទោះយ៉ាងណាវិស័យកសិកម្មនៅមានបញ្ហាប្រឈមមួយចំនួន ដូចជាការកើនឡើងថ្លៃផលិតផលកសិកម្ម ស្របពេលដែល បច្ចេកទេសដាំដុះ និងការធ្វើទំនើបកម្មនៅមានកម្រិតនៅឡើយ។

វិស័យកសិកម្ម គឺជាសសរស្តម្ភមួយក្នុងចំណោមសសរស្តម្ភទាំង៤ នៃសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ទោះជាយ៉ាងណាក៏ដោយកម្ពុជានៅតែស្ថិតក្នុងដំណាក់កាលដំបូងនៃការផ្លាស់ប្តូរកសិកម្មរបស់ខ្លួន ដូចដែលបានបង្ហាញដោយកម្រិតនៃការវិនិយោគ និងផលិតភាពដីរបស់ខ្លួនបើប្រៀបធៀបទៅនឹងប្រទេសជិតខាងក្នុងតំបន់។ ស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ប្រទេសកម្ពុជា គឺជាប្រទេសមួយក្នុងចំណោម បណ្តាប្រទេសកំពុងអភិវឌ្ឍន៍លឿនបំផុតនៅទ្វីបអាស៊ីជាមួយនឹងអត្រាកំណើនGDPជាមធ្យម៧% ក្នុងទសវត្សរ៍កន្លងមកនេះ។ ប្រជាជនកំពុងកើនឡើងយ៉ាងឆាប់រហ័ស (១,៦% ជារៀងរាល់ឆ្នាំ) ដែលមានន័យថាទីផ្សារក្នុងស្រុកកំពុងមានការកើនឡើង។ ដូចគ្នានេះដែរចំនួនប្រជាជននៅតាមទីប្រជុំជន ក៏កំពុងតែកើនឡើងដែរ ថ្វីបើប្រជាជនកម្ពុជាភាគច្រើននៅតែរស់នៅក្នុងទីជនបទហើយមានចំនួន៨២%

នៃកម្លាំងពលកម្មសរុប ប្រកបរបរកសិកម្ម ដែលបានផ្តល់២៦.៧% នៃផលិតផលក្នុងស្រុកសរុបនៅឆ្នាំ២០១៧។ លក្ខណៈភូមិសាស្ត្ររបស់កម្ពុជាមានភាពអំណោយផលដល់កសិកម្ម ដែលប្រមូលផ្តុំដោយ ដីទំនាប ជ្រលងភ្នំ និងប្រភពទឹកសាប ជាពិសេសគឺអាកាសធាតុរបស់ប្រទេសកម្ពុជាក៏ អំណោយផងដែរ ព្រោះទទួលបានអត្ថប្រយោជន៍ពីរដូវខ្យល់មូសុង ដែលត្រូវបានផ្សារភ្ជាប់ជាមួយនឹងភ្លៀងធ្លាក់ខ្លាំងហើយ សីតុណ្ហភាពនៅមានកម្រិតខ្ពស់ពេញមួយឆ្នាំ។ ភាពអំណោយទានធម្មជាតិទាំងនេះគឺអំណោយផលខ្លាំងណាស់សម្រាប់ការដាំដុះស្រូវ (ដែលតំណាង ៦៨% នៃផ្ទៃដីដាំដុះទាំងអស់ក្នុងឆ្នាំ២០១៣) និងដំណាំផ្សេងៗដទៃទៀត ។

ស្រូវ គឺជាដំណាំចម្បងរបស់ប្រទេសកម្ពុជាដោយមានផលិតកម្មសរុបចំនួន ៩,៩៥ លានតោនក្នុងឆ្នាំ២០១៦។ ប្រទេសកម្ពុជាបាននាំចេញអង្ករចំនួន ៦៣៥,៦៧៩ តោនក្នុងឆ្នាំ២០១៧។ ពូជដែលបាននាំចេញជាទូទៅមានគុណភាពខ្ពស់ដូចដែលបានបង្ហាញដោយ "ពានរង្វាន់អង្ករល្អបំផុតនៅលើពិភពលោក" ដែលទទួលបានដោយពូជមួយប្រភេទនៃអង្ករក្រអូបកម្ពុជានៅឆ្នាំ ២០១២ ២០១៣ និងឆ្នាំ២០១៤។ ការនាំចេញអង្ករត្រូវបានកំណត់អាទិភាពដោយរាជរដ្ឋាភិបាលស្របតាមកិច្ចព្រមព្រៀងជាច្រើនជាមួយបណ្តាប្រទេសជាមិត្ត ដែលបានធ្វើឱ្យប្រទេសកម្ពុជាធ្វើពិពិធកម្មដៃគូពាណិជ្ជកម្មរបស់ខ្លួនទៅដល់ទៅ៦៣ប្រទេស នៅឆ្នាំ២០១៧។ ផលិតកម្មរបស់ប្រទេសកម្ពុជាត្រូវបានបែងចែករវាងស្រូវវស្សា និងរដូវប្រាំង ដែលការដាំដុះក្នុរដូវវស្សាតំណាងឱ្យ ៨០%នៃទិន្នផលសរុប និងរដូវប្រាំងគឺពឹងផ្អែកទៅលើបច្ចេកទេសប្រព័ន្ធធារាសាស្ត្រដើម្បីអាចផ្តល់ទិន្នផលខ្ពស់។[10]

តាមន័យធម្មជាតិ និងវិទ្យាសាស្ត្រ វិស័យកសិកម្មនៅតែដើរតួនាទីធំដដែល ដោយបានធ្វើជាជនទួល់សេដ្ឋកិច្ច ជំរុញកំណើនសេដ្ឋកិច្ច និងសម្រាប់ដោះស្រាយបញ្ហាជាតិ។ វិស័យកសិកម្មកើនឡើងនឹងមានភាពល្អប្រសើរ ពីព្រោះវាបានធ្វើឱ្យទំនិញនានាចុះថោក ហើយធ្វើឱ្យវិស័យផ្សេងៗ

[10] Netherlands embassy in Bangkok , Agriculture in Cambodia (2018)

ទៀតដូចជា ឧស្សាហកម្ម សេវាកម្ម និងទេសចរណ៍កើនឡើង។ ប្រទេសមួយមិនអាចអភិវឌ្ឍន៍វិស័យឧស្សាហកម្មបានទេ ប្រសិនបើទំនិញម្ហូបអាហារឡើងថ្លៃ ព្រោះវាជះឥទ្ធិពលដល់កម្មករ តែបើសិនជាទំនិញចុះថោក នោះនឹងផ្តល់ឥទ្ធិពលវិជ្ជមានដល់វិស័យដទៃទៀត ។ ការអភិវឌ្ឍវិស័យកសិកម្មឱ្យបានល្អ វានឹងជះឥទ្ធិពលល្អដល់វិស័យផ្សេងៗទៀត។ កាលណាកសិកម្មអភិវឌ្ឍន៍ល្អ មានន័យថា មនុស្សមានការងារធ្វើច្រើន ទទួលបានចំណូលច្រើន និងចំណាយច្រើន ដែលជះឥទ្ធិពលដល់សេដ្ឋកិច្ចទៀត។ មួយវិញទៀត កាលណាប្រជាកសិករធ្វើកសិកម្មច្រើនធ្វើឱ្យតម្លៃម្ហូបអាហារថោក ដែលជាការសម្រួលដល់ការចំណាយរបស់មន្ត្រីរាជការ និងពលរដ្ឋ ។

GDP ពីវិស័យកសិកម្មនៅក្នុងប្រទេសកម្ពុជាបានកើនឡើងដល់ ៩៤០១.២០ ពាន់លានរៀលក្នុងឆ្នាំ ២០១៧ ពី ៩២៤០.៦០ ពាន់លានរៀលក្នុងឆ្នាំ ២០១៦។ GDP មកពីកសិកម្មនៅក្នុងប្រទេសកម្ពុជាជាមធ្យមមាន ៧២១១.៩២ ពាន់លានរៀលពីឆ្នាំ ១៩៩៨ ដល់ ២០១៧ ឈានដល់កម្រិតខ្ពស់បំផុត ៩៤០១.២០ ពាន់លានរៀលនៅឆ្នាំ២០១៧ និងទាបបំផុតចំនួន ៤៧៥៦.៩០ ពាន់លានរៀលនៅឆ្នាំ ១៩៩៨ ។

រូបភាពទី១៖ GDP ពីវិស័យកសិកម្មពីឆ្នាំ២០១០-២០១៨




## ២.២ ស្ថានភាពផលិតកម្មដំណាំស្រូវនៅកម្ពុជា ចន្លោះឆ្នាំ២០០៨-២០១៨

### ២.២.១ ស្ថានភាពទូទៅនៃផលិតកម្មដំណាំស្រូវ

ចាប់ពីឆ្នាំ១៩៩០មក អាស្រ័យដោយមានកំណែទម្រង់លើប្រព័ន្ធនៃរបបនយោបាយជាតិ និងការប្រែក្លាយពីរបបនៃប្រព័ន្ធប្រមូលផ្តុំ ឬសង្គមនិយម មកជារបបទីផ្សារសេរីវិញ ជាពិសេស

ក្រោយកិច្ចព្រមព្រៀងសន្តិភាព និងការបង្រួបបង្រួមជាតិនៅទីក្រុងប៉ារីសថ្ងៃទី២៣ តុលា ១៩៩១មកធ្វើឱ្យផលិតកម្មស្រូវត្រូវបានជំរុញ និងបង្កើនយកចិត្តទុកដាក់យ៉ាងខ្លាំងក្លា។

នៅក្នុងរយៈពេលចន្លោះឆ្នាំ២០០៨ ដល់២០១២ ផ្ទៃដីដាំដុះដំណាំស្រូវបានកើនឡើងយ៉ាងឆាប់រហ័សពី២.៦លានហិកតា និងមានបរិមាណស្រូវប្រមាណ៧.១៧លានតោន នៅក្នុងឆ្នាំ២០០៨ ហើយកើនដល់ជាង៣លានហិកតា និងមានបរិមាណស្រូវប្រមាណ៩.២៩លានតោន នៅក្នុងឆ្នាំ២០១២ និងមានស្បៀងអាហារសល់ពីការហូបចុកគិតជាស្រូវប្រមាណ៤,៧៣លានតោន និងគិតជាអង្ករសល់ប្រមាណជិត៣លានតោន សម្រាប់ការនាំចេញ។ រហូតមកដល់ឆ្នាំ២០១៧ ដំណាំស្រូវមានការដាំដុះនៅលើផ្ទៃដី ២,៩៨៩,៦៣១ហិកតា និងប្រមូលផលបាន ៧,១៨៤,៩០៦តោន និងឆ្នាំ២០១៨ មានផ្ទៃដីដាំដុះ៣.២០៩លានហិកតា និងប្រមូលផលបាន ៧,៨០៤,៩០៦តោន។ សម្រាប់ឆ្នាំ២០១៩ គិតត្រឹមខែឧសភាយើងរកបានតែទិន្នន័យនៃការបង្កបង្កើនផលស្រូវវស្សា នៅទូទាំងប្រទេសប៉ុណ្ណោះនៅលើផ្ទៃដីចំនួន៤៨៤,០០៧ហិកតា។[11](មើលបន្ថែមក្នុងឧបសម្ព័ន្ធទី២ និងទី៣)

តារាងទី១ ៖ ផលិតកម្មដំណាំស្រូវចន្លោះ២០០៨ ដល់ ២០១៨

| បរិយាយ | ផ្ទៃដីដាំដុះ(ហាត) | ផ្ទៃដីប្រមូលផល(ហាត) | ទិន្នផល(តោន/ហាត) | បរិមាណ(តោន) | បរិមាណអង្ករសល់(តោន) | គិតជាស្រូវសល់(តោន) |
|---|---|---|---|---|---|---|
| ២០០៨ | ២,៦១៥,៧៤១ | ២,៦១៣,៣៦៣ | ២.៧៤៦ | ៧,១៧៥.៤៧៣ | ២,០២៥,០៣៣ | ៣,១៦៤,១១៤ |
| ២០០៩ | ២,៧១៩,០៨០ | ២,៦៧៤,៦០៣ | ២.៨៣៦ | ៧,៥៨៥,៨៧០ | ២,២៤៤,៥៩៨ | ៣,៥០៧,១៨៥ |
| ២០១០ | ២,៧៩៥,៨៩២ | ២,៧៧៧,៣២៣ | ២.៩៧ | ៨,២៤៩,៤៥២ | ២,៥១៦,៧៥២ | ៣,៩៣២,៤២៥ |
| ២០១១ | ២,៩៦៨,៥២៩ | ២,៧៦៦,៦១៧ | ៣.១៧៣ | ៨,៧៧៩,៣៦៥ | ២,៧៨០,៣២៨ | ៤,៣៤៤,២៦៣ |
| ២០១២ | ៣,០០៧,៥៤៥ | ២,៩៨០,២៩៧ | ៣.១១៧ | ៩,២៩០,៩៤០ | ៣,០៣១,០១៧ | ៤,៧៣៥,៩៦៤ |
| ២០១៣ | ៣,០៥២,៤២០ | ២,៩៦៨,៩៦៧ | ៣.១៦៣ | ៩,៣៨៩,៩៦១ | ៣,០៩០,៤៥២ | ៤,៨២៨,៨៣២ |
| ២០១៤ | ៣,០៥៥,៥០៧ | ៣,០២៨,៨៣៦ | ៣.០៧៩ | ៩,៣២៤,៤១៦ | ៣,០១៣,៧៨៣ | ៤,៧០៩,០៣៦ |

[11] ក្រសួងរុក្ខាប្រម៉ាញ់ និងនេសាទ, របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ និងទិសដៅសម្រាប់ឆ្នាំបន្ទាប់(២០១២, ២០១៦ និង២០១៩)

| | | | | | | |
|---|---|---|---|---|---|---|
| **២០១៥** | ៣,០៥១,៨១២ | ៣,០២៥,៦៣០ | ៣.០៨៥ | ៩,៣៣៥,២៨៨ | ២,៩៧៥,៨០៩ | ៨,៦៩៩,៧០២ |
| **២០១៦** | ២,៩០៧,០៨៧ | ២,៣១៥,៧៩៨ | _ | ៦,៨៥៧,៨០៧ | _ | _ |
| **២០១៧** | ២,៩៨៩,៦៣១ | ២,៣៨២,៩២៩ | _ | ៧,១៨៨,៩០៦ | _ | _ |
| **២០១៨** | ៣,២០៩,៥៨៥ | ២,៨២០,៣៧៦ | _ | ៧,១៨៨,៩០៦ | _ | _ |

ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### ២.២.២ ស្ថានភាពនៃការនាំចេញផលិតកម្មដំណាំស្រូវ

ផលិតកម្មដំណាំស្រូវសម្រាប់ការនាំចេញនៅទីនេះ គឺសំដៅទៅលើការនាំចេញអង្ករ។ ការនាំចេញអង្ករផ្លូវការរបស់កម្ពុជាបានកើនឡើងគួរឱ្យកត់សម្គាល់ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះពី។ នៅឆ្នាំ២០១០ប្រទេសកម្ពុជាបាននាំចេញអង្ករត្រឹមតែ ១០៥,២៥៩លានតោនប៉ុណ្ណោះ រហូតមកដល់ឆ្នាំ២០១៣ បរិមាណនេះបានកើនឡើងដល់ប្រហែល ៣៧៨,៨៥៦លានតោន ជាមួយការបានផ្លាស់ប្តូរពីអ្នកជំនួញស្រូវសុទ្ធទៅជាអ្នកនាំចេញអង្ករវិញ។ ហើយមកដល់ឆ្នាំ២០១៦នេះបរិមាណនាំចេញបានកើនដល់៥៤២,១៩៨លានតោន និងធ្វើឱ្យកម្ពុជាក្លាយជាប្រទេសនាំចេញអង្ករធំជាងគេទី១២នៅទូទាំងពិភពលោក[12]។ ចំណែកនៅដំណាច់ឆ្នាំ២០១៨ការនាំចេញស្រូវមានការធ្លាក់ចុះមកត្រឹមតែ៦២៦,២២៥លានតោន ដោយសារតែកាលពីចុងឆ្នាំ២០១៧កន្លងទៅ កម្ពុជានាំចេញស្រូវទៅប្រទេសជិតខាងច្រើនពេក ធ្វើឱ្យរោងម៉ាស៊ីនក្នុងស្រុកមិនសូវសម្បូរស្រូវសម្រាប់ផលិតជាអង្ករដើម្បីនាំចេញ។ ទោះបីជាមើលឃើញបរិមាណនៃការនាំចេញធ្លាក់ចុះមែន ប៉ុន្តែបើនិយាយពីចំនួនទឹកប្រាក់បានពីការនាំចេញវិញ កើនឡើងវិញ ព្រោះតែការនាំចេញរបស់កម្ពុជា ភាគច្រើនជាអង្ករក្រអូបដែលមានតម្លៃថ្លៃ ហើយការនាំចេញអង្ករសបានធ្លាក់ចុះជំនួសវិញ។ ចំណែកឯការនាំចេញអង្ករ ក្នុងឆ្នាំ២០១៩គិតត្រឹមត្រីមាសដំបូងមានចំនួន ៣៦,៨០៩តោន។ ឆ្លើយតបនឹងការកើនឡើងនេះ គឺទន្ទឹមជាមួយពេលដែលសហភាពអឺរ៉ុបបានកំពុងដកប្រព័ន្ធអនុគ្រោះពន្ធEBA ពីកម្ពុជាផងដែរ ប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជាបានទទួលនូវកូតាថ្មី ដែលផ្តល់ដោយរាជរដ្ឋាភិបាលចិន និងអនុញ្ញាតឱ្យកម្ពុជានាំចូលអង្ករដោយរួចពន្ធទៅទីផ្សារចិនរហូតដល់៤០០,០០០តោន ក៏ដូចជាទីផ្សារ EU នៅ

[12] Chea Ponleu and Heng Sola, Overview of the Cambodian Rice Market-Challenges and the way forward [ទិដ្ឋភាពទូទៅនៃការប្រកួតប្រជែងទីផ្សារអង្ករកម្ពុជា និងបន្តទៅមុខ] (2018).

តែមានស្ថិរភាព ដោយសារតែអតិថិជននៅតែគាំទ្រអង្ករកម្ពុជា ទោះបីជាចំនួនអាចនឹងមិនកើនឡើងនៅពេលអនាគតក៏ដោយ។

វិស័យស្រូវអង្ករកម្ពុជាបានផ្លាស់ប្តូរបន្តិចម្តងៗ នូវគុណភាពផលិតកម្ម និងស្តង់ដាកែច្នៃដែលត្រូវបានទទួលស្គាល់ពីឈ្មួញអន្តរជាតិ។

ការផ្លាស់ប្តូរវិស័យស្រូវអង្ករត្រូវបានជំរុញដោយកត្តាមួយចំនួនរួមមានដូចខាងក្រោមៈ

១. ផ្តោតសំខាន់ទៅលើវិធីសាស្ត្រច្រើនជាងយុទ្ធសាស្ត្រសម្របសម្រួល និងការនាំចេញពោលគឺផ្តោតទៅលើវិធីសាស្ត្រអភិវឌ្ឍឧស្សាហកម្ម។

២. បានពង្រឹងសមត្ថភាពកិនស្រូវ និងបានកែលម្អតាមបែបទំនើបកម្ម

៣. គោលនយោបាយក្នុងស្រុកដែលជាច្រកឈានជើងចូលទីផ្សារអន្តរជាតិ

តារាងទី២ៈ បរិមាណអង្ករកម្ពុជាដែលបាននាំចេញទៅទីផ្សារអន្តរជាតិចន្លោះឆ្នាំ២០០៩-២០១៩

| ឆ្នាំ | បរិមាណនាំចេញ (គិតជាលានតោន) | កំណើន |
|---|---|---|
| ២០០៩ | ១២,៦១៣ | - |
| ២០១០ | ១០៥,២៥៩ | ៨៨% |
| ២០១១ | ២០១,៨៩៩ | ៤៨% |
| ២០១២ | ២០៥,៧១៧ | ២% |
| ២០១៣ | ៣៧៨,៨៥៦ | ៤៦% |
| ២០១៤ | ៣៨៧,០៦១ | ២% |
| ២០១៥ | ៥៣៨,៣៩៦ | ២៨% |
| ២០១៦ | ៥៤២,១៤៤ | ១% |
| ២០១៧ | ៥៦២,២៣៧ | 4% |
| ២០១៨ | ៤៩៧,២៤០ | -13% |
| ២០១៩ | ៣៦,៤០៩(គិតត្រឹមខែឧសភា ឆ្នាំ២០១៩) | - |

រូបភាពទី២ៈ បរិមាណអង្ករកម្ពុជាដែលបាននាំចេញទៅទីផ្សារអន្តរជាតិចន្លោះឆ្នាំ២០០៩-២០១៨



ប្រភព៖ លេខាធិការដ្ឋានច្រកចេញចូលតែមួយ សម្រាប់បំពេញបែបបទនាំចេញអង្ករ

**២.២.៣ ទីផ្សារគោលដៅ**

ការនាំចេញអង្ករទៅកាន់ប្រទេសចិនបានកើនឡើងជាបន្តបន្ទាប់ ជាពិសេសចាប់ពីឆ្នាំ២០១៥នៅពេលដែលអនុសារណៈយោគយល់ត្រូវបានចុះហត្ថលេខា រវាងរាជរដ្ឋាភិបាលកម្ពុជា និងប្រទេសចិនដើម្បីអនុញ្ញាតឱ្យមានកូតាអង្ករចំនួន ១០០,០០០តោនសម្រាប់ឆ្នាំ២០១៦ និង២០០,០០០តោនសម្រាប់ឆ្នាំ២០១៧។ បរិមាណនេះក៏បានកើនឡើងដល់៣០០,០០០តោន នៅក្នុងបរិមាណនាំចេញសរុបប្រហែល៦០ម៉ឺនតោន។ នៅក្នុងឆ្នាំ២០១៧ មានការនាំចេញអង្ករទៅកាន់ទីផ្សារគោលដៅចំនួន៥៦ប្រទេស ក្នុងនោះទិសដៅសំខាន់ៗចំនួន១០ប្រទេស មកពីប្រទេសក្នុងសមាជិកសហភាពអឺរ៉ុបចំនួន៨ប្រទេសសមាជិកអាស៊ាន១ប្រទេស និងទិសដៅផ្សេងទៀតចំនួន១ប្រទេស (មើលបន្ថែមក្នុងឧបសម្ព័ន្ធទី៤ និងទី៥)។[13]

ចំណែកឯក្នុងឆ្នាំ២០១៨វិញ ប្រទេសកម្ពុជាមានការនាំចេញអង្ករទៅកាន់ទិសដៅកើនឡើងដល់ចំនួន៦១ប្រទេស ក្នុងនោះទិសដៅសំខាន់ៗមានប្រទេសចិនឈរលំដាប់ទី១ បារាំងលំដាប់ទី២ ម៉ាឡេស៊ីលំដាប់ទី៣ ហ្គាបុងលំដាប់ទី៤ ណេដឺឡែនលំដាប់ទី៥ វៀតណាមលំដាប់ទី៦ ថៃលំដាប់ទី៧ ប៉ូឡូញលំដាប់ទី៨ បែលហ្សិកលំដាប់ទី៩ និងអង់គ្លេសលំដាប់ទី១០ ជាមួយក្រុមហ៊ុននាំចេញចំនួន៨៧ក្រុមហ៊ុន។[14]

[13] មជ្ឈមណ្ឌលពត៌មាន និងឯកសារកសិកម្ម, របាយការណ៍ស្តីពីស្ថានភាពនៃការបំពេញបែបបទនាំចេញអង្ករប្រចាំខែមិថុនាដើមឆ្នាំ២០១៧

[14]ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, របាយការណ៍ស្តីពីសភាពកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំឆ្នាំ២០១៨ និងទិសដៅអនុវត្តបន្ត (២០១៩), ទំព័រ២

តារាងទី៣៖ ទីផ្សារគោលដៅនាំចេញអង្ករកម្ពុជាសំខាន់ៗក្នុង២០១៨

| ល.រ | ទីផ្សារគោលដៅសំខាន់ៗ | បរិមាណនាំចេញ (គិតជាតោន) | បរិមាណនាំចេញ(គិតជាភាគរយ) |
|---|---|---|---|
| ១ | ប្រទេសចិន | ១៧០,១៥៤ | ៣៧% |
| ២ | ប្រទេសបារាំង | ៨៦,០៥០ | ១៨% |
| ៣ | ប្រទេសម៉ាឡេស៊ី | ៤០,៨៦១ | ៩% |
| ៤ | ប្រទេសហ្កាបុង | ៣៣,០៦០ | ៧% |
| ៥ | ប្រទេសណេដឺឡែន | ២៦,៧១៩ | ៦% |
| ៦ | ប្រទេសវៀតណាម | ២៦,៧១២ | ៦% |
| ៧ | ប្រទេសថៃ | ២៣,៨០៦ | ៥% |
| ៨ | ប្រទេសប៉ូឡូញ | ២៣,១៩២ | ៥% |
| ៩ | ប្រទេសប៊ែលហ្ស៊ិក | ១៩,១៧៧ | ៤% |
| ១០ | ប្រទេសអង់គ្លេស | ១៦,១៧៨ | ៣% |
| សរុប | | ៤៦៥,៩៥៩ | ១០០% |

រូបភាពទី៣៖ ទីផ្សារគោលដៅនាំចេញអង្ករកម្ពុជាសំខាន់ៗក្នុងឆ្នាំ២០១៨




ប្រភព៖ លេខាធិការដ្ឋានច្រកចេញចូលតែមួយ សម្រាប់បំពេញបែបបទនាំចេញអង្ករ

### ២.២.៤ តម្លៃការនាំចេញ

តម្លៃនៃការនាំចេញអង្ករបានកើនឡើងយ៉ាងខ្លាំងនៅចន្លោះឆ្នាំ២០១០ និង២០១៦។ នៅឆ្នាំ២០១០ប្រទេសកម្ពុជាទទួលបានប្រាក់ចំណូលប្រហែល៣៨លានដុល្លារ ពីការនាំចេញអង្ករទៅកាន់ទីផ្សារអន្តរជាតិ។

តម្លៃនេះបានកើនឡើងដល់៨ដងស្មើនឹង២៨៥លានដុល្លារនៅឆ្នាំ២០១៥ និង៣០០លានដុល្លារក្នុងឆ្នាំ២០១៦។ ចន្លោះពីឆ្នាំ២០១៥ដល់២០១៦ទោះបីជាបរិមាណនៃការនាំចេញអង្ករបានកើនឡើងត្រឹមតែ0.៧% ក៏ដោយក៏តម្លៃនាំចេញបានកើនឡើងប្រហែល៧%យ៉ាងគួរឱ្យកត់សម្គាល់ដែរ។[15]

តារាងទី៤៖ តម្លៃ និងកំណើននៃការនាំចេញអង្ករកម្ពុជាចន្លោះឆ្នាំ ២០១០-២០១៦

| ឆ្នាំ | តម្លៃនៃការនាំចេញ(គិតជាលានដុល្លា) | កំណើន |
|---|---|---|
| ២០១០ | ៣៨.៧៥ | 0% |
| ២០១១ | ១០៦.៣៧ | ២០៦% |
| ២០១២ | ១៣៩.៣៦ | ៣១% |
| ២០១៣ | ២៥១.៣៧ | ៨០% |
| ២០១៤ | ២៣១.៥៨ | -៨% |
| ២០១៥ | ២៨៥.៩១ | ២៣.១០% |
| ២០១៦ | ៣០៥.៨៩ | ៧.៤០% |

រូបភាពទី៤៖ តម្លៃនៃការនាំចេញអង្ករកម្ពុជាចន្លោះឆ្នាំ២០១០-២០១៦ (គិតជាលានដុល្លា)




ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

[15] Chea Ponleu and Heng Sola, Overview of the Cambodian Rice Market-Challenges and the way forward [ទិដ្ឋភាពទូទៅនៃការប្រកួតប្រជែងទីផ្សារអង្ករកម្ពុជា និងបន្តទៅមុខ] (2018).

## ២.៣ ស្ថានភាពនៃការវិនិយោគលើវិស័យស្រូវអង្ករនៅក្នុងសេដ្ឋកិច្ចកម្ពុជាចន្លោះឆ្នាំ២០០៨-២០១៨

ការវិនិយោគលើវិស័យស្រូវអង្ករមានច្រើនផ្នែកដូចជា ការវិនិយោគលើធាតុចូល ហិរញ្ញវត្ថុ កម្លាំងពលកម្ម ម៉ាស៊ីនកិនស្រូវ ឃ្លាំងស្តុក និងឡសម្ងួត។ល។ ប៉ុន្តែនៅក្នុងចំណោមការវិនិយោគលើទាំងនេះ យើងខ្ញុំសូមធ្វើការសិក្សាស្រាវជ្រាវតែលើការវិនិយោគលើម៉ាស៊ីនកិនស្រូវ ឃ្លាំងស្តុក និងឡសម្ងួតប៉ុណ្ណោះ ព្រោះជាការវិនិយោគដ៏លេចធ្លោមួយ ដើម្បីបម្រើឱ្យគោលនយោបាយនាំចេញអង្កររបស់រាជរដ្ឋាភិបាល ក៏ដូចជាទាក់ទាញអ្នកវិនិយោគឱ្យមានកំណើនកើនឡើង និងផ្តល់អត្ថប្រយោជន៍ជូនប្រជាជនបានជាច្រើនផ្នែក។

### ២.៣.១ ការវិនិយោគលើម៉ាស៊ីនកិនស្រូវ ឃ្លាំងស្តុក និងឡសម្ងួត

ខណៈមានការបង្ហាញពីគម្រោងសាងសង់ឃ្លាំង និងឡសម្ងួតស្រូវកាន់តែច្រើននៅកម្ពុជា អ្នកតំណាងនៅក្នុងឧស្សាហកម្មនេះ មានសុទិដ្ឋិនិយមថាកម្ពុជានឹងមិនជួបបញ្ហាប្រឈមដោយសារកង្វះខាត ឃ្លាំងស្តុក និងឡសម្ងួតច្រើនទេនៅឆ្នាំ២០១៩។ ជាមួយគ្នានេះការខិតខំអភិវឌ្ឍន៍សមត្ថភាពរបស់ក្រុមហ៊ុនរោងម៉ាស៊ីនកិនស្រូវនីមួយៗ រួមជាមួយការជួយគាំទ្រពីស្ថាប័នរដ្ឋផងនោះរដូវកាលប្រមូលផលឆ្នាំនេះនឹងមិនមានបញ្ហាដូច២-៣ឆ្នាំមុនទៀតទេ ខណៈបច្ចុប្បន្នមានឡសម្ងួត និងឃ្លាំងស្តុកស្រូវត្រូវបានដាក់ដំណើរការស្ទើរតែគ្រប់ខេត្តទូទាំងប្រទេស។ បច្ចុប្បន្ននៅកម្ពុជាមានរោងម៉ាស៊ីនកិនស្រូវសរុបជាង៣០០ ដែលជារោងម៉ាស៊ីនធំៗអាចមានសមត្ថភាពស្តុកដល់រាប់ម៉ឺនតោន។[16]

ចំពោះការផលិតអង្កររបស់ម៉ាស៊ីនកិនស្រូវវិញ គឺត្រូវចំណាយថ្លៃដើមចាប់ពី២១៨,០០០រៀល ទៅ ៣២៨,០០០រៀល ដើម្បីកិនឱ្យបានល្អក្នុងបរិមាណអង្ករ១តោន។ ចំណាយលើទ្រព្យមិនសកម្ម (៣០ទៅ៤០%) នៅតែជាខ្ទង់ចំណាយដែលខ្ពស់ជាងគេសម្រាប់រោងម៉ាស៊ីនកិនស្រូវ។ចំណាយលើទ្រព្យសកម្ម(ការរំលោះសម្ភារបរិក្ខារ) ថាមពល(អគ្គិសនី) និងហិរញ្ញវត្ថុនៅតែជាខ្ទង់ចំណាយធំៗជាងគេទាំង៣ សម្រាប់រោងម៉ាស៊ីនធំ ឬខ្ទង់ចំណាយធំរបស់រោងម៉ាស៊ីន គឺថ្លៃឈ្នួលពលកម្ម។[17]

[16] https://www.postkhmer.com, published May 28, 2019.
[17] សហព័ន្ធស្រូវអង្ករកម្ពុជា, ប្រតិបត្តិតាមដានវិស័យស្រូវ-អង្ករកម្ពុជា (២០១៨) ទំព័រ៥។

## ២.៣.២ ការគាំទ្រលើការវិនិយោគ ម៉ាស៊ីនកិនស្រូវ ឃ្លាំងស្តុក និងឡសម្ងួត

### ២.៣.២.១ ផែនការជំរុញផលិតកម្មរបស់រាជរដ្ឋាភិបាល[18]

នៅក្នុងឆ្នាំ២០១០ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញផែនការជំរុញផលិតកម្មស្រូវបន្ថែមទៀត និងគ្រោងនាំចេញអង្ករឱ្យបានចំនួន១លានតោនត្រឹមឆ្នាំ២០១៥ ដើម្បីជួយរួមចំណែករុញច្រានកំណើនសេដ្ឋកិច្ចរបស់ប្រទេសឱ្យបានចន្លោះពី៦% ទៅ ៧%តាំងពីឆ្នាំ២០១១មកម្ល៉េះ។

អ្នកស្រាវជ្រាវជាន់ខ្ពស់នៃវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា បានព្យាករណ៍ថាកម្ពុជានឹងទទួលបានកំណើនសេដ្ឋកិច្ចប្រមាណ៦,៥%នៅឆ្នាំក្រោយៗ ដោយមានការរួមចំណែកយ៉ាងសំខាន់ពីវិស័យកសិកម្មនេះ។ សក្តានុពលដ៏ទូលំទូលាយនៃវិស័យនេះអ្នកវិនិយោគទុនបរទេសនឹងចូលមកបណ្តាក់ទុនកាន់តែច្រើនថែមទៀតជាពិសេស គឺផ្នែករោងម៉ាស៊ីនកិនស្រូវធំៗនេះ។

### ២.៣.២.២ ការផ្តល់មូលនិធិ

**ពីរាជរដ្ឋាភិបាល៖** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងធនាគារអភិវឌ្ឍន៍ជនបទ ត្រូវបានប្រគល់ភារកិច្ចក្នុងការទទួលខុសត្រូវលើការផ្តល់ឥណទានពិសេសរបស់រាជរដ្ឋាភិបាល និងមូលនិធិបដិភាគរបស់ធនាគារអភិវឌ្ឍន៍ជនបទ ដើម្បីជួយដល់សមាគមន៍រោងម៉ាស៊ីនកិនស្រូវ ទីផ្សារស្រូវ ក្រុមហ៊ុននាំចេញអង្ករ សហាគមន៍កសិករ (ដែលមានផលិតកម្មកសិកម្មតាមកិច្ចសន្យា) ក្នុងគោលដៅដើម្បី៖

១) បង្កើនការផលិតក្នុងស្រុកប្រកបដោយបរិមាណ និងគុណភាព

២) ប្រមូលទិញស្រូវក្នុងអំឡុងពេលរដូវប្រមូលផល

៣) ការប្រកួតប្រជែង ទាំងតម្លៃ និងគុណភាព ជាពិសេស គឺកែប្រែពីការនាំស្រូវចេញ ទៅជាការនាំអង្ករចេញ

៤) បង្កើនតំលៃបន្ថែម និងបង្កើនការស្តុកទុកសម្រាប់សុវត្ថិភាពចំណីអាហារថ្នាក់ជាតិ។

ហិរញ្ញប្បទានរបស់រាជរាជរដ្ឋាភិបាលនេះត្រូវបានផ្តល់ឱ្យតាមរយៈមូលនិធិនេះដើម្បីអនុវត្តគម្រោងនាំចេញអង្កររបស់រាជរដ្ឋាភិបាលជាបន្តបន្ទាប់មាន៖

- ២លានដុល្លារអាមេរិក ដល់ ៤លានដុល្លារអាមេរិកនៅក្នុងឆ្នាំ២០០៦
- ៦លានដុល្លារអាមេរិកនៅក្នុងឆ្នាំ២០០៧
- ១៦លានដុល្លារអាមេរិកនៅក្នុងឆ្នាំ២០០៨

[18] https://khmer.voanews.com/a/cambodia-agriculture-boost, published December 10, 2010.

-១៨លានដុល្លារអាមេរិកនៅក្នុងឆ្នាំ២០១០

បច្ចុប្បន្ននេះទុនមូលនិធិទ្រទ្រង់ និងអភិវឌ្ឍន៍វិស័យកសិកម្ម គឺត្រូវបានបង្កើនដល់ចំនួន ៣៦លានដុល្លារអាមេរិក សម្រាប់ជួយគាំទ្រដល់វិស័យស្រូវអង្ករ និងអនុវិស័យមួយចំនួនទៀតមាន ដូចជាដំឡូងមី និងកៅស៊ូជាដើម។ ជាលទ្ធផលគម្រោងនេះគឺជាផ្នែកមួយក្នុងការជំរុញ វិស័យស្រូវអង្ករ ទៅក្នុងកម្រិតប្រកួតប្រជែងជាមួយប្រទេសជិតខាង និងនៅក្នុងទីផ្សារពិភពលោក។

**ពីធនាគារអភិវឌ្ឍន៍អាស៊ី(ADB)[19]៖** ប្រាក់កម្ចីពីADBមានរហូតដល់ទៅ ១,៧៥០,000ដុល្លារក្នុងរោងម៉ាស៊ីនមួយដោយយកកម្រៃការប្រាក់ទាបបំផុតគឺ៥%ក្នុង១ឆ្នាំ បានផ្តល់ឱ្យរោងម៉ាស៊ីនកិនស្រូវចំនួន២កន្លែងក្នុងខេត្តបាត់ដំបង ដែលជារោងម៉ាស៊ីនមានអាជ្ញាប័ណ្ណត្រឹមត្រូវក្នុងការនាំអង្ករចេញទៅបរទេស។ រាជរដ្ឋាភិបាលកម្ពុជាផ្តល់សិទ្ធិអាទិភាពឱ្យរោងម៉ាស៊ីនទាំងពីរនេះដើម្បីទទួលបានប្រាក់កម្ចីឥណទានពីADBដើម្បីយកទៅធ្វើឡសម្ងួត និងឃ្លាំងស្តុកស្រូវអង្ករ តាមរយៈគម្រោងជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករប្រចាំខេត្តបាត់ដំបង។ លោកឈឹម សាបុន នាយកគម្រោងជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករប្រចាំខេត្តដំបងបញ្ជាក់ថានេះជាឱកាសល្អមួយសម្រាប់ខេត្តបាត់ដំបង ដែលរាជរដ្ឋាភិបាលសហការជាមួយADB បានបង្កើតគម្រោងRICE-SDPនេះឡើង ដើម្បីលើកស្ទួយដល់ម្ចាស់រោងម៉ាស៊ីនកិនស្រូវអាចមានលទ្ធភាពធ្វើឡសម្ងួត និងឃ្លាំងស្តុកស្រូវអង្ករខ្នាតធំងាយស្រួលក្នុងការផលិត និងរក្សាទុកកសិផលឱ្យមានគុណភាពល្អសម្រាប់នាំចេញ។

### ២.៣.២.៣ វេទិការស្តីពីពាណិជ្ជកម្មស្រូវ

វេទិការPTP ត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៦ក្នុងពេលឈានដល់ការប្រមូលផលរដូវវស្សាដោយមានអង្គការFO ចំនួន៩៤បានចុះឈ្មោះជាអ្នកប្រើប្រព័ន្ធ ហើយមានអង្គការកសិករចំនួន៣២ បានបង្ហោះការប្រកាសស្តីពីការប្រមូលផលដែលបានព្យាករណ៍ និងសមត្ថភាពផ្គត់ផ្គង់ស្រូវរបស់អង្គភាពខ្លួន។ ជាទូទៅវេទិការស្តីពីពាណិជ្ជកម្មស្រូវ មានគោលបំណងកែលម្អទំនាក់ទំនងរវាងអង្គការកសិករ និងម្ចាស់រោងម៉ាស៊ីនកិនស្រូវ ដើម្បីបង្កើនបរិមាណ និងតម្លៃស្រូវអង្ករកម្ពុជាដែលបានលក់ទៅម្ចាស់រោងម៉ាស៊ីនកិនស្រូវក្នុងតំបន់។ វេទិការPTP ផ្តល់អត្ថប្រយោជន៍ចម្បងក្នុងការ ធ្វើឱ្យអង្គការFO និងម្ចាស់រោងម៉ាស៊ីនកិនស្រូវទាំងអស់ចូលរួមក្នុងប្រតិបត្តិការខ្សែរសង្វាក់តម្លៃ ស្រូវ។

[19] https://vayofm.com/news/detail/76936-712689484.html, March 14, 2017

ប្រសិទ្ធភាពថ្លៃចំណាយនេះបានធ្វើឱ្យសេដ្ឋកិច្ចដំណើរការល្អ និងផ្តល់ការលើកទឹកចិត្តទៅម្ចាស់រោងម៉ាស៊ីនកិនស្រូវក្នុងការចូលរួមក្នុងវេទិកា។

តារាងទី៥ ៖ ភ្នាក់ងារពាក់ព័ន្ធដែលចូលរួមក្នុងវេទិកាពាណិជ្ជកម្មស្រូវ

| ភ្នាក់ងារពាក់ព័ន្ធ | តួនាទី/មុខងារ | ការងារសំខាន់ |
|---|---|---|
| អង្គការកសិករចំនួន៩៤ (FO) | ការប្រមូល | រៀបចំផលិតកម្មស្រូវ និងការផ្គត់ផ្គង់ ប្រមូល/ បង្កើត និងផ្តល់ទិន្នន័យស្តីពីការរំពឹងទុកផ្គត់ផ្គង់ស្រូវ |
| សហព័ន្ធ FO ចំនួន៣ (FAEC, FCFD, FWN) | ជំនួយផ្នែកបច្ចេកទេស/អ្នកសម្របសម្រួល | ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ FO ដើម្បីធានាភាពត្រឹមត្រូវរបស់ទិន្នន័យ កែសម្រួល ផ្សព្វផ្សាយ និងតាមដានការប្រកាសលក់ស្រូវអង្ករជំនួសមុខឱ្យសមាជិករបស់ពួកគេ |
| ម្ចាស់រោងម៉ាស៊ីនកិនស្រូវ៨០/ក្រុមហ៊ុននាំចេញ | អ្នកទិញ | ផ្តល់តម្រូវការសម្រាប់ការរៀបចំប្រភព និងទិញស្រូវអង្ករនៅមូលដ្ឋានរបស់FO |
| ក្រុមប្រឹក្សាSCC RP | ជំនួយការផ្នែកបច្ចេកទេស | ជំនួយការផ្នែកបច្ចេកទេសទៅសហព័ន្ធFO, ការសម្របសម្រួលនៃការពិគ្រោះយោបល់របស់ភ្នាក់ងារការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ដំណើរការ |
| ក្រុមហ៊ុន Proact IT | សេវាកម្មឌីហ្សាញវិបសាយ | ការឌីហ្សាញ និងការបង្កើតវិបសាយ |

### ២.៣.២.៤ ការគាំទ្រសហព័ន្ធស្រូវអង្ករកម្ពុជា

គម្រោងឃ្លាំងសម្ងួត និងឃ្លាំងស្តុកស្រូវ គឺជាគម្រោងដ៏សំខាន់បំផុតសម្រាប់អនាគតវិស័យស្រូវអង្ករសម្រាប់យើងទាំងអស់គ្នា ដែលត្រូវការរៀបចំផែនការឱ្យច្បាស់លាស់ រវាងរាជរដ្ឋាភិបាលនិងវិស័យឯកជននៅក្នុងវិស័យស្រូវអង្ករ ដើម្បីជួយជំរុញ និងពង្រីកការទុកចិត្តនៅក្នុងទីផ្សារក្នុងស្រុកក៏ដូចជាទីផ្សារអន្តរជាតិ។ សហព័ន្ធស្រូវអង្ករកម្ពុជាបាននឹងកំពុងតែរៀបចំការងារនៅមូលដ្ឋានដើម្បីចូលរួមរៀបចំការងារ

ការចូលរួមរៀបចំដោះស្រាយការងារជាមួយភាគីសំខាន់ៗក្នុងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន។

## ២.៤ ការវិនិយោគដំណាំស្រូវ និងសេដ្ឋកិច្ចកម្ពុជា

### ២.៤.១ ដំណាំស្រូវក្នុងកំណើនសេដ្ឋកិច្ច[20]

ក្នុងវិស័យកសិកម្ម ដំណាំស្រូវពិតជាមានសារៈសំខាន់បំផុតក្នុងការចូលរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ព្រោះដំណាំស្រូវអាចផ្តល់នូវប្រភពស្បៀងអាហារ សម្រាប់ជីវភាពប្រចាំថ្ងៃរបស់មនុស្សគ្រប់រូប ជាប្រភពផ្គត់ផ្គង់វត្ថុធាតុដើមចម្បងសម្រាប់ការអភិវឌ្ឍកសិឧស្សាហកម្ម និងជាប្រភពចំណូលជាតិសំខាន់ ដែលទទួលបានពីការធ្វើផលិតកម្ម និងការនាំចេញស្រូវអង្ករទៅកាន់ទីផ្សារអន្តរជាតិ ។ នេះជាចំណុចគន្លឹះចម្បងបំផុតដែលអាចបញ្ជាក់ថា ដំណាំស្រូវមានតួនាទីក្នុងការជំរុញការរីកលូតលាស់ផ្នែកសេដ្ឋកិច្ចជាតិ ។

តម្រូវការស្រូវអង្ករសម្រាប់អាស៊ី មានការកើនឡើងយ៉ាងឆាប់រហ័ស ដោយការកើនឡើងនេះធ្វើឱ្យកើនឡើងនូវចំណីអាហារ និងការព្រួយបារម្ភចំពោះសុវត្ថិភាពស្បៀងដែលកំពុងបន្តកើតមាន។ ស្ថានភាពសេដ្ឋកិច្ចដែលប្រែប្រួល និងស្ថានភាពនៃការផ្គត់ផ្គង់អាចបង្កើនតម្រូវការដំណាំស្រូវ។ ដោយគិតគូរពីកត្តាទាំងអស់នេះ វិស័យកសិកម្មត្រូវបានព្យាករណ៍ថានឹងអនុវត្តល្អប្រសើរ។ ការនាំចេញផលិតផលកសិកម្ម ជាពិសេសការនាំចេញអង្ករត្រូវបានវាយតម្លៃថាមានការកើនឡើង ដោយសាររាជរដ្ឋាភិបាលបានផ្តល់អាទិភាពខ្ពស់ដល់វិស័យនេះ ។ កម្ពុជាទទួលបានចំណូលពីការនាំចេញអង្ករសរុបនៅក្នុងឆ្នាំ២០១៧កន្លងទៅ ប្រមាណជា៥០០លានដុល្លារសហរដ្ឋអាមេរិក ដោយក្នុងនោះការនាំចេញអង្ករក្រអូបរបស់កម្ពុជាមានបរិមាណច្រើនរហូតដល់ជាង៦៤% នៃការនាំចេញសរុប។ យោងតាមទិន្នន័យដែលចេញផ្សាយដោយសហព័ន្ធស្រូវអង្ករកម្ពុជាបានឱ្យដឹងថា អង្ករក្រអូបរបស់កម្ពុជាទទួលបានតម្លៃស្ថិតនៅក្នុងចន្លោះពី៧៥០ ដល់ ៨៤០ដុល្លារក្នុង១តោនសម្រាប់ប្រភេទអង្ករក្រអូប ខណៈអង្ករសធម្មតាមានតម្លៃប្រមាណ ៤៥០ដុល្លារក្នុងមួយតោន។

[20] រាជរដ្ឋាភិបាលកម្ពុជា, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៤-២០១៨), ទំព័រ១៤។

រាជរដ្ឋាភិបាលបានកំណត់គោលការណ៍កំណើនវិស័យកសិកម្មប្រចាំឆ្នាំចំនួន ៥% ដើម្បីធ្វើឱ្យវិស័យកសិកម្មកាន់តែមានទំហំធំល្មមឡើង ក៏ប៉ុន្តែមានផលិតភាពកាន់តែខ្ពស់ ដែលគោលដៅនេះត្រូវសម្រេចឱ្យបាននៅឆ្នាំ២០៣០។ យោងតាមការប៉ាន់ប្រមាណទុក កម្លាំងពលកម្មសរុបក្នុង វិស័យកសិកម្មនឹងត្រូវធ្លាក់ចុះ ខណៈដែលផលិតភាពនៃការប្រើប្រាស់ដីអាចនឹងមានកំណើនពី ១,៣០០ដុល្លារ រហូតដល់ ៣,៧០០ដុល្លារក្នុងមួយហិកតា ហើយផលិតភាពនៃកម្លាំងពលកម្មនឹងមានកំណើនពី ១,២០០ដុល្លារ រហូតដល់ ៣,៧០០ដុល្លារសម្រាប់កសិករម្នាក់។ ក្នុងកាលៈទេសៈនេះក៏ដោយ កម្ពុជានៅមានលទ្ធភាពពង្រីកកំណើនក្នុងការបង្កើនទិន្នផលស្រូវ និងកំណត់ពូជស្រូវដែលអំណោយផលដល់ការធ្វើពិពិធកម្មនៃការនាំចេញអង្ករពីកម្ពុជា។

**២.៤.២ ដំណាំស្រូវក្នុងលើកកម្ពស់ជីវភាពប្រជាជន**[21]

ដំណាំស្រូវមិនត្រឹមតែបានចូលរួមចំណែក ឱ្យមានកំណើនសេដ្ឋកិច្ចប៉ុណ្ណោះទេ គឺថែមទាំងបានចូលរួមចំណែកដ៏សំខាន់ក្នុងកិច្ចការសង្គម ក៏ដូចជាការចូលរួមចំណែកលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាផងដែរ ពោលគឺការវិនិយោគលើដំណាំស្រូវអាចដោះស្រាយបាននូវការងារធ្វើរបស់ប្រជាជនរហូតដល់ប្រមាណ ៤០% ក្នុងឆ្នាំ២០១៧ និងអាចចូលរួមចំណែកធំដល់ការកាត់បន្ថយភាពក្រីក្រតាមរយៈការធ្វើផលិតកម្មកសិកម្មលើដំណាំស្រូវនេះ ។

ក្នុងរយៈពេល៧ឆ្នាំ កម្ពុជាបានកាត់បន្ថយភាពក្រីក្របានជាងពាក់កណ្ដាល បើគិតត្រឹមឆ្នាំ២០១១ អត្រាភាពក្រីក្រនៅកម្ពុជា ស្មើនឹង២០,៥%។ ការកាត់បន្ថយភាពក្រីក្រមានល្បឿនល្មមពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៧ ប៉ុន្តែបន្ទាប់ពីពេលនោះមកភាពក្រីក្រត្រូវបានកាត់បន្ថយយ៉ាងលឿនពីកម្រិត ៥០,១%នៅឆ្នាំ២០០៧ មកត្រឹម២៣,៩% នៅឆ្នាំ២០០៩មក ល្បឿននៃការកាត់បន្ថយភាពក្រីក្រមានកម្រិតល្មមវិញ និង១៧,៧%ក្នុងឆ្នាំ២០១២។ ភាពក្រីក្រត្រូវបានកាត់បន្ថយគ្រប់តំបន់ទាំងអស់នៅទូទាំងប្រទេស ប៉ុន្តែបានកើតឡើងក្នុងពេលខុសៗគ្នា ដោយសារប្រជាពលរដ្ឋប្រមាណ៨០%រស់នៅទីជនបទ។ កម្មវិធីដែលត្រូវបានរៀបចំឡើងដើម្បីកាត់បន្ថយភាពក្រីក្រត្រូវបានផ្ដោតទៅលើប្រជាពលរដ្ឋរស់នៅទីជនបទ ដែលក្នុងនោះរួមមានសុខភាព អប់រំ ជាពិសេសកសិកម្មលើដំណាំស្រូវ។ គិតត្រឹមឆ្នាំ

[21] ធនាគារពិភពលោក, របាយការណ៍ប្រចាំប្រទេស (២០១៣), ទំព័រ៥៦។

២០១១ អត្រានៃភាពក្រីក្រនៅទីជនបទ មានអត្រាខ្ពស់ជាងតំបន់ដទៃទៀត។ នៅទីជនបទអត្រាភាពក្រីក្រមានកម្រិត២៣,៧% នៅភ្នំពេញ១,៥% និងនៅទីប្រជុំជនដទៃទៀត ១៦,១%ទោះបីអត្រានៅទីជនបទធៀបនឹងទីក្រុងបានធ្លាក់ចុះក្តី (ពី២៧,៦% ក្នុងឆ្នាំ២០០៤មក១៤,៩%ក្នុងឆ្នាំ២០១១) ចំនួនពលរដ្ឋក្រីក្រនៅទីជនបទនៅតែមានចំនួនច្រើននៅឡើយ។ ក្នុងចំណោមពលរដ្ឋក្រីក្រទូទាំងប្រទេស១០នាក់ មាន៩នាក់រស់នៅទីជនបទ ដោយសារប្រជាពលរដ្ឋរស់នៅទីក្រុងមានតែ២១,២%នៃប្រជាពលរដ្ឋសរុបប៉ុណ្ណោះ។ ចំណែកឯនៅទីជនបទមានប្រជាពលរដ្ឋ រហូតដល់ ៧៨,៨%ឯណោះ។

ចំណូលដែលបានមកពីផលិតផលកសិកម្មលើដំណាំស្រូវជាប្រភពដ៏សំខាន់មួយដែលបានបង្កើនចំណូលគ្រួសារនៅតាមទីជនបទ។ នេះដោយសារតែសកម្មភាពសេដ្ឋកិច្ច និងមុខរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋភាពច្រើន នៅតាមតំបន់ទីជនបទ គឺពឹងផ្អែកយ៉ាងខ្លាំងនៅលើការងារ កសិកម្ម។ តាមរយៈព័ត៌មានអង្កេតសេដ្ឋកិច្ច និងសង្គមកិច្ចកម្ពុជាបានបង្ហាញឱ្យឃើញថាចំណូលប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ដែលរស់នៅតាមទីជនបទពីកសិផលបានកើនឡើងទ្វេរដងក្នុងរយៈពេលប្រាំឆ្នាំ។ ការកើនឡើងពីចំណូលនៃកសិផលភាគច្រើនបានពីស្រូវអង្ករ។

កត្តា២សំខាន់ៗដែលចូលរួមក្នុងការកាត់បន្ថយភាពក្រីក្រនៅជនបទ ចន្លោះឆ្នាំ២០០៤-២០១១៖

កត្តាទី១ គឺតម្លៃអង្ករ

កត្តាទី២ គឺប្រាក់ឈ្នួលកសិកម្ម

រូបភាពទី៥៖ កត្តាដែលនាំឱ្យមានការកាត់បន្ថយភាពក្រីក្រឆ្នាំ២០០៤-២០១១




ប្រភព៖ ធនាគារពិភពលោក

# ជំពូកទី៣

# យន្តការនានាក្នុងការទាក់ទាញការវិនិយោគលើវិស័យស្រូវអង្ករនៅកម្ពុជា

## ៣.១ គោលនយោបាយលើកទឹកចិត្តរបស់រាជរដ្ឋាភិបាល

### ៣.១.១ ច្បាប់វិនិយោគ

អ្នកវិនិយោគត្រូវបានទទួលស្គាល់ និងចាត់ទុកដោយស្មើភាពគ្នាចំពោះមុខច្បាប់ដោយគ្មានការរើសអើងអំពីសញ្ជាតិ ឬពូជសាសន៍អ្វីទេ លើកលែងតែកម្មសិទ្ធលើដីធ្លីដូចមានចែងក្នុងច្បាប់ភូមិបាល។

រាជរដ្ឋាភិបាលលើកទឹកចិត្ត ដើម្បីជំរុញលើវិស័យសំខាន់ៗដូចជាៈ

- ការបង្កើតការងារ
- ការបង្កើនការនាំចេញ
- ការផលិតទំនិញកសិ-ឧស្សាហាកម្ម និងឧស្សាហាកម្មកែច្នៃ
- ការអភិវឌ្ឍន៍ជនបទជាដើម។

ចំពោះកម្មសិទ្ធិដីធ្លីរបស់អ្នកវិនិយោគ សម្រាប់បម្រើឱ្យគោលដៅនៃការអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវបានអនុញ្ញាត្តចំពោះ រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរ ដោយអាចប្រើប្រាស់ដីធ្លីតាមរយៈដីសម្បទាន ឬជួលរយៈពេលមិនកំណត់ដែលអាចបន្តសារជាថ្មីបាន ស្របតាមបទបញ្ញតិដូចមានចែងក្នុងច្បាប់ភូមិបាល។

ចំពោះវិវាទក្នុងការវិនិយោគ អ្នកវិនិយោគអាចជ្រើសរើសដោះស្រាយ ដោយអាចធ្វើការដោះស្រាយតាមរយៈក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬតាមរយៈតុលាការហើយភាគីអាចដោះស្រាយតាមនីតិវិធីអន្តរជាតិដោយស្របទៅតាមកិច្ចព្រមព្រៀង ដែលបានចុះជាមួយគ្នាមុនធ្វើការវិនិយោគ។

យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ការធ្វើជំនួញ ឬវិនិយោគអាចប្រព្រឹត្តទៅបានដោយសេរីនៅក្នុងការកំណត់របស់ច្បាប់។ ការប្រកបមុខរបរត្រូវមានសេរីភាពសេដ្ឋកិច្ច គឺតម្រូវឱ្យរដ្ឋគោរពសេរីភាពប្រកបមុខរបរអាជីវកម្មផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្ម គោរពសិទ្ធិទៅ លើមធ្យោបាយផលិតកម្ម។ សេរីភាពក្នុងការធ្វើជំនួញ គឺពលរដ្ឋមានសិទ្ធិលក់ដូរផលិតផលរបស់ខ្លួនដោយសេរី

រដ្ឋត្រូវតម្រូវឱ្យប្រជាពលរដ្ឋលក់ផលិតផលទៅឱ្យរដ្ឋ ដើម្បីឱ្យមានការកែចម្រើនលើថវិការជាតិ។ មិនតែប៉ុណ្ណោះរដ្ឋមិនអនុញ្ញាតឱ្យយកភោគផល ឬទ្រព្យសម្បត្តិឯកជនទៅប្រើប្រាស់ ទោះបីមួយរយៈពេលក៏ដោយត្រូវហាមឃាត់ លើកលែងតែមានករណីពិសេស ដូចជាមានគ្រោះអាសន្នជាដើម។

### ៣.១.២ ការលើកលែងពន្ធអាករ[22]

ក្នុងបរិការណ៍នៃការអភិវឌ្ឍវិស័យកសិកម្ម រាជរដ្ឋាភិបាលបានផ្តល់គោលនយោបាយអនុគ្រោះពន្ធចំពោះការនាំចូលសម្ភារកសិកម្ម និងបង្កើតយន្តការអន្តរក្រសួងតាមដានប្រព័ន្ធព័ត៌មានទីផ្សារសម្ភារកសិកម្ម ដើម្បីធានាឱ្យកសិករអាចទទួលបាននូវ ស្ថិរភាពចំណាយលើធាតុចូល និងការបន្ថយថ្លៃដើមឱ្យនៅជាអប្បបរមា ដែលបង្កលក្ខណៈងាយស្រួលក្នុងការប្រកួតប្រជែងទីផ្សារកសិផល។ បច្ចុប្បន្នការរីកចម្រើននៃវិស័យកសិកម្មកំពុងតែមានសន្ទុះឈានឡើងជារៀងរាល់ឆ្នាំ ទន្ទឹមនឹងសេចក្តីត្រូវការធាតុចូលសម្រាប់ប្រើប្រាស់ក្នុងវិស័យនេះកាន់តែកើនឡើង ដែលទាមទារឱ្យមានការគ្រប់គ្រងការធ្វើពាណិជ្ជកម្មជីកសិកម្ម ថ្នាំកសិកម្ម និងសម្ភារកសិកម្មផ្សេងទៀតប្រកបដោយប្រសិទ្ធភាព គុណភាព សុវត្ថិភាព និងតម្លាភាពដើម្បីផ្តល់ជូនទាំងអ្នកផលិត អាជីវករ និងអ្នកប្រើប្រាស់ទទួលបាននូវយុត្តិធម៌។ ទន្ទឹមគ្នានឹងកំណើនជាបន្តបន្ទាប់នៃផ្ទៃដីកសិកម្មតម្រូវការជីកសិកម្ម និងថ្នាំកសិកម្មក៏មានកំណើនគួរឱ្យកត់សម្គាល់។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដាក់ចេញនូវយន្តការលើកលែងពន្ធអាករលើតម្លៃបន្ថែមលើការ ផ្គត់ផ្គង់ផលិតផលកសិកម្មមិនទាន់កែច្នៃ ដើម្បីគាំទ្រដល់គោលនយោបាយនាំចេញអង្ករបស់រាជរដ្ឋាភិបាល និងសម្រាលបន្ទុកចំណាយរបស់ប្រជាជនក្នុងប្រើប្រាស់ផលិតផលមិនទាន់ កែច្នៃដោយត្រូវបានចាត់ទុកថាជាការផ្គត់ផ្គង់មិនជាប់ពន្ធអាករ។ ដូច្នេះទាក់ទងនឹងការនាំចេញ និងការទិញក្នុងស្រុកនូវសម្ភារ

---

[22] អនុក្រឹត្យលេខ៥៥ អនក្រ.បក, ៣០ មីនា ២០១៦ ស្តីពីការកែសម្រួល អនុក្រឹត្យលេខ១១៤ អនក្រ.បក ស្តីពីអាករលើតម្លៃបន្ថែម, ២៤ ធ្នូ ២០១៤។

ឬវត្ថុធាតុដើមសម្រាប់ការធ្វើកសិកម្មដាំដុះផលិតផលផលិតកម្មមិនទាន់កែច្នៃត្រូវបានលើកលែងពន្ធ។

**៣.១.៣ ការលើកទឹកចិត្តផ្នែកពន្ធដារ**[23]

ផលិតកសិកម្ម ឬកសិ-ឧស្សាហកម្ម ជាវិស័យអាទិភាពមួយចំណោមវិស័យដទៃទៀត ដែលត្រូវបានផ្តល់ការទឹកចិត្តផ្នែកពន្ធដារ ដោយសហគ្រាសធុនតូច និងមធ្យមអាចទទួលបានការលើកទឹកចិត្តដូចជា៖

(១) លើកលែងពន្ធលើប្រាក់ចំណូល៣ (បី) ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះបញ្ជីពន្ធដារសម្រាប់សហគ្រាសចុះបញ្ជីថ្មី
ឬចាប់ពីថ្ងៃដែលសហគ្រាសបានមកធ្វើបច្ចុប្បន្នកម្មសម្រាប់សហគ្រាសដែលបានចុះបញ្ជីរួច ហើយចាប់ពីពេលនេះអនុក្រឹត្យនេះចូលធរមាន ឬ

(២) លើកលែងពន្ធលើប្រាក់ចំណូលរយៈពេល៥ (ប្រាំ) ឆ្នាំ ដោយគិតចាប់ពីថ្ងៃដែលចុះបញ្ជីពន្ធដារសម្រាប់ហគ្រាសចុះបញ្ជីថ្មី
ពីថ្ងៃដែលសហគ្រាសបានមកធ្វើបច្ចុប្បន្នកម្មសម្រាប់សហគ្រាសដែលបានចុះបញ្ជីរួចហើយ
ចាប់ពីពេលនេះអនុក្រឹត្យនេះចូលធរមានដែលបំពេញលក្ខខណ្ឌណាមួយដូចខាងក្រោម៖
- ប្រើវត្ថុធាតុដើមក្នុងស្រុកចាប់ពី៦០% ឡើងទៅ ឬ
- បន្ថែមចំនួននិយោជិកបន្ថែមទៀត២០% ឬ
- មានទីតាំងក្នុងតំបន់ប្រមូលផ្តុំសហគ្រាសធុនតូច និងមធ្យម( SME Cluster)

(៣) លើកលែងការរបង់រំលោះពន្ធលើប្រាក់ចំណូលអប្បរមាក្នុងរយៈពេលលើកលែងពន្ធប្រាក់ចំណូល

(៤) លើកទឹកចិត្តចំណាយដែលអាចកាត់កងបាន ដូចខាងក្រោម ៖
- អនុញ្ញាត្តឱ្យកាត់កងចំណាយ២០០% ចំពោះចំណាយលើការប្រើប្រាស់បញ្ជើគណនេយ្យតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

[23] អនុក្រឹត្យស្តីពីការលើកចិត្តផ្នែកពន្ធដា សម្រាប់សហគ្រាសធុនតូច និងឯមធ្យមក្នុងវិស័យអាទិភាព, លេខ១២៤ អនុក្រ.បក, ០២ តុលា ២០១៨, មាត្រា៦។

-អនុញ្ញាត្តឱ្យកាត់កងចំណាយ២០០% ចំពោះចំណាយលើការបណ្តុះបណ្តាលលើការកាន់បញ្ជីគណនេយ្យ ឬបណ្តុះបណ្តាលជំនាញបច្ចេកទេសដល់និយោជិត

-អនុញ្ញាត្តឱ្យកាត់កងចំណាយ១៥០% ចំពោះវិនិយោគលើម៉ាស៊ីន ឬឧបករណ៍បច្ចេកវិទ្យាដែលមានលក្ខណៈនវានុវត្តន៍សម្រាប់បម្រើ និងលើកកម្ពស់ផលិតភាពផលិតកម្ម។

ក្នុងការទទួលបានការលើកទឹកចិត្តនេះ សហគ្រាសត្រូវកាន់បញ្ជីគណនេយ្យ និងលិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ទៅតាមកាលកំណត់ជូនរដ្ឋបាលសារពើពន្ធ ទោះបីជាត្រូវលើកលែងពន្ធលើប្រាក់ចំណូល និងដាក់លិខិតប្រកាសបង់ពន្ធអាករដទៃទៀតតាមច្បាប់ និងបទបញ្ញត្តិស្តីពីពន្ធដារជាធរមាន។ ផ្ទុយទៅវិញសហគ្រាសដែលមិនបានបំពេញលក្ខខណ្ឌដែលបានកំណត់ការលើកទឹកចិត្តជូននឹងត្រូវបានដកហូតមកវិញ។

### ៣.១.៤ គោលនយោបាយជំរុញការវិនិយោគ

រាជរដ្ឋាភិបាលបាន ដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រពីរគឺ

(១) បន្តជំរុញការអភិវឌ្ឍន៍វិស័យឯកជនឱ្យមានភាពរស់រវើកក្នុងតួនាទីជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច

(២) ប្រែក្លាយកម្ពុជាឱ្យទៅជាគោលដៅវិនិយោគប្រកបដោយភាពទាក់ទាញ និងប្រកួតប្រជែងក្នុងតំបន់ ជាពិសេសក្នុងក្របខ័ណ្ឌតំបន់សមាគមន៍អាស៊ាន(ASEAN)

ក្នុងនោះរាជរដ្ឋាភិបាលបានផ្តោតអាទិភាពលើ

- ការជំរុញលើកទឹកចិត្តការវិនិយោគជនបទ ដែលនឹងចូលរួមដល់ការអភិវឌ្ឍសេដ្ឋកិច្ចកាត់បន្ថយគម្លាតរវាងទីក្រុង និងជនបទ ក៏ដូចជាលើកស្ទួយជីវភាពប្រជាជន និងកាត់បន្ថយចំណាកស្រុកមកទីប្រជុំជន និងចំណាកស្រុករកការងារក្រៅប្រទេស
- ការបន្តពង្រឹងបរិស្ថានអនុគ្រោះសម្រាប់ការវិនិយោគ និងធុរកិច្ច តាមរយៈការបន្តកែលម្អការធ្វើវិចារណកម្មរបបលើកទឹកចិត្តសម្រាប់គម្រោងវិនិយោគ។ ការបន្តពង្រឹងក្របខ័ណ្ឌ

អភិបាលកិច្ច និងប្រសិទ្ធភាពនៅស្ថាប័នសាធារណៈ រួមទាំងការបន្តពង្រឹងយន្តការ **ច្រកចេញ-ចូលតែមួយ** នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

- ការបន្តកែលម្អកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការកែសម្រួលទម្រង់បែបបទ នីតិវិធី និងយន្តការនៃការដឹកជញ្ជូនឆ្លងដែន ការកាត់បន្ថយការចំណាយធុរកិច្ច រួមទាំងការពង្រឹង និងអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស
- ពង្រឹងសេវាថែទាំការវិនិយោគ ដើម្បីដោះស្រាយបញ្ហាប្រឈមរបស់វិនិយោគិនទាន់ពេលវេលា។

**ក្រុមប្រឹក្សាវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា** បានបង្កើត **"សេវាច្រកចេញចូលតែមួយ"** សម្រាប់វិនិយោគិនជាច្រើនឆ្នាំមកហើយ ដើម្បីកាត់បន្ថយបន្ទុកផ្នែករដ្ឋបាលនៅក្នុងសុំការ អនុម័ត ពីរាជរដ្ឋាភិបាលកម្ពុជាលើគម្រោងថ្មី។ **ក្រុមប្រឹក្សាវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា** និង**ក្រសួងពាណិជ្ជកម្ម** បន្តជំរុញឱ្យមានការវិនិយោគថ្មីៗ ក្នុងវិស័យសេដ្ឋកិច្ចអាទិភាពដើម្បីធ្វើពិពិធកម្ម និងពង្រីកមូលដ្ឋានសេដ្ឋកិច្ច ដើម្បីសក្តានុពលដលើវិនិយោគិនវិស័យឯកជន និងពង្រឹងការសម្របសម្រួលក្នុងចំណោមស្ថាប័នពាក់ព័ន្ធនានា របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការជំរុញការទទួលខុសត្រូវរួមគ្នា សម្រាប់លើកកម្ពស់ការប្រកួតប្រជែង របស់អាជីវកម្មក្នុងវិស័យ ឯកជន។

### ៣.១.៥ ការឧបត្ថម្ភធនរបស់រាជរដ្ឋាភិបាល

ដើម្បីចូលក្នុងការលើកកម្ពស់វិស័យស្រូវអង្ករនៅកម្ពុជា រាជរដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍ជនបទ បានបង្កើតយន្តការនៃការផ្តល់ឥណទានពិសេស៥០លានដុល្លាអាមេរិករបស់ ធនាគារអភិវឌ្ឍន៍ជនបទ និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីទប់ស្កាត់ការធ្លាក់ចុះនៃតម្លៃស្រូវដែលផ្តល់ជូនតាមរយៈធនាគារអភិវឌ្ឍន៍ជនបទក្នុងការទំលាក់កញ្ចប់ឥណទានពិសេស ដើម្បីសាងសង់ឃ្លាំងស្តុកផ្ទុកបានក្នុងបរិមាណចំនួន២សែនតោន និងឡសម្ងួតស្រូវចំនួន៣ពាន់តោនក្នុងមួយថ្ងៃ ស្ថិតក្នុងខេត្តបាត់ដំបង ដែលមានសមត្ថភាពស្រូបទាញស្រូវពីប្រជាកសិករនៅជុំវិញតំបន់បាន ដែលត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់កាលពីឆ្នាំ២០១៨ ក្រៅពីខេត្តបាត់ដំបង

ឃ្លាំងស្តុកស្រូវ៥ម៉ឺនតោន និងឡសម្ងួតស្រូវ១៥០០តោនក្នុងមួយថ្ងៃ នៅតំបន់៣ទៀតគឺ កំពង់ធំ ព្រៃវែង និងតាកែវ បានសាងសង់ផងដែរតាមរយៈកញ្ចប់ឥណទានពិសេសនេះ។ ក្នុងតំបន់ឃ្លាំងស្តុកស្រូវ និងឡសម្ងួត នៅតំបន់២គឺតាកែវ និងបានដាក់ឱ្យដំណើរការនៅដើមខែកក្កដា ២០១៨ឃ្លាំងស្តុកស្រូវ និង ឡសម្ងួតនៅតំបន់២គឺ តាកែវ និងកំពង់ធំ បានដាក់ឱ្យដំណើរការនៅ២០១៨រួចដែរហើយ។ វត្តមានឃ្លាំងស្តុកស្រូវ និងសម្ងួតស្រូវនៅតំបន់ដែលមានសក្តានុពលប្រមូលទិញស្រូវនេះ នឹងលើកស្ទួយថ្លៃស្រូវក៏ដូចជារួមចំណែកដល់ប្រជាកសិករផងដែរ។

ជាពិសេសជាងនេះទៅទៀតរាជរដ្ឋាភិបាលបានបង្កើតឥទានជាទុនបង្វិលកើនឡើងដល់៥០លានដុល្លានេះ មានកញ្ចប់ថវិការបស់រាជរដ្ឋាភិបាលចំនួន៤៣លានដុល្លា និងមូលនិធិផ្ទាល់របស់ធនាគារអភិវឌ្ឍន៍ជនបទចំនួន ៧លានដុល្លា ដើម្បីផ្តល់ឱ្យរោងម៉ាស៊ីនកិនស្រូវ ក្រុមហ៊ុនកែច្នៃ និងនាំចេញអង្ករ និងមជ្ឈមណ្ឌល ឬអ្នកប្រមូលទិញ ស្រូវដោយទំលាក់កម្ចីសម្រាប់ប្រមូលទិញស្រូវនៅរដូវប្រមូលផល។ យន្តការមានប្រសិទ្ធភាពក្នុងការធានាមិនឱ្យតម្លៃស្រូវធ្លាក់ចុះទាបជាងទីផ្សារ។ ជាក់ស្តែងរាជរដ្ឋាភិបាលបានធ្វើការឧបត្ថម្ភធនលើតម្លៃពូជស្រូវដល់ប្រជាកសិករ ដើម្បីកាត់បន្ថយថ្លៃដើមផលិតដោយឧបត្ថម្ភប្រមាណ១ពាន់រៀលក្នុងមួយគីឡូ បានន័យប្រសិនបើពូជស្រូវតម្លៃ៣ពាន់រៀលក្នុងមួយគីឡូ កសិករចេញតែ២ពាន់រៀលទេ ។

## ៣.២ ការកសាង និងលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធ

### ៣.២.១ ស្ថានភាពទូទៅនៃហេដ្ឋារចនាសម្ព័ន្ធ[24]

ហេដ្ឋារចនាសម្ព័ន្ធ បរិយាយអំពីទ្រព្យបង្កើតឡើងដែលអនុញ្ញាតឱ្យប្រទេសមួយដំណើរការ ដូចជាផ្លូវថ្នល់ ផ្លូវដែក កំពង់ផែ ព្រលានយន្តហោះ ប្រព័ន្ធគមនាគមន៍ អគ្គិសនី និងបណ្តាញចែកចាយទឹកស្អាត។ ខណៈពេលដែលសង្គ្រាមរាប់សិបឆ្នាំ និងភាពវិករដែលកើតឡើងនៅចុងទសវត្ស ឆ្នាំ២០០០ បាននាំមកនូវការខូចខាតសន្ធឹកសន្ធាប់ ដល់ហេដ្ឋារចនាសម្ព័ន្ធប្រទេសយ៉ាងណាមិញការស្តារឡើងវិញត្រូវបានធ្វើឡើងយ៉ាងឆាប់រហ័សនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។

[24] https://opendevelopmentcambodia.net/km/topics/infrastructure/, published November 28, 2015.

កម្ពុជាមានផ្លូវថ្នល់សរុបប្រវែង ៤៧,២៦៣គីឡូម៉ែត្រ ក្នុងនោះ៧៤%ជាផ្លូវខេត្តនៅទីជនបទ គិតមកត្រឹម ឆ្នាំ២០១៣ ផ្លូវជាតិនិងផ្លូវខេត្ត ប្រវែង១២,២៣៩គីឡូម៉ែត្រត្រូវបានត្រួសត្រាយ។ ប្រទេសកម្ពុជាមានផ្លូវទឹក ប្រមាណជា ១,៧៥០គីឡូម៉ែត្រ ក្នុងនោះ៨៥០គីឡូម៉ែត្រ អាចធ្វើចរាចរបាននៅក្នុងរដូវប្រាំង។ កំពង់ផែស្វយ័តក្រុងព្រះសីហនុ គឺជាផែអន្តរជាតិសមុទ្រទឹកជ្រៅ និងជាកំពង់ផែពាណិជ្ជកម្មតែមួយគត់របស់ប្រទេសកម្ពុជា។ កំពង់ផែនេះគ្របដណ្តប់នៅលើផ្ទៃដី ១២៥ ហិកតា។ អស់រយៈពេលប្រាំឆ្នាំពី២០១៤-២០១៨ ចំនួនកុងតឺន័រដែលផ្ទុកនៅកំពង់ផែនេះបានកើនឡើងជាមធ្យម ១១ %ក្នុងមួយឆ្នាំៗ។ កំពង់ផែស្វយ័តភ្នំពេញរបស់រដ្ឋ នៅស្រុកកៀនស្វាយនៃទឹកដីខេត្តកណ្តាល ដែលមានចម្ងាយ ៣០គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ គឺជាកំពង់ផែធំបង្អស់ទី២ របស់កម្ពុជា។ នៅខែមករា ឆ្នាំ២០១៣ កំពង់ផែ បានបើកឱ្យដំណើរការ ស្ថានីយកុងតឺន័រ តម្លៃ២៨លានដុល្លារអាមេរិក ក្រោមជំនួយថវិកាពីរាជរដ្ឋាភិបាលនៃប្រទេសចិន។ ផលិតផលកសិកម្ម(ជាពិសេសស្រូវអង្ករ) គឺជាទំនិញនាំចេញឆ្លងកាត់កំពង់ផែនេះ។ ក្នុងរយៈពេល៥ឆ្នាំ ចាប់ពីឆ្នាំ ២០១៣មក ចរាចរណ៍កុងតឺន័រឆ្លងកាត់កំពង់ផែភ្នំពេញបានកើនឡើងជាមធ្យម ១៤,៤%ក្នុងមួយឆ្នាំ។ នៅក្នុងដំណាក់កាលទី១ និងទី២ នៃការអភិវឌ្ឍ កំពង់ផែនេះបានបង្កើនសមត្ថភាពផ្ទុករបស់ខ្លួនបានរហូតដល់ ៣០០,០០០TEUs ក្នុងរយៈពេលមួយឆ្នាំ។ នៅដំណាក់កាលទី៣នៃការពង្រីកបន្ថែមនេះ មានគោលបំណងបង្កើនសមត្ថភាពផ្ទុកកុងតឺន័រឱ្យបានរហូតដល់ ៥០០,០០០TEUs ក្នុងមួយឆ្នាំ។ កំពង់ផែស្វួតភ្នំពេញ គឺជាកំពង់ផែទឹកទន្លេ ដែលមានចម្ងាយ ៣៣០គីឡូម៉ែត្រពីសមុទ្រ។ កប៉ាល់ផ្ទុកទំនិញនៅទីនេះ អាចបម្រើដល់គោលដៅអន្តរជាតិជាច្រើន ដូចជា ប្រទេសសិង្ហបុរី ជាដើម។

ភ្នំពេញ ដែលជារាជធានីនៃប្រទេសកម្ពុជា ប្រើប្រាស់ប្រមាណជា ៩០% នៃអគ្គិសនីទូទាំងប្រទេស។ ការពង្រីក បណ្តាញចែកចាយថាមពល ទៅដល់តំបន់ជនបទ ដែលជាលំនៅដ្ឋានរបស់ប្រជាជនប្រមាណជា ៨០% នៅមានកម្រិតនៅឡើយ គិតមកត្រឹមឆ្នាំ២០១៣ គ្រួសារកម្ពុជា ២២.៥% ប៉ុណ្ណោះ មានអគ្គិសនីប្រើប្រាស់ យ៉ាងណាមិញ នៅឆ្នាំ២០១៧ លំនៅដ្ឋាន៦៨% បានទទួលនូវអគ្គិសនីប្រើប្រាស់តាមរយៈទម្រង់ផ្សេងៗ។ នៅក្នុងឆ្នាំ២០១៤ សម្តេចនាយករដ្ឋមន្ត្រី បានប្រកាសការប្តេជ្ញាចិត្តធានាថា "នៅត្រឹមឆ្នាំ២០២០ គ្រប់ភូមិទាំងអស់នៅក្នុងប្រទេសកម្ពុជា នឹងមានអគ្គិសនីប្រើប្រាស់ ខណៈដែលគ្រួសារ ៧០%នឹងមានថាមពលនៅត្រឹមឆ្នាំ២០៣០"។ គម្រោងធំៗសម្រាប់ពង្រីកបណ្តាញចែកចាយ កំពុងចាប់ផ្តើមអនុវត្តដើម្បីសម្រេចគោលដៅរបស់ផែនការ

យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ សំដៅបង្កើនបណ្តាញបញ្ជូនថាមពលប្រវែងជាង ១២,៨០០គីឡូម៉ែត្រ ទៅនឹងបណ្តាញចែកចាយ នៅត្រឹមឆ្នាំ២០១៨។

### ៣.២.២ ហេដ្ឋារចនាសម្ព័ន្ធ និងវិស័យកសិកម្ម

ជាការពិតណាស់ហេដ្ឋារចនាសម្ព័ន្ធ គឺជាសសៃឈាមដ៏សំខាន់នៃរាល់ការអភិវឌ្ឍ សម្រាប់រាល់ដំណើរការលើគ្រប់វិស័យទាំងអស់ ជាក់ស្តែងនៅក្នុងការអភិវឌ្ឍវិស័យកសិកម្ម ហេដ្ឋារចនា- សម្ព័ន្ធដើរតួនាទីយ៉ាងសំខាន់ចំពោះ ការដឹកជញ្ជូនទាំងវត្ថុធាតុដើម និងទិន្នផល ក៏ដូចជាដំណើរការនៃការដាំដុះ និងផលិតកម្មផងដែរ។ ហេតុនេះហើយ ទើបនៅពេលប្រទេសមួយចង់លើកកម្ពស់នូវផលិតកម្មកសិកម្ម រាជ្ឋាភិបាល និងក្រសួងដែលពាក់ព័ន្ធ តែងយកចិត្តទុកដាក់ ក្នុងការកសាង និងលើកកម្ពស់ ទៅលើហេដ្ឋារចនាសម្ព័ន្ធឱ្យមានភាពល្អប្រសើរ។

ដើម្បីលើកកម្ពស់ដល់ផលិតកម្មកសិកម្មរាជរដ្ឋាភិបាលកម្ពុជាបាន និងបន្តយកចិត្តទុកដាក់នៅក្នុងការកសាង និងលើកកម្ពស់ការកសាងនូវហេដ្ឋារចនាសម្ព័ន្ធនានាដូចជា ផ្លូវថ្នល់ ស្ពាន និងប្រព័ន្ធធារាសាស្ត្រជាដើម តាមរយៈការសហការណ៍ជាមួយដៃគូអភិវឌ្ឍនានា និងជំនួយឧបត្ថម្ភពីបរទេស អង្គការ និងធនាគារអន្តរជាតិនានា ពីព្រោះនេះជាកត្តាដ៏សំខាន់ក្នុងការលើកម្ពស់វិស័យកសិកម្ម និងជំរុញដល់ការវិនិយោគទៅលើវិស័យនេះផងដែរ ។

ការជំរុញ និងស្តារហេដ្ឋារចនាសម្ព័ន្ធ ត្រូវបានដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍកសិកម្មដែលជាសកម្មភាពអាទិភាពមួយ ដើម្បីបម្រើការងារពិសោធន៍ស្រាវជ្រាវ អភិវឌ្ឍ និងផ្ទេរបច្ចេកវិទ្យាទំនើបសមស្របលើមុខជំនាញពាក់ព័ន្ធនឹងផលិតកម្មដំណាំ ជាពិសេសគឺដំណាំស្រូវ ដើម្បីឆ្ពោះទៅសម្រេចបានបណ្តើរៗ នូវគោលដៅនៃគោលនយោបាយស្តីពីការជំរុញផលិតកម្មដំណាំស្រូវ និងការនាំចេញអង្ករ ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជា។

#### ៣.២.២.១ ការកសាង និងស្តារហេដ្ឋារនាសម្ព័ន្ធក្នុងគោលនយោបាយនាំចេញអង្ករ

ក្រសួងសាធារការដឹកជញ្ជូន និងក្រសួង-ស្ថាប័នពាក់ព័ន្ធ បានរៀបចំផែនការសកម្មភាព វិនិយោគអភិវឌ្ឍន៍លើហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ដើម្បីកាត់បន្ថយថ្លៃនាំចេញ

ដែលបណ្តាលមកពីហេដ្ឋារចនាសម្ព័ន្ធ ការដឹកជញ្ជូន កន្លែងលើកដាក់ទំនិញ ឃ្លាំងផ្ទុកទំនិញ ប្រតិបត្តិការកំពង់ផែ និងសេវាដទៃទៀត ដោយពិនិត្យមើលលទ្ធភាព លើហេដ្ឋារចនាសម្ព័ន្ធការដឹកជញ្ជូន និងការលើកដាក់ទំនិញ។

ការដឹកអង្ករ និងទំនិញតាមផ្លូវដែក មានថ្លៃថោក និងអាចកាត់បន្ថយចំណាយក្រៅផ្លូវការ ព្រមទាំងចំណេញពេលវេលា។ ក្រសួងសាធារណការ និងដឹកជញ្ជូន ជាពិសេសតាមរយៈគណៈកម្មាធិការគ្រប់គ្រងសម្បទានរាជាយស្ម័យយានកម្ពុជា បានបន្តជំរុញស្តារផ្លូវដែក និងប្រតិបត្តិការដឹកជញ្ជូនតាមផ្លូវដែកឱ្យបានលឿន (បាត់ដំបង-ភ្នំពេញ និង ភ្នំពេញ-ព្រះសីហនុ) និងអភិវឌ្ឍន៍ ផ្លូវដែក ព្រមទាំងសហការជាមួយក្រុមហ៊ុនសម្បទានិក ដើម្បីចាប់ផ្តើមការដឹកជញ្ជូនតាមផ្លូវដែកឱ្យបានឆាប់រហ័ស។

### ៣.២.២.២ ផែនការគ្រប់គ្រងទឹកក្នុងវិស័យកសិកម្ម[25]

ការគ្រប់គ្រងទឹកក្នុងវិស័យកសិកម្ម(AWM) ជាពិសេស គឺប្រព័ន្ធធារាសាស្ត្រត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជាដែលជាកត្តាអាទិភាពក្នុងការកាត់ភាពក្រីក្រ និងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច។ ការវិនិយោគលើAWM នៅកម្ពុជាមានភាពចាំបាច់ក្នុងការឆ្ពោះទៅរកការសម្រេចបាននូវគោលនយោបាយបង្កើនការនាំចេញអង្ករ និងលើកកម្ពស់សន្តិសុខស្បៀង និងកាត់បន្ថយភាពក្រីក្រនៅកម្រិតមូលដ្ឋាន។ គោលដៅនៅក្នុងគម្រោងនេះគឺ ផ្តោតលើការបង្កើនការស្រោចស្រពនៅរដូវប្រាំង និងការធ្វើពាណិជ្ជកម្មកសិកម្ម។ យុទ្ធសាស្ត្រជាតិកសិកម្ម និងទឹក (SAW) កំណត់នូវការវិនិយោគលើប្រព័ន្ធធារាសាស្ត្រជាចម្បងក្នុងការអភិវឌ្ឍ និងការស្តារហេដ្ឋារចនាសម្ព័ន្ធទ្រង់ទ្រាយធំនៅថ្នាក់ជាតិ។ ក្នុងឆ្នាំ ២០១២ MOWRAM បានចុះបញ្ជីជាង ២៦០ លានដុល្លារក្នុងការវិនិយោគដែលបានគ្រោងទុកនៅក្នុងទំរង់នៃកម្ចី និងជំនួយឥតសំណងសម្រាប់ការវិនិយោគប្រព័ន្ធធារាសាស្ត្រ។ លើសពីនេះទៀតផែនការឃុំសង្កាត់តាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ កំណត់អាទិភាព AWM នៅថ្នាក់ឃុំទោះបីជាប្រភពនៃការផ្តល់មូលនិធិ សម្រាប់គំនិតផ្តួចផ្តើមក្នុងតំបន់បែបនេះនៅមានកម្រិតក៏ដោយ។

[25]Robyn Johnston និង Thuon Try និង Sanjiv de Silva, AWM in Cambodia [ផែនការគ្រប់គ្រងធនធានទឹកនៅកម្ពុជា], (June 2013), 3.

#### ៣.២.២.៣ ការពង្រឹងមធ្យោបាយដឹកជញ្ជូន

កាលពីចុងឆ្នាំ២០១៦ ក្នុងឱកាសសន្និបាតបូកសរុបការងារប្រចាំឆ្នាំ សហព័ន្ធស្រូវអង្ករបានលើកឡើងសំណូមពរមួយចំនួនដើម្បី ដោះស្រាយពីបញ្ហាកង្វល់ផ្សេងទាក់ទងនឹងបញ្ហាវិស័យ ដឹកជញ្ជូន ដើម្បីសម្រួលការដឹកជញ្ជូន ការធ្វើពាណិជ្ជកម្មឱ្យកាន់តែប្រសើរឡើងទៅកាន់រាជរដ្ឋាភិបាល និងក្រសួងសាធារណការនិងដឹកជញ្ជូនទាក់ទងនឹង៖

- ការពង្រីកមធ្យោបាយដឹកជញ្ជូនឱ្យសម្បូរបែប ខណៈពេលដែលបច្ចុប្បន្ន ការដឹកជញ្ជូនពឹងផ្អែកខ្លាំងបំផុតលើផ្លូវថ្នល់ ខណៈដែលផ្លូវដែក និងផ្លូវទឹកសុទ្ធតែជាសក្តានុពលខ្លាំង សម្រាប់ការដឹកជញ្ជូនផលិតផល តែកម្ពុជាមិនទាន់ប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនៅឡើយ។ ការបង្កើតមធ្យោបាយដឹកជញ្ជូនច្រើនអាចធ្វើឱ្យតម្លៃមានការប្រកួតប្រជែង និងផ្តល់ជម្រើសកាន់តែច្រើនដល់អ្នកប្រើប្រាស់សេវាដឹកជញ្ជូន
- ពង្រីកមធ្យោបាយដឹកជញ្ជូនតាមផ្លូវគោកបន្ថែមទៀត ពិសេសផ្លូវជាតិលេខ១ លេខ៥ ជាច្រើនដើម្បីឱ្យការដឹកជញ្ជូនបានឆាប់រហ័ស និងចំណេញពេលវេលា
- ពង្រីកមធ្យោបាយដឹកជញ្ជូនតាមខេត្ត ជាពិសេសការដឹកជញ្ជូន តាមផ្លូវស្រែរបស់បងប្អូនកសិករ ឬរោងម៉ាស៊ីន ដើម្បីសម្រួលថ្លៃដើម
- អន្តរាគមន៍ជាប្រព័ន្ធ ឬបមន្តណាមួយជួយបញ្ចុះតម្លៃ forwarding fee ដែលតាមសិក្សារបស់អង្គការ JICA រកឃើញថាមានតម្លៃខ្ពស់ជាងប្រទេសជិតខាង។

## ៣.៣ ទីផ្សារនាំចេញសម្រាប់វិស័យស្រូវអង្ករ

### ៣.៣.១ ចក្ខុវិស័យ និងយុទ្ធសាស្ត្រជំរុញការនាំចេញអង្ករ

ចក្ខុវិស័យរបស់រាជរដ្ឋាភិបាល គឺចង់ឱ្យកម្ពុជាក្លាយជាជង្រុកស្រូវ និងជាប្រទេសនាំចេញអង្ករសំខាន់មួយនៅលើទីផ្សារពិភពលោក។ ក្នុងន័យនេះរាជរដ្ឋាភិបាលបានកំណត់យកឆ្នាំ២០១៥ ជាឆ្នាំគោលដើម្បី៖

១. ជំរុញការផលិតស្រូវលើសឱ្យបានច្រើនជាង៤លានតោន ក្នុងនោះបរិមាណអង្ករសម្រាប់នាំចេញត្រូវសម្រេចឱ្យបានយ៉ាងតិច១លានតោន

២. ធ្វើឱ្យអង្ករកម្ពុជាត្រូវបានគេទទួលស្គាល់ជាអន្តរជាតិ។ ក្នុងការអនុវត្តគំនិតផ្តួចផ្តើមនេះ រាជរដ្ឋាភិបាលនឹងគោរពប្រតិបត្តិគោលការណ៍សំខាន់ៗ ដើម្បីធានាផលប្រយោជន៍របស់កសិករ

តាមរយៈការបង្កើនប្រាក់ចំណូល និងកាត់បន្ថយភាពក្រីក្ររបស់ពួកគេ ការរក្សាបាននូវសន្តិសុខស្បៀង ដោយប្រើប្រាស់យន្តការសុវត្ថិភាពសង្គមមួយរឹងមាំ និងការរួមវិភាគកំណើនសេដ្ឋកិច្ចជាតិតាមរយៈការបង្កើនតម្លៃបន្ថែមពីការនាំចេញអង្ករ។ គោលការណ៍ទាំងនោះមានៈ

- ប្រកាន់យកគោលការណ៍ទីផ្សារដោយរក្សាការប្រកួតប្រជែងក្នុងគោលដៅជំរុញការនាំចេញអោយមានប្រសិទ្ធភាពខ្ពស់ផង ធានាផលប្រយោជន៍របស់កសិករតាមរយៈការបង្កើនប្រាក់ចំណូល និងការកាត់បន្ថយភាពក្រីក្ររបស់ពួកគាត់ផង និងរក្សាបាននូវសន្តិសុខស្បៀង
- លើកកម្ពស់ប្រសិទ្ធភាព ក្នុងការសម្របសម្រួលរវាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដើម្បីសម្រួលដល់ដំណើរការនាំចេញដោយផ្តល់ និងសម្រួលការផ្តល់សេវាសាធារណៈគ្រប់ប្រភេទរួមមាន ការផ្តល់អាជ្ញាប័ណ្ណនាំចេញ និងវិញ្ញាបនប័ត្របញ្ជាក់គុណភាពផ្សេងៗដែលតម្រូវដោយប្រទេសនាំចូល ការសម្រួលការដឹកជញ្ជូន និងការផ្តល់ព័ត៌មានទីផ្សារទាន់ពេលវេលា សំដៅកាត់បន្ថយសោហ៊ុយចំណាយសម្រាប់ការនាំចេញ និងការពង្រឹងភាពប្រកួតប្រជែងអង្ករកម្ពុជាឱ្យបានជាអតិបរមា
- ជំរុញកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍សង្គមស៊ីវិល ព្រមទាំងវិស័យឯកជនដូចជាផលិតករស្រូវ-អាជីវករម៉ាស៊ីនកិនស្រូវពាណិជ្ជករ និងអ្នកដឹកជញ្ជូនក្នុងការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ និងការចរចាស្វែងរកទីផ្សារក្រៅប្រទេស ក៏ដូចជាការពង្រឹងស្ថាប័នផ្តល់ព័ត៌មានទីផ្សារ និងពាណិជ្ជកម្មអង្ករ
- លើកទឹកចិត្ត និងគាំទ្រការចូលរួមពីសំណាក់កសិករ និងសហគមន៍កសិករ ដើម្បីការពារផលប្រយោជន៍របស់ពួកគេ តាមរយៈការបង្កើនផលិតកម្ម និងការផ្គត់ផ្គង់ស្រូវប្រកបដោយគុណភាព ក៏ដូចជាការលើកស្ទួយអំណាចចរចាថ្លៃដោយទទួលបានព័ត៌មានទីផ្សារ ការបណ្តុះបណ្តាលបច្ចេកទេសដាំដុះ និងឥណទានសមស្រប
- ជំរុញការលើកទឹកចិត្តដល់ការបង្កើនសមត្ថភាពនាំចេញអង្ករពីកម្ពុជាដោយខ្លួនឯង ដោយបើកចំហដល់ក្រុមហ៊ុនសាជីវកម្មទាំងអស់ដែលបើកស្នាក់ការប្រមូលទិញ និងកែច្នៃស្រូវនៅក្នុងប្រទេសឱ្យធ្វើការនាំចេញអង្ករស្របច្បាប់ ប្រកួតប្រជែងដោយសុច្ចរិត

យុត្តិធម៌ និងស្មោះត្រង់ ដោយគោរពបាននូវកាតព្វកិច្ចបង់ពន្ធ និងទទួលបានការលើកទឹកចិត្តតាមការកំណត់នៃច្បាប់របស់កម្ពុជាជាធរមាន។

### ៣.៣.២ ផលិតកម្មពូជស្រូវស្រាលសំខាន់ៗសម្រាប់ការនាំចេញអង្ករ

រាជរដ្ឋាភិបាលបានបញ្ចេញពូជស្រូវសំខាន់ៗ ចំនួន១០ពូជរួមទាំងបង្គុំបច្ចេកទេសផលិតកម្មដំណាំស្រូវសម្រាប់បង្កើនផលិតកម្មដំណាំស្រូវ និងគុណភាពឆ្លើយតបនឹងតម្រូវការទីផ្សារ។ ពូជស្រូវសំខាន់ៗចំនួន១០នេះជាប្រភេទពូជមានទិន្នផល និងគុណភាពអង្ករខ្ពស់ រួមមានៈ ពូជស្រូវស្រាលមិនប្រកាន់រដូវចំនួន៣ពូជ គឺពូជសែនពិដោរ ពូជអ៊ីអ៊ែរ៦៦ និងពូជជលសារ ពូជស្រូវ កណ្តាលប្រកាន់រដូវចំនួន៤ពូជ គឺពូជផ្ការំដួល ពូជផ្ការំដេង ពូជផ្ការមៀត និងពូជផ្ការច័ន្ទសែនសរ និងពូជស្រូវស្រាលធ្ងន់ប្រកាន់រដូវមានចំនួន៣ពូជ គឺពូជរាំងជ័យ ពូជខា៤ និងពូជខា៦។ លក្ខណៈរបស់ពូជស្រូវស្រាលមិនប្រកាន់រដូវ ចំណេះដឹងបច្ចេកទេស និងបទពិសោធន៍សំខាន់ៗពីបង្គុំបច្ចេកទេសប្រពលវប្បកម្មដំណាំស្រូវ និងគុណភាពអង្ករឆ្លើយតបទៅនឹងតម្រូវការទីផ្សារដើម្បីទទួលបានទិន្នផលស្រូវខ្ពស់ គុណភាពស្រូវ និងអង្ករល្អ។

ជារួមការអនុវត្តតាមបង្គុំបច្ចេកទេស កសិករនឹងទទួលបានទិន្នផលខ្ពស់គុណភាពគ្រាប់ស្រូវ និងអង្ករល្អ ងាយស្រួលលក់ លក់បានតម្លៃខ្ពស់ និងប្រសិទ្ធភាពក្នុងការទទួលទាន ជាហេតុធ្វើឱ្យប្រជាកសិករមានប្រាក់ចំណូល ជីវភាពរស់នៅល្អប្រសើរ និងចូលរួមចំណែកក្នុងការអនុវត្តគោលនយោបាយស្តីពី ផលិតកម្មស្រូវ និងការនាំចេញអង្កររបស់រាជរដ្ឋាភិបាលកម្ពុជាថែមទៀត។

### ៣.៣.៣ ស្តង់ដារអង្ករសម្រាប់អង្ករស និងអង្ករក្រអូប

បទដ្ឋានទាំងនេះ បានប្រកាសឱ្យប្រើដោយព្រះរាជក្រឹត្យបានបង្កើតការធានាគុណភាពដែលនាំឱ្យមានការទទួលស្គាល់ជាអន្តរជាតិ និងទំនុកចិត្តពីអ្នកទិញសកលលោក។ ជាលទ្ធផលការកំណត់ពីអត្តសញ្ញាណDNAត្រូវបានបង្កើតឡើងសម្រាប់ពូជស្រូវក្រអូបកម្ពុជា ហើយបច្ចុប្បន្នកសិករកាន់តែច្រើនអាចទទួលបានគ្រាប់ពូជតម្លៃខ្ពស់ និងវគ្គបណ្តុះបណ្តាលដែលពាក់ព័ន្ធ។ បច្ចេកទេសធ្វើកសិកម្មប្រសើរ និងដំណើរការកិនស្រូវកំពុងបង្កើនទិន្នផលឧស្សាហកម្ម និងប្រាក់ចំណូល

ឧស្សាហកម្មអង្ករបស់កម្ពុជាស្របតាមកេរ្តិ៍ឈ្មោះរបស់ខ្លួនសម្រាប់ផលិតអង្ករក្រអូប។ លទ្ធផលនេះគឺគួរអោយចាប់អារម្មណ៍ណាស់សម្រាប់កម្ពុជា បានឈ្នះពានរង្វាន់អង្ករល្អបំផុតរបស់ពិភពលោកកាលពីបីឆ្នាំមុន(២០១០) ក្នុងសន្និបាតស្រូវអង្ករប្រចាំឆ្នាំ។ ក្នុងឆ្នាំ២០១៣កន្លងមកកម្ពុជា កំពុងស្វែងរកការយកចិត្តទុកដាក់លើការរីកចម្រើនទាំងនេះនៅលើទីផ្សារអន្តរជាតិ។

**៣.៣.៤ ការចូលរួមពី អង្គការសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងទីភ្នាក់ងារអភិវឌ្ឍន៍បារាំងក្នុងការនាំចេញ**

ដើម្បីចូលរួមគាំទ្រដល់រោងម៉ាស៊ីនកិនស្រូវ និងអ្នកនាំចេញអង្ករកម្ពុជាក្នុងការចូលទៅកាន់ទីផ្សារអន្តរជាតិ IFC និង AFD/SNEC បានធ្វើការស្ទង់មតិពីប្រទេសចំនួន៦ ដែលត្រូវបានកំណត់ថាជាទីផ្សារនាំចេញខ្ពស់សម្រាប់អង្ករក្រអូបខ្ពស់ដូចជា ប្រទេសចិនហុងកុង ប្រទេសកូតឌីវ័រ ប្រទេសបារាំង ប្រទេសអាល្លឺម៉ង់ (ជាលក្ខណៈបុគ្គល និងជាផ្នែកមួយនៃទីផ្សារសហភាពអឺរ៉ុប) សិង្ហបុរី និងសហរដ្ឋអាមេរិក។ ប្រទេសនេះមានភាពខុសប្លែកគ្នាយ៉ាងខ្លាំងក្នុងទំហំទីផ្សារ និងភាពយូរឆ្នាំសម្រាប់អតិថិជន និងចំណង់ចំណូលចិត្តស្តង់ដា នីតិវិធីនិងកូតាឬការដាក់កម្រិត/កិច្ចព្រមព្រៀងពាណិជ្ជកម្មផ្សេងទៀត។ ដូច្នេះយុទ្ធសាស្ត្រដែលអ្នកនាំអង្ករចេញរបស់ប្រទេសកម្ពុជានឹងត្រូវអនុវត្តក៏នឹងផ្លាស់ប្តូរ ហើយគួរតែជំរុញឱ្យវិស័យនេះអនុវត្តនូវសមត្ថភាព និងការបង្កើនគុណភាព នៅតាមដំណាក់កាលផ្សេងៗគ្នាតាមខ្សែសង្វាក់ផ្គត់ផ្គង់។ ការរីកចម្រើនទាំងនេះនឹងមានផលវិជ្ជមានបន្ថែមទៀតនៅក្នុងវិស័យនេះនិងលើសេដ្ឋកិច្ចកម្ពុជាទាំងមូល។

**៣.៤ វិស័យហិរញ្ញវត្ថុ**

**៣.៤.១ វិស័យហិរញ្ញវត្ថុលើដំណាំស្រូវនៅកម្ពុជា**

វិស័យហិរញ្ញវត្ថុនៅកម្ពុជាគ្របដណ្តប់ដោយវិស័យធនាគារ ដែលក្នុងនោះទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ។ នៅក្នុងឆ្នាំ២០១៥ ឥណទានរបស់គ្រឹះស្ថានធនាគារ

និងមីក្រូហិរញ្ញវត្ថុសរុបបានកើនឡើងជាលំដាប់ដល់ ១៤.៧ពាន់លានដុល្លារអាមេរិក ឥណទាននេះត្រូវបានបែងចែកដល់វិស័យជាច្រើននៅក្នុងសេដ្ឋកិច្ច។ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ទទួលបាន១០.១៩% ជាតម្លៃធំជាងគេលំដាប់ទី៣ បន្ទាប់ពីវិស័យពាណិជ្ជកម្មលក់ដុំ និង ពាណិជ្ជកម្មលក់រាយ។ [26]

តួអង្គសំខាន់ៗមួយចំនួនដែលត្រូវការហិរញ្ញវត្ថុនៅក្នុងវិស័យកសិកម្មរួមមាន៖

១. តម្រូវការរបស់កសិករ និងសហគ្រិន

២. ប្រតិបត្តិការរវាងអ្នកដើរតួនៅតាមបណ្តោយខ្សែសង្វាក់ផលិតកម្ម

៣. តម្រូវការហេដ្ឋារចនាសម្ព័ន្ធ និង

៤. ការបង្កើតចំណេះដឹងដើម្បីគាំទ្រដល់វិស័យនេះ

ចំពោះកសិករ និងសហគ្រិនកសិកម្មតូចៗ ត្រូវការហិរញ្ញវត្ថុដើម្បីអនុញ្ញាតឱ្យពួកគេពង្រីកផលិតកម្ម និងធ្វើពិពិធកម្មផលិតផលរបស់ពួកគេបន្ថែមទៀត។ ឧទាហរណ៍ ហិរញ្ញវត្ថុសម្រាប់ធាតុចូល (ដូចជាគ្រាប់ពូជនិងជី) ផលិតកម្ម (ដូចជាគ្រឿងម៉ាស៊ីននិងឧបករណ៍) និងទីផ្សារ (ដូចជាការកែច្នៃការវេចខ្ចប់ និងការដឹកជញ្ជូន) ជាដើម។[27]

### ៣.៤.២ វិស័យហិរញ្ញវត្ថុចូលរួមទាក់ទាញការវិនិយោគលើដំណាំស្រូវនៅកម្ពុជា

#### ៣.៤.២.១ ការគាំទ្រហិរញ្ញវត្ថុ និងក្របខណ្ឌនៃការអនុវត្ត

តាមរយៈគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជាបានបង្ហាញថា រាជរដ្ឋាភិបាល កម្ពុជាគឺជាប្រភពចម្បងក្នុងការផ្តល់ហិរញ្ញប្បទានដល់សេវាផ្សព្វផ្សាយកសិកម្ម។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុវត្តការផ្តល់ហិរញ្ញប្បទាននេះតាមយន្តការផ្តល់ថវិកាតាមកម្មវិធី ដោយធានាឱ្យមានស្ថិរភាពនៃការផ្តល់ហិរញ្ញវត្ថុនេះ គឺអាស្រ័យទៅលើលទ្ធភាពនៃការលើកសំណើរ និងការអនុវត្តរបស់អង្គភាពពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនូវកម្មវិធីរយៈពេលវែង និងផែនការប្រចាំឆ្នាំ រួមទាំងផែនការប្រចាំឆ្នាំ រួមទាំងផែនការថវិកានៅថ្នាក់ឃុំ។

រីឯមូលនិធីពីដៃគូអភិវឌ្ឍន៍នានា គឺជាប្រភពនៃការបំពេញបន្ថែមលើការផ្តល់សេវាផ្សព្វផ្សាយកសិកម្មរបស់រាជរដ្ឋាភិបាលដ៏សំខាន់

---

[26] ធនាគារជាតិ នៃកម្ពុជា, ការផ្តល់ហិរញ្ញប្បទានដល់វិស័យកសិកម្ម (២០១៦), ទំព័រ២។

[27]IISD, Finanacing for Agriculture [ហិរញ្ញវត្ថុសម្រាប់វិស័យកសិកម្ម] (September 2015), 1.

ផងដែរ។

គម្រោងអភិវឌ្ឍន៍កសិកម្មដែលផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ទោះបីជាគម្រោងទាំងនេះអនុវត្តដោយអង្គភាពរាជរដ្ឋាភិបាល ឬអង្គការមិនមែនរាជរដ្ឋាភិបាលក្តី ជាទូទៅមានទំហំធំគួរឱ្យកត់សម្គាល់ និងត្រូវបន្តតួនាទីក្នុងការផ្តល់សេវាផ្សព្វផ្សាយកសិកម្មនៅក្នុងរយៈពេលខ្លី និងរយៈពេលមធ្យមនាពេលអនាគត។

### ៣.៤.២.២ វិធានការពាក់ព័ន្ធនឹងការប្រមូលទិញ និងការកែច្នៃស្រូវ[28]

វិធានការបន្ទាន់ និងផ្តល់ផលភ្លាមៗគឺបន្តជំរុញការផ្តល់ហិរញ្ញប្បទានសម្រាប់ការប្រមូលទិញស្រូវដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា ត្រូវរៀបចំ និងដាក់ឱ្យប្រើប្រាស់នូវយន្តការហិរញ្ញប្បទានចាំបាច់នានាដើម្បីឱ្យសហគមន៍កសិករ រោងម៉ាស៊ីនកិនស្រូវ និងក្រុមហ៊ុននាំចេញមានលទ្ធភាពខ្ចីឥណទាន ក្នុងនោះរួមទាំងឥណទានពីធនាគារពាណិជ្ជដែលរួមបញ្ចូលយន្តការផ្តល់ឥណទានកម្ចីដែលមានការធានាពីរដ្ឋផងដែរ។ វិធានការជាក់ស្តែងដូចជា៖

- បង្កើនទុនបន្ថែមដល់ធនាគារអភិវឌ្ឍន៍ជនបទបន្ថែមចំនួន៧លានដុល្លាអាមេរិក (ពី១៣ លានដុល្លាអាមេរិក ទៅ ២០លានដុល្លាអាមេរិក)
- បង្កើនទ្វេដងនូវមូលនិធិទ្រទ្រង់ និងអភិវឌ្ឍន៍វិស័យកសិកម្មពីចំនួន១៨ ទៅ ៣៦លានដុល្លាអាមេរិក
- រៀបចំគម្រោងធានាឥណទានដើម្បីធានាកម្ចីពីធនាគារពាណិជ្ជដោយក្រុមហ៊ុន និងស្ថាប័នប្រមូលទិញស្រូវ
- សហការជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីបង្កើនមូលនិធិរំលែកហានិភ័យដើម្បីជំរុញការផ្តល់កម្ចីដោយធនាគារពាណិជ្ជចំពោះសកម្មភាពកែច្នៃក្នុងវិស័យកសិកម្ម និងសម្រាប់សហគ្រាសធុនតូច និងមធ្យម
- ជំរុញឱ្យក្រុមហ៊ុនកែច្នៃ(ម្ចាស់រោងចក្រម៉ាស៊ីនកិនស្រូវ) អនុវត្តតាមទស្សនទាន "ទីផ្សារស្រូវបើកចំហរ" (Open Paddy Market) តាមរយៈសកម្មភាពមួយចំនួនដូចជា ផលិតកម្មតាមកិច្ចសន្យាជាមួយសហគមន៍កសិកម្ម សេវាថ្លឹង ហាលស្រូវ

[28] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, គោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ (២០១៥) ទំព័រ៧។

បញ្ចាំស្រូវដើម្បីយកប្រាក់ទៅប្រើប្រាស់ជាមុន ផ្តល់ពូជស្រូវមានគុណភាពខ្ពស់ និងជីគីមីជាដើម ដល់សហគមន៍កសិករ ដើម្បីផលិតតាមតម្រូវការទីផ្សារ។

### ៣.៤.២.៣ តួនាទីធនាគារអភិវឌ្ឍន៍ជនបទចំពោះការអភិវឌ្ឍកសិកម្ម

ធនាគារអភិវឌ្ឍន៍ជនបទ គឺជាធនាគាររបស់រដ្ឋតែមួយគត់នៅកម្ពុជា បានបង្កើតឡើងនៅឆ្នាំ១៩៩៨ ក្នុងការផ្តល់ឥណទានដល់កសិករ និងគ្រឹះស្ថានហិរញ្ញវត្ថុមួយចំនួន ដើម្បីបម្រើឱ្យគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ដូច្នេះហើយ ស្របជាមួយគោលនយោបាយរបស់រាជរដ្ឋា-ភិបាលក្នុងការគ្រោងនាំចេញអង្ករឱ្យបាន១លានតោន ក្នុងឆ្នាំ២០១៥កន្លងមក ទើបឥណទានប្រហែលជា៥០ ទៅ ៦០ % ត្រូវបានផ្គត់ផ្គង់ទៅលើវិស័យស្រូវអង្ករ។

នៅក្នុងឆ្នាំ២០១៧ រាជរដ្ឋាភិបាលកម្ពុជា បានទម្លាក់កញ្ចប់ថវិកាពិសេសតាមរយៈធនាគារអភិវឌ្ឍន៍ជនបទចំនួន ៥០លានដុល្លា ជាទុនបង្វិល (Working Capital) រយៈពេលខ្លី (មិនលើសពី១ឆ្នាំ)សម្រាប់វិស័យស្រូវអង្ករ សម្រាប់ផ្តល់ឥណទានទៅដល់អ្នកស្នើសុំ"**ឥណទានកញ្ចប់ពិសេស**" ដែលអាចយកតែស្រូវ និងអង្ករធ្វើជាវត្ថុបញ្ចាំប៉ុណ្ណោះ និងប្រើនីតិវិធីផ្តល់កម្ចីត្រឹមតែ២ថ្ងៃ ខុលពីកម្ចីធម្មតាត្រូវប្រើរយៈពេល២សប្តាហ៍ ឬ១ខែ។ ក្នុងការផ្តល់ឥណទាននេះ ធនាគារអាចផ្តល់លទ្ធភាពកម្ចី៧០%នៃតម្លៃស្រូវអង្ករដែលប្រជាកសិករមាន និងមិនចាំបាច់មកដល់ទីតាំងរបស់ធនាគារផងដែរ គឺធនាគារមានការបង្កើតក្រុមចល័ត២ក្រុម គឺក្រុមទី១. ក្រុមផ្តល់ឥណទាន និងក្រុមទី២. ក្រុមតាមដានការប្រើប្រាស់ឥណទាន។ ក្រុមហ៊ុនដែលបានកម្ចីទាំងនេះហើយ ត្រូវតែយកទៅ ប្រើប្រាស់ក្នុងការទិញដំណាំស្រូវតែប៉ុណ្ណោះ ដើម្បីជំរុញការទិញកសិផលស្រូវអង្ករពីកសិករ។ គិតត្រឹមឆ្នាំ២០១៧ ធនាគារបានផ្តល់ឥណទានដល់ក្រុមហ៊ុនស្រូវប្រហែលជា១០ក្រុមហ៊ុន។ ការផ្តល់ឥណទានទៅដល់ម្ចាស់រោងម៉ាស៊ីនកិនស្រូវ គឺជាការជួយដល់កសិករ ជំរុញឱ្យម្ចាស់រោងម៉ាស៊ីនកិនស្រូវខំទិញស្រូវពីកសិករ ក្នុងតម្លៃសមស្របអាចឱ្យកសិករចំណេញទាំងអស់គ្នា។ ធនាគារអភិវឌ្ឍន៍ជនបទ ក៏បានផ្តល់ឥណទានទៅដល់ប្រជាកសិករផងដែរ តាមរយៈសហគមន៍កសិកម្មផងដែរ។

មិនត្រឹមតែប៉ុណ្ណោះ រាជរដ្ឋាភិបាលក៏បានផ្តល់ទុនបន្ថែមទៅលើផ្នែកផ្សេងៗ ដែលពាក់ព័ន្ធជាមួយវិស័យស្រូវអង្ករនេះថែមទៀត។

ទិសដៅបន្ថែមក្នុងការលើកកម្ពស់វិស័យកសិកម្ម៖

១. ពង្រឹងតួអង្គនីមួយៗនៅក្នុងចង្វាក់ផលិតកម្ម

២. ជួយសម្រួលប្រព័ន្ធដឹកជញ្ជូន (Logistic) ដល់កសិករ

៣. ពង្រីកឥណទានទៅកាន់អនុវិស័យផ្សេងៗទៀតក្រៅពីវិស័យស្រូវអង្ករនៅក្នុងកសិកម្ម។

## ៣.៥ ការអភិវឌ្ឍធនធានមនុស្ស និងការស្រាវជ្រាវអភិវឌ្ឍន៍កសិកម្ម

### ៣.៥.១ ការអភិវឌ្ឍធនធាន[29]

ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស បានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើនប្រសិទ្ធិភាពការងារប្រកបដោយសមធម៌ និងជាគោលដៅចម្បងក្នុងការលើកស្ទួយសមត្ថភាព ធនធានមនុស្ស ស្របតាមជំនាញបច្ចេកទេស និងវិទ្យាសាស្ត្រ ដើម្បីរួមចំណែកលើកស្ទួយ អភិវឌ្ឍន៍ប្រទេស ដែលជាជ្រុងមួយនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។ ក្នុងនោះដែរក្រសួងកសិកម្ម រុក្ខប្រមាញ់និងនេសាទ បានយកចិត្តទុកដាក់ក្នុងការពង្រឹងការគ្រប់គ្រង និង ការអភិវឌ្ឍធនធានមនុស្ស ជាពិសេសការគ្រប់គ្រងការងារមន្ត្រីរាជការ ការរៀបចំមន្ត្រីកាន់មុខតំណែង ការងាររចនាសម្ព័ន្ធ ការរៀបចំបៀវត្សន៍ ធានារ៉ាប់រងសង្គម ការងាររៀបចំដំឡើងថ្នាក់ ការងាររៀបចំមន្ត្រីគ្រប់អាយុឱ្យចូលនិវត្តន៍ ជាពិសេសគឺការងារអភិវឌ្ឍន៍ធនធានមនុស្ស ឱ្យស្របទៅតាមគោលការណ៍ច្បាប់ និងបទដ្ឋាននានា។

បច្ចុប្បន្នដំណើរនៃផលិតកម្មកសិកម្ម បាននិងកំពុងវិវឌ្ឍតាមរបត់ទីផ្សារសេរី ដូចនេះរចនា-សម្ព័ន្ធ និងភារកិច្ចនៃអង្គភាពនីមួយៗចាំបាច់ត្រូវតែកែលម្អ ឱ្យស្របតាមសភាពការណ៍ជាក់ស្តែង។ វិស័យកសិកម្មអាចអភិវឌ្ឍន៍ទៅបាន គឺតម្រូវឱ្យមានរចនាសម្ព័ន្ធគ្រប់គ្រងរឹងមាំ និងធនធានមនុស្សមានសមត្ថភាពសមស្រប នៅតាមបណ្តាអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលភារកិច្ចទាំងអស់នេះត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពនាពេលកន្លងមក។

[29] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ផែនការអភិវឌ្ឍន៍កសិកម្ម ២០១៤-២០១៨, ទំព័រ៩១។

ការអភិវឌ្ឍធនធានមនុស្សនៅក្នុងវិស័យត្រូវបានយកចិត្តទុកដាក់ និងបានបញ្ចូលក្នុងកម្មវិធីនៃគោលនយោបាយអភិវឌ្ឍន៍កសិកម្ម ជាចំណុចអាទិភាពដែលត្រូវយកចិត្តទុកដាក់ផងដែរ។ ការអភិវឌ្ឍ ធនធានមនុស្សក្នុងវិស័យកសិកម្ម តាមរយៈការបង្កើនចំណេះដឹងបច្ចេកទេស និងជំនាញកសិកម្មពាក់ព័ន្ធនានា ស្រាវជ្រាវបន្ថែមនូវបច្ចេកវិទ្យា និងរបកគំហើញថ្មីៗ ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារការងារ និងការអភិវឌ្ឍសង្គម ជាពិសេសបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង ស្ថាប័ន ការផ្តល់សេវាគាំទ្រ និងពង្រឹងសមត្ថភាពផ្នែកអប់រំ និងបណ្តុះបណ្តាលសម្រាប់អភិវឌ្ឍន៍កសិកម្មប្រកបដោយនិរន្តរភាព។

ក្រសួងកសិកម្ម រុក្ខប្រមាញ់និងនេសាទ និងស្ថាប័នដែលក្រសួងដែលពាក់ព័ន្ធបានជំរុញ និងយកចិត្តទុកដាក់ដល់សាកលវិទ្យាល័យ និងសាលាជាតិកសិកម្មនានា បន្តនិងយកចិត្តទុកដាក់ក្នុងការបណ្តុះបណ្តាល អភិវឌ្ឍន៍ធនធានមនុស្សទៅលើវិស័យកសិកម្ម ឱ្យសមស្របទៅនឹងតម្រូវការទីផ្សារការងារផង និងក្នុងគោលបំនងលើកលើកកម្ពស់លើវិស័យកសិកម្មផងដែរ។

ជាក់ស្តែងយោងទៅការបូកសរុបលទ្ធផលរបស់ផែនការអភិវឌ្ឍកសិកម្មឆ្នាំ ២០១៤-២០១៨កន្លងទៅនេះ សាកលវិទ្យាល័យភូមិន្ទកសិកម្ម បានសម្រេចបានការងារសំខាន់ៗជាច្រើន ជាពិសេស បណ្តុះបណ្តាលធនធានមនុស្ស ការងារស្រាវជ្រាវវិទ្យាសាស្ត្រ ការងារផ្សព្វផ្សាយ និងការងារសហប្រតិបត្តិការជាតិនិងអន្តរជាតិលើផ្នែកអប់រំកសិកម្ម។ នៅឆ្នាំ២០១៣ កន្លងទៅនេះ មាននិស្សិតសរុបចំនួន ៥, ៩៧៣នាក់ ក្នុងនោះនារី១,៩០៣នាក់ (ស្មើនឹង២៣%នៃនិស្សិតសរុប) កំពុងសិក្សានៅថ្នាក់បរិញ្ញាបត្ររង បរិញ្ញបត្រ បញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត នៅក្នុងសាកលវិទ្យាល័យភូមិន្ទកសិកម្ម លើមុខជំនាញ១០ ដែលពាក់ព័ន្ធនឹងវិទ្យាសាស្ត្រកសិកម្ម វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិស្វកម្ម-កសិកម្ម វិទ្យាសាស្ត្រជលផល កសិឧស្សាហាកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ រៀបចំដែនដី និងរដ្ឋបាលដីធ្លី និងវិទ្យាសាស្ត្រកៅស៊ូ។ ក្នុងរយៈពេល៥ឆ្នាំកន្លងទៅនេះ សាកលវិទ្យាល័យភូមិន្ទកសិកម្ម បានបណ្តុះបណ្តាលនិស្សិតដោយជោគជ័យបានចំនួន១៦៣នាក់ (នារី៣៧៦នាក់)។ សាលាជាតិកសិកម្មចំនួន២ទៀតគឺ សាលាជាតិកសិកម្មព្រែកលៀប មាននិស្សិតចំនួន១ ៥៦២នាក់

(នារី៥០២) និងសាលាជាតិកសិកម្មកំពង់ចាមមាននិស្សិតសរុបចំនួន ១,៥៥៩នាក់ (នារី៦០៨នាក់) ក៏មានបណ្តុះបណ្តាលជំនាញកសិកម្មនេះ និងបាន វាយតម្លៃថាមានការវិវឌ្ឍន៍ផងដែរ។

សាកលវិទ្យាល័យ និងសាសាជាតិសាលាកសិកម្មទាំងនេះ បានអនុវត្តកម្មវិធីអប់រំនានា ដើម្បីលើកកម្ពស់គុណភាពអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសកសិកម្មក្រោមគោលបំណងៈ

- ពង្រឹង និងពង្រីកធនធានមនុស្សលើវិស័យកសិកម្ម វិទ្យាសាស្ត្រ និងជំនាញពាក់ព័ន្ធដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារការងារ និងការអភិវឌ្ឍសង្គម ស្រាវជ្រាវនូវបច្ចេកទេស និងរបកគំហើញថ្មីៗ បម្រើកការអប់រំគោលនយោបាយ និងការអភិវឌ្ឍកសិកម្ម
- បង្កើនប្រសិទ្ធភាពគ្រប់គ្រងដឹកនាំ និងសមត្ថភាពអប់រំបណ្តុះបណ្តាលក្នុងវិស័យកសិកម្ម ដើម្បីឆ្លើយតបនឹងតម្រូវការបណ្តុះបណ្តាល ស្របតាមទីផ្សារពលកម្មកសិកម្ម
- ពង្រឹងគុណភាពបណ្តុះបណ្តាលការអនុវត្តជាក់ស្តែង និងស្រាវជ្រាវបច្ចេកវិទ្យាសាស្ត្រគ្រប់កម្រិត និងបន្តកសាងហេដ្ឋារចនាសម្ព័ន្ធសិក្សា។

ការអភិវឌ្ឍធនធានមនុស្សពិតជាកត្តាដ៏មានសារៈសំខាន់ ក្នុងការកសាងនិងអភិវឌ្ឍប្រទេស ដូចគ្នានេះដែរ ទោះបីជាវិស័យកសិកម្មជាវិស័យអាទិភាពមួយនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែយើងនៅតែមានបញ្ហា ប្រឈមនឹងការខ្វះខាតធនធានមនុស្សដែលមានជំនាញក្នុងវិស័យកសិកម្ម ដែលនេះទាមទារឱ្យរាជរដ្ឋាភិបាល និងក្រសួងដែលពាក់ព័ន្ធបន្តជំរុញបន្ថែមទៀត ដើម្បីលើកកម្ពស់ប្រសិទ្ធភាពធនធានមនុស្ស ព្រមទាំងជាផ្នែកមួយធ្វើអ្នកវិនិយោគ មានចំណាប់អារម្មណ៍ក្នុងការបង្កើនការវិ- និយោគផងដែរ។

### ៣.៥.២ ការអភិវឌ្ឍ និងស្រាវជ្រាវកសិកម្ម [30]

សិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យា និងចំណេះដឹងវិទ្យាសាស្ត្រគ្រប់ដីប្រកបដោយ ចីរភាព និងកំណត់តម្រូវការសារធាតុចិញ្ចឹមរបស់ដំណាំ សម្រាប់ប្រព័ន្ធដំណាំស្រូវជាមូលដ្ឋាន (១)ស្រូវដើមរដូវ និងស្រូវវស្សា (២)ស្រូវប្រដេញទឹក និងស្រូវមុនទឹកចូល (៣) ស្រូវស្រោចស្រពពេញលេញធ្វើបីដង

[30] រាជរដ្ឋាភិបាលកម្ពុជា, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ (២០១៤), ទំព័រ៣០៥។

- អនុវត្តបង្កុំបច្ចេកវិទ្យាប្រព័ន្ធដំណាំស្រូវជាមូលដ្ឋានដែលមានលក្ខណៈសេដ្ឋកិច្ច និងបរិស្ថានសម្រាប់តំបន់ទំនាបរំពឹងទឹកភ្លៀង តំបន់ស្រោចស្រពពេញលេញ និងតំបន់ចំការ
- សិក្សាស្រាវជ្រាវចំណេះដឹងបច្ចេកវិទ្យាក្នុងប្រព័ន្ធគ្រប់គ្រងទីជំរាល ឱ្យកាន់តែមានផលិតភាព និងនិរន្តរភាពដើម្បីរួមចំណែកលើកកម្ពស់សកម្មភាពអនុវត្តល្អ ក្នុងការប្រើប្រាស់ធនធានដី និងទឹក
- សិក្សាស្រាវជ្រាវក្នុងផលិតកម្មជាក់ស្តែងលើប្រសិទ្ធភាពសម្ភារឧបករណ៍ និងម៉ាស៊ីនសម្រាប់បម្រើឱ្យការប្រមូលផលវេចខ្ចប់ ដឹកជញ្ជូនទុកដាក់ប្រកបដោយសុវត្ថិភាព និងធានាបាននូវការបាត់បង់ទាប
- ស្រាវជ្រាវ និងអភិវឌ្ឍឧបករណ៍ប្រើប្រាស់ សម្រាប់បម្រើឱ្យការងារក្រោយប្រមូលផលដំណាំ
- ការវាយតម្លៃទៅលើសមត្ថភាពបន្សាំទៅនឹងបម្រែបម្រួលអាកាសធាតុដូចជា គ្រោះទឹកជំនន់ និងរាំងស្ងួតក្នុងរបបកសិកម្ម និង
- ពង្រឹងសមត្ថភាព និងទេពកោសល្យរបស់អ្នកស្រាវជ្រាវ និងផ្សព្វផ្សាយតាមរយៈបណ្តុះ-បណ្តាលក្នុង និងក្រៅប្រទេស។

## ៣.៦ ការលើកកម្ពស់ការផ្តល់សេវាគាំទ្រ និងធាតុចូលវិស័យកសិកម្ម

សេវាកម្មពាក់ព័ន្ធផលិតកម្មកសិកម្ម ឬធាតុចូលកសិកម្ម សំដៅដល់សេវាកម្មនានាដែលគាំទ្រដល់ការលើកកម្ពស់ផលិតកម្មកសិកម្មដូចជា សេវាឥណទាន សន្សំ បញ្ញើ ដឹកជញ្ជូនកសិផល ផ្សព្វផ្សាយ ឬបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម សេវាកម្មផ្គត់ផ្គង់សម្ភារកសិកម្ម សេវារៀបចំដី សេវាផ្គត់ផ្គង់ប្រេងឥន្ធនៈ សេវាកម្មកម្ចាត់សមាសធាតុចង្រៃ និងសេវាកម្មផ្សេងទៀតដែលអនុវត្តនៅក្នុងប្រព័ន្ធកសិកម្ម។

### ៣.៦.១ វិធានការនាក់ទងនឹងផលិតកម្មស្រូវ[31]

វិធានការនេះ ត្រូវបានរៀបចំឡើងជាវិធានគោលនយោបាយក្នុងការសម្រួលនីតិវិធីនាំចូលពូជស្រូវ ជី ធាតុចូលកសិកម្ម និងគ្រឿងយន្តកសិកម្ម រួមជាមួយការបន្តលើកទឹកចិត្តផ្នែកពន្ធលើការនាំចូលចំពោះសម្ភារ និងបរិក្ខាទាំងនោះ។ ដើម្បីអនុវត្តន៍ទៅបាន រាជរដ្ឋាភិបាលបានកំណត់សកម្មភាពលើះ

[31] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ផែនការសកម្មភាពសម្រាប់អនុវត្តឯកសារគោលនយោបាយ ស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ, (ភ្នំពេញ, ២០១១)។

- ការរៀបចំកែលំអនីតិវិធីជួយសម្របសម្រួលការធ្វើអាជីវកម្ម ការចុះបញ្ជីការ និងការនាំចូលសម្ភារកសិកម្ម។ ព័ត៌មានបង្ហាញផ្លូវសម្រាប់អតិថិជនស្តីពីការកែសម្រួលនីតិវិធីក្នុងការធ្វើអាជីវកម្ម ការចុះបញ្ជីការ និងការនាំចូលសម្ភារកសិកម្មនឹងត្រូវបានកំណត់ច្បាស់លាស់ និងដាក់ឱ្យប្រើប្រាស់
- ការរៀបចំបញ្ជីឈ្មោះគ្រឿងយន្តកសិកម្ម ដើម្បីសម្របសម្រួលការនាំចូលជាដើម។

**៣.៦.២ ប្រព័ន្ធកសិកម្មតាមកិច្ចសន្យា**

កសិកម្មតាមកិច្ចសន្យា ត្រូវបានចាត់ទុកជាយន្តការដ៏មានប្រសិទ្ធភាពមួយដើម្បីបង្កើនការរួមចំណែក និងផលប្រយោជន៍សម្រាប់កសិករខ្នាតតូច និងក្រុមហ៊ុនកសិ-ពាណិជ្ជកម្ម។ ដើម្បីលើកកម្ពស់ផលិតភាព និងការទទួលបានទីផ្សារសម្រាប់ផលិតផលកសិកម្ម រាជរដ្ឋាភិបាលកម្ពុជាបានលើកកម្ពស់ការធ្វើកសិកម្មតាមកិច្ចសន្យា នៅតាមសហគមន៍ដែលជាមធ្យោបាយមួយ ដើម្បីកាត់បន្ថយឧបសគ្គមួយចំនួនក្នុងផ្នែកកសិកម្ម និងការផ្សារភ្ជាប់ទៅទីផ្សារ។

គម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច ជាគម្រោងរួមគ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម មានគោលដៅបង្កើនវិបុលភាពរបស់កសិករខ្នាតតូចតាមរយៈការបង្កើនប្រាក់ចំណេញកាន់តែច្រើនដោយផ្សារភ្ជាប់អាជីវកម្មកសិកម្ម និងទីផ្សារក្នុងទិសដៅដើម្បីសម្រេចបាននូវការបង្កើនប្រាក់ចំណូលដល់អ្នកទទួលផលផ្ទាល់(កសិករ) បានមកពីការងារធ្វើកសិកម្មវិញរហូតដល់៥០% និងបង្កើនប្រាក់ចំណូលសុទ្ធដល់អ្នកទទួលផលមិនផ្ទាល់(អ្នកវិនិយោគ) ច្រើនជាង៣០% គម្រោងនេះកំពុងធ្វើអន្តរាគមន៍ទៅលើផ្នែកតំណភ្ជាប់គ្នារវាង អាជីវកម្ម និងទីផ្សារៈ

១. កសាងសមត្ថភាពកសិករ-ផលិតករឱ្យយល់ដឹងពីទីផ្សារ និងអាជីវកម្ម

២. គាំទ្រក្រុមប្រឹក្សាឃុំលើការពង្រឹងប្រព័ន្ធព័ត៌មានទីផ្សារ

៣. សម្របសម្រួលកសិកម្មតាមកិច្ចសន្យា និងភាពជាដៃគូជាមួយកសិ-ពាណិជ្ជកម្ម។

### ៣.៦.៣ ការដាក់ប្រើប្រាស់សេវាកម្មព័ត៌មានទីផ្សារពាណិជ្ជកម្ម[32]

ការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ "សេវាព័ត៌មានទីផ្សារកសិកម្ម" ថ្ងៃទី១៨ តុលា ២០១៨ ក្នុងគោលបំណង៖

- បង្កើនប្រសិទ្ធភាពក្នុងការទទួលបាននូវព័ត៌មានទីផ្សារកសិកម្មសម្រាប់កសិករ ពាណិជ្ជករ និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀតនៅក្នុងសង្វាក់ទីផ្សារកសិកម្ម ដើម្បីជួយពួកគាត់អោយលក់បានក្នុងតម្លៃល្អមួយ និងបង្កើតបណ្តាញទំនាក់ទំនងទីផ្សារកសិកម្មដើម្បីជាប្រយោជន៍ដល់ពួកគាត់
- ធ្វើឱ្យកសិករមានជម្រើសកាន់តែច្រើនឡើង ក្នុងការធ្វើទីផ្សារផលិតផលរបស់ពួកគាត់ ជាមួយនឹងការចរាចរតម្លៃមួយប្រសើរជាងមុននៅក្នុងសង្វាក់ទីផ្សារកសិកម្ម
- ធ្វើឱ្យកសិករ និងពាណិជ្ជករមានសមត្ថភាពកាន់តែច្រើនជាងមុនក្នុងបច្ចេកទេសមុន និងក្រោយប្រមូលផល ជាពិសេសការធ្វើចំណាត់ថ្នាក់ផលិតផល ការវេចខ្ចប់ ការរក្សាទុក និងបច្ចេកទេសក្នុងការដឹកជញ្ជូន ដើម្បីធ្វើឱ្យផលិតផលរបស់ពួកគាត់ទទួលបានតម្លៃកាន់តែប្រសើរឡើង និង
- កសាង និងពង្រឹងសមត្ថភាពបច្ចេកទេស របស់មន្ត្រីដែលបំរើការងារពាក់ព័ន្ធនឹងទីផ្សារកសិកម្មនៅតាមរាជធានី-ខេត្ត។

ចំពោះការអនុវត្តវិញ អាចដំណើរការទៅបានដោយផ្អែកលើចំណុចសំខាន់២៖

- ព័ត៌មានទីផ្សារ គឺមន្ត្រីទីផ្សារកសិកម្មនៅទីក្រុងភ្នំពេញ និងនៅតាមរាជធានី-ខេត្តចំនួន ២៥ ផ្សេងទៀតប្រមូលព័ត៌មានតម្លៃលក់ដុំនៃកសិផលចំនួន៣ដងក្នុង១សប្តាហ៍ និងព័ត៌មានតម្លៃលក់រាយចំនួន១ដងក្នុង១សប្តាហ៍ពីផ្សារចំនួន៣០ធំៗ និងចំណុចប្រមូលផ្សេងៗទៀតនៅក្នុងរាជធានី-ខេត្តគោលដៅចំនួន២៥។
- ការអភិវឌ្ឍទីផ្សារ គឺនៅចុងឆ្នាំ២០០៧សេវាព័ត៌មានទីផ្សារកសិកម្មត្រូវបានពង្រីកបន្ថែមដោយការណែនាំនូវសាលាទីផ្សារកសិករ។

[32] គេហទំព័រសេវាពតិមានទីផ្សារកសិកម្ម https://amis.org.kh/page/info-agri-market

### ៣.៦.៤ ការលុបចោលអង្គភាពភ្នាក់ងារកម្ពុជានាវាចរ (កាំសាប)

អង្គភាពភ្នាក់ងារកម្ពុជានាវាចរ (កាំសាប) ដែលជាភ្នាក់ងាររដ្ឋមួយត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៧៩ដើម្បីសម្រួលដល់ការធ្វើពាណិជ្ជកម្មតាមនាវា ពោលគឺ១ថ្ងៃបន្ទាប់ពីលោកនាយករដ្ឋមន្ត្រីបានចុះហត្ថលេខាលើអនុក្រឹត្យបញ្ចប់វត្តមានរបស់កាំកុងត្រូល នៅតាមមាត់ច្រកព្រំដែនទាំងអស់។ វិធានការផ្នែកពាណិជ្ជកម្មបានលេចចេញជារូបរាងជាបន្តបន្ទាប់នៅក្នុងអ្វីដែលរាជរដ្ឋាភិបាលបានលើកឡើងថាជាកំណែទម្រង់មួយ ដើម្បីពង្រឹងឯករាជភាពផ្នែកសេដ្ឋកិច្ចនៅក្នុងគ្រាដែលប្រទេសកម្ពុជាបានបាត់បង់ការអនុគ្រោះពន្ធលើការនាំចេញអង្ករ និងប្រឈមមុខការបាត់បង់ប្រព័ន្ធអនុគ្រោះពន្ធនានា។

ចំណាត់ការទាំងនេះត្រូវបានប្រមុខរាជរាជរដ្ឋាភិបាលលើកឡើងថា ដើម្បីកាត់បន្ថយភាពសាំញ៉ាំ និងស្មុគស្មាញក្នុងការធ្វើធុរកិច្ច និងសម្រួលការនាំចេញទំនិញកម្ពុជាទៅទីផ្សារអន្តរជាតិឱ្យកាន់តែប្រសើរបន្ថែមទៀត បើទោះជាមិនបានចូលរួមចំណែកធំដល់ការកាត់បន្ថយថ្លៃដើមរបស់ធុរជនក្តី តែវាជាសញ្ញាវិជ្ជមានថ្មីមួយបន្ថែមទៀតសម្រាប់វិស័យឯកជន ខណៈតម្លៃអគ្គិសនីខ្ពស់នៅតែជាបញ្ហា។ ប្រធានសមាគមភ្នាក់ងារបញ្ជូនទំនិញកម្ពុជាថា នេះជាការគិតគូរដ៏ល្អរបស់ថ្នាក់ដឹកនាំក្នុងការជួយដល់វិស័យឯកជន បើទោះបីជាការចំណាយពេលឆ្លងកាត់កាំសាបមិនច្រើនក្តី។ការសម្រេចលុបចោលភ្នាក់ងារកម្ពុជានាវាចរ នឹងធ្វើឱ្យតម្លៃដឹកជញ្ជូនទំនិញនៅកម្ពុជាធ្លាក់ចុះបន្ថែមទៀត ហើយក៏នឹងចូលរួមចំណែកបន្ថែមទៀតក្នុងការជួយលើកទឹកចិត្ត និងការទាក់ទាញឱ្យមានការចូលមកវិនិយោគនៅកម្ពុជាបានកាន់តែច្រើនទៀតផងដែរ។ ចំណែកនាយកមជ្ឈមណ្ឌលគោលនយោបាយ ក៏បានឱ្យដឹងថា ការលុបចោលអង្គភាពកាំសាប និងអង្គភាពមួយចំនួនទៀតដែលមិនចាំបាច់ គឺជារឿងត្រឹមត្រូវ ព្រោះបច្ចុប្បន្ននៅកម្ពុជាមានអាជ្ញាធរជាច្រើនដែលកំពុងធ្វើការងារជាន់ជំនាញគ្នា ដូច្នេះការលុបចោលកាំសាប វាជាការល្អ ជាការជួយសម្រួលទៅដល់ការចេញចូលនៅកំពង់ផែ។

## ៣.៧ ការកែទម្រង់ការគ្រប់គ្រងដីធ្លី

នៅក្នុងនីតិកាលទី៥ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តកាន់តែសកម្ម និងស៊ីជម្រៅថែមទៀតនូវកំណែទម្រង់ដីធ្លី ដោយផ្តោតលើការពង្រឹងការគ្រប់គ្រង ការរៀបចំ ការប្រើប្រាស់ និងការបែងចែកដីធ្លី ការធានាសុវត្ថិភាពនៃកម្មសិទ្ធដី ការលុបបំបាត់ភាពអនាធិបតេយ្យ ក្នុងការកាប់ដីដោយខុសច្បាប់ ការដាក់ចេញនូវវិធានការសមស្រប ដើម្បីទប់ស្កាត់ការប្រមូលដីទុក ដោយមិនបានប្រើប្រាស់ និងមិនផលិត ព្រមទាំងដើម្បីរួមចំណែកសម្រេចគោលដៅអភិវឌ្ឍន៍ជាតិ ក្នុងការកាត់បន្ថយភាពក្រីក្រ

ការធានានូវសន្តិសុខស្បៀង និងការអភិវឌ្ឍសង្គមសេដ្ឋកិច្ចក្នុងបរិការណ៍នៃសេដ្ឋកិច្ចទីផ្សារសេរី។ ក្នុងនោះដែរដើម្បីសម្រេចបានគោលដៅរាជរដ្ឋាភិបាល បានផ្តល់អាទិភាពលើការជំរុញរៀបចំច្បាប់ស្តីពីការរៀបចំដែនដី និងនគរូបនីយកម្ម និងច្បាប់ស្តីពីដីកសិកម្ម។

ការងារកែទម្រង់ដីធ្លីពិតជាមានសារៈសំខាន់នៅក្នុងការពង្រើក និងបែងចែកដីធ្លីកសិកម្ម ក្នុងក្របខណ្ឌដីសម្បទានសេដ្ឋកិច្ច សំដៅលើកកម្ពស់បង្កើនផលិតភាពនិងពិពិធភាវូបនីយកម្ម និងការកាត់បន្ថយភាពក្រីក្រនៅតាមទីជនបទ របស់ប្រជាកសិករ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាននិងកំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីអំពី ការគ្រប់គ្រងនិងប្រើប្រាស់ដីកសិកម្ម និងស្វែងធនធាដើម្បីរៀបចំតំបន់ដាំដុះ និងផែនទីប្រើប្រាស់ដីកសិកម្ម។

### ៣.៧.១ ការគ្រប់គ្រង និងប្រើប្រាស់ដីកសិកម្ម[33]

ដីកសិកម្មជាធនធានធម្មជាតិដ៏សំខាន់ ដែលទាមទារឱ្យមានការប្រើប្រាស់ឱ្យបានសមស្រប ធានារក្សាបាននូវគុណភាពពីធម្មជាតិ និងកែលំអគុណភាព ដើម្បីគោលដៅអភិវឌ្ឍន៍ផលិតកម្មមួយប្រកបដោយនិរន្តរភាព។ ក្នុងន័យនេះការជំរុញការស្រាវជ្រាវ និងការរៀបចំចំណាក់ថ្នាក់ដី ទៅតាមប្រភេទដំណាំមានសក្តានុពលអំណោយផលដល់ផលិតកម្មកសិកម្ម គឺចាំបាច់ត្រូវយកចិត្តទុកដាក់អនុវត្តឱ្យមានប្រសិទ្ធភាព ជាពិសេសជំរុញការកសាងច្បាប់ស្តីពីការកសាង និងប្រើប្រាស់ដីកសិកម្ម ដើម្បីឱ្យមាននីតិវិធីគ្រប់គ្រងការពារដីដែលមានគុណភាពសម្រាប់ផលិតកម្ម និងមានវិធានបច្ចេកទេសថែរក្សា និងកែលម្អឡើងវិញ។

វិស័យកសិកម្មជាជ្រុងទី១ នៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។ នៅទូទាំងប្រទេស ស្រូវគឺជាដំណាំដ៏សំខាន់បំផុត ដែលពឹងផ្អែកលើប្រព័ន្ធក្សេត្របរិស្ថានចំនួនពីរ ស្ថិតនៅជុំវិញប្រព័ន្ធទន្លេមេគង្គ-ទន្លេបាសាក់ និងទន្លេសាប ក្នុងតំបន់ទំនាបកណ្តាល គឺ(១)តំបន់ទំនាបល្បាប់ចាស់ភាគខាងលើដែលពឹងផ្អែកលើទឹកភ្លៀងទាំងស្រុង និងទឹកអូរ និងបឹងបួរ និង(២) តំបន់ទំនាបលិចទឹកសកម្មពីទឹកទន្លេ។ ប្រព័ន្ធក្សេត្របរិស្ថានទាំងពីរនេះ លាតសន្ធឹងប្រមាណ៩៧% នៃផ្ទៃដីដាំដុះសរុបក្នុងប្រទេស។ ធនធានដីជាងពាក់កណ្តាលជាដីមានដីជាតិតិច ហើយដីជាតិដីក៏មានការប្រែប្រួលខុសៗគ្នា

[33] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ផែនការអភិវឌ្ឍន៍កសិកម្ម ២០១៤-២០១៨, ទំព័រ៤៨។ ?

ដែលជះឥទ្ធិពល ដល់ការប្រើប្រាស់ដីសម្រាប់ដំណាំ និងរុក្ខជាតិផ្សេងៗ។ ភាគច្រើននៃដីមានជីជាតិខ្ពស់និងមធ្យមប្រមូលផ្តុំនៅតំបន់ទំនាប ប្រមាណជា៤៣% នៃវាលទំនាបទាំងមូល។ ដីមានជីជាតិទាំងនោះនៅរាយប៉ាយជាប់គ្នានឹងតំបន់ខ្ពង់រាបដែលមានជីជាតិតិចតួច។ បច្ចុប្បន្នកសិកម្មកំពុងជំរុញការធ្វើប្រពលវប្បកម្មដំណាំ ជាពិសេសដំណាំស្រូវ ការធ្វើពិពិធកម្មកសិកម្ម និងពាណិជ្ជូបនីយកម្ម ការប្រើប្រាស់ពូជថ្មីមានសក្តានុពលទិន្នផលខ្ពស់ គុណភាពល្អ ការអនុវត្ត កសិកម្មល្អ ក្នុងផលិតកម្មដំណាំ ការការពារផលិតផលសម្គាល់ភូមិសាស្ត្រ ការធ្វើកសិកម្មសរីរាង្គ ការអនុវត្តបច្ចេកវិទ្យាក្រោយការប្រមូលផល ការដោះបញ្ហាដីខ្សោះជីជាតិ ការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងការរិះរកការកាត់បន្ថយ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។

### ៣.៧.២ ការប្រើប្រាស់ដីក្នុងការគ្រប់គ្រងធនធានទឹក

ទឹក និងដីជាធនធានគ្រឹះនៃវិស័យកសិកម្ម។ ក្នុងន័យនេះការស្តារ ការកសាង និងថែទាំហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព គឺដើម្បីជំរុញផ្ទៃដីស្រោចស្រព និងជំរុញការបង្កបង្កើនផល។ ការគ្រប់គ្រង ការប្រើប្រាស់ និងការបែងចែកដីធ្លីប្រកបដោយប្រសិទ្ធភាព គឺជាត្រូវបានរួមផ្សំជាមួយនឹងការរៀបចំប្រព័ន្ធស្រោចស្រព ការផ្តល់ចំណេះដឹង និងបច្ចេកទេសកសិកម្ម ការកែច្នៃផលិតផលកសិកម្ម ការផ្តល់ព័ត៌មានពីទីផ្សារផលិតផលកសិកម្ម ។ល។ ក្នុងបរិបទនេះការការពារគុណភាពទឹក ការរៀបចំប្រព័ន្ធធារាសាស្ត្រស្របទៅតាមគោលការណ៍នៃការថែរក្សា ការការពារ បរិស្ថាន ការការពារទឹកជំនន់ និងភាពរាំងស្ងួត គឺជាយុទ្ធសាស្ត្រគន្លឹះក្នុងការកាត់បន្ថយភាពក្រីក្រ។

ជារួមការអនុវត្តគោលនយោបាយដីធ្លី គឺជួយធានាសុវត្ថិភាពនៃការកាន់កាប់ដីការប្រើប្រាស់ដីធ្លីទៅតាមសក្តានុពលប្រកបដោយប្រសិទ្ធភាព ព្រមទាំងផ្តល់ដីទៅឱ្យអ្នកផលិតពិតប្រាកដដែលនេះជាកត្តាគន្លឹះក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមធ្វើឱ្យជីវភាពរស់នៅរបស់ប្រជាជនកាន់តែប្រសើរ។ ការកសាងព័ត៌មានប្រព័ន្ធដីធ្លីសម្រាប់ជាមូលដ្ឋាននៃការរៀបចំប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ និងការជំរុញការអនុវត្តភាពជាដៃគូសហគ្រាសកសិកម្ម និងកសិករតាមរយៈផលិតកម្មតាមកិច្ចសន្យា និងជម្រើសផ្សេងៗទៀត ព្រមទាំងការបង្កើត និងអនុវត្តយុទ្ធសាស្ត្រ និងក្របខណ្ឌនៃការបែងចែកដី សម្រាប់បែងចែកដីរយៈពេលវែង និងមធ្យម

ក្នុងគោលដៅសង្គមកិច្ចសេដ្ឋកិច្ច គឺជាគោលដៅដែលបានកំណត់នៅក្នុងគោលនយោបាយដីធ្លីផងដែរ។

## ៣.៨ ការពង្រឹងសហគមន៍កសិកម្ម

### ៣.៨.១ អំពីសហគមន៍កសិកម្ម[34]

សហគមន៍កសិកម្ម ឬសហករណ៍ គឺជាសមាគមន៍ស្វយ័តនៃមនុស្សមួយក្រុមប្រមូលផ្តុំគ្នាដោយស្ម័គ្រចិត្តដើម្បីបំពេញតម្រូវការសេដ្ឋកិច្ច សង្គម និងវប្បធម៌ និងសេចក្តីប៉ងប្រាថ្នាតាមរយៈការធ្វើជាម្ចាស់រួមគ្នា និងគ្រប់គ្រងសហគមន៍តាមបែបប្រជាធិបតេយ្យ។

មុខរបររបស់សហគន៍កសិកម្មមានចំនួន៥គឺ

១. ឥណទានកសិកម្ម

២. ទីផ្សារ

៣. ផ្គត់ផ្គង់ធាតុចូលកសិកម្ម និងតម្រូវការប្រចាំថ្ងៃ

៤. ការប្រើប្រាស់រួមគ្នា

៥. ដំបូន្មានបច្ចេកទេសកសិកម្ម និងផ្សេងៗទៀត

សហគមន៍កសិកម្មសរុបគិតត្រឹមឆ្នាំ២០១៨ មានចំនួន១,១១៦សហគមន៍ ក្នុងនោះមានសមាជិកសរុប១៣០,០៥៩នាក់ ស្រី៨០,៨៣៩នាក់ មានដើមទុនសរុប៦៩,០៧៧,១១៥,៧៦៦រៀល។

តារាងទី៦៖ ចំនួនសហគមន៍ដែលត្រូវបានបង្កើតនៅតាមបណ្តាឆ្នាំ គិតត្រឹមឆ្នាំ២០១៨

| ឆ្នាំបង្កើត | ចំនួនសហគមន៍កសិកម្ម | សមាជិកសរុប | សមាជិកនារី | តម្លៃភាគហ៊ុន | ដើមទុន |
|---|---|---|---|---|---|
| **២០០៣** | ១ | ៣៨ | ១៦ | ៥,០២០,០០០ | ១៨,៦០៥,០០០ |
| **២០០៤** | ១៣ | ១,១៣៦ | ៥៥៥ | ៣២៨,៨៥៨,១៥០ | ៦១១,៧៣៥,១៧៧ |
| **២០០៥** | ២៩ | ២,៤៧៩ | ១,៣៧៧ | ៥៩៧,៦៧០,០០០ | ១,១១៥,០៣៤,១១៩ |
| **២០០៦** | ១៩ | ២,៧០៩ | ១,៤៧២ | ៤៩៧,៥០០,០០០ | ១,២០០,៥១៣,០០០ |
| **២០០៧** | ១២ | ៧២៣ | ៣៦៦ | ១១៥,១៥០,០០០ | ២៤២,៥៧៦,៦៥០ |
| **២០០៨** | ១៩ | ១,១៧៦ | ៧៨៨ | ២៥២,៦២០,០០០ | ៥១៤,៣៣៣,៧០០០ |

[34] នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម, ការប្រកបមុខរបរផ្គត់ផ្គង់របស់សហគមន៍កសិកម្ម (ភ្នំពេញ, ២០១៦), ទំព័រ១៤។

| | | | | | |
|---|---|---|---|---|---|
| **២០០៩** | ៦១ | ៨,៧០០ | ៥,០៩៥ | ២,៥០០,៣៦០,០០០ | ៦,៣៦០,២០៦,២១០ |
| **២០១០** | ៦៤ | ៦,៨២៨ | ៤,០៨១ | ២,៥២៣,៦៨២,៥០០ | ៣,៥៦២,៣៦៦,៩១៤ |
| **២០១១** | ៦០ | ៨,១៥៥ | ៥,៣៤៦ | ២,៣៣៣,៩៧៥,០០០ | ៣,១៩៧,៦២៦,៩៤៨ |
| **២០១២** | ១៤១ | ១៨,៩៦៩ | ១១,៨៣៧ | ៣,១៨៣,៥២០,០០០ | ៥,៦៦០,៧៩២,២៥៤ |
| **២០១៣** | ១០៤ | ១០,៦៩៨ | ៦,៨០៤ | ៤,៨១១,៤០០,០០០ | ៦,៥៩០,១២៥,៦០០ |
| **២០១៤** | ១៥៤ | ១០,៦២៩ | ៦,៣១០ | ៣,៧៤១,២៦៥,០០០ | ៥,៥៥៧,៣៨១,១០៦ |
| **២០១៥** | ៧៣ | ៥,៥៩៧ | ៣,៣៤៧ | ១,២៩៥,១៧០,០០០ | ១,៤៥៩,៦៧៨,៥០០ |
| **២០១៦** | ១០៧ | ៩,៨៦០ | ៥,៧៤២ | ២,២២៥,៨៨៥,០០០ | ៣,២៨៣,២៨២,៨៨០ |
| **២០១៧** | ២៣ | ១,៤៨៨ | ៧០៥ | ២៤៤,៧១០,០០០ | ៨៥,២០០,១៤២ |
| **២០១៨** | ២៣៦ | ៤០,៥៥៨ | ២៦,៥៩៨ | ១២,៦៤០,៦៣៨,៩៥០ | ២៩,៦១៧,៦៥៧,៥៦៦ |
| **សរុប** | **១,១១៦** | **១៣០,០៥៩** | **៨០,៤៣៩** | **៣៧,២៩៧,៤២៤,៦០០** | **៦៩,០៧៧,១១៥,៧៦៦** |

ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### ៣.៨.២ ការជំរុញពង្រឹងសហគមន៍កសិកម្មនៅក្នុងផលិតកម្មដំណាំស្រូវ

#### ៣.៨.២.១ ច្បាប់ស្តីពី "សហគមន៍កសិម្ម"

ច្បាប់ស្តីពីសហគមន៍កសិកម្ម មានយន្តការគាំទ្រសហគមន៍កសិកម្មតាមរយៈ៖

**ក្រុមប្រឹក្សាគោលនយោបាយសហគមន៍កសិកម្ម៖** ត្រូវបានបង្កើតឡើងដោយមានការដឹកនាំដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ដែលមានសមាជិកជាតំណាងមកពីទីស្តីការ គណៈរដ្ឋមន្ត្រី តំណាងក្រសួងមហាមន្ត្រី តំណាងក្រសួង ឬស្ថាប័នផ្សេងទៀតដែលពាក់ព័ន្ធនឹងសហគមន៍កសិកម្មកម្ពុជា តំណាងវិស័យឯកជន តំណាងសង្គមស៊ីវិល និងប្រធានអង្គភាពជំនាញពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ស្ថាប័នមានសមត្ថកិច្ច៖** ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ជាស្ថាប័នមានសមត្ថកិច្ចក្នុងការជំរុញ និងគាំទ្រក្នុងការគាំទ្រក្នុងការបង្កើត ការចុះបញ្ជី ប្រតិបត្តការ និងការអភិវឌ្ឍរបស់សហគមន៍ កសិកម្ម។

**មូលនិធិអភិវឌ្ឍសហគមន៍កសិកម្ម៖** ត្រូវបង្កើតមូលនិធិអភិវឌ្ឍសហគមន៍កសិកម្ម ដែលសរសេរជាអក្សរកាត់ "ម.អ.ស" ដោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីប្រើប្រាស់ក្នុងក្របខ័ណ្ឌនៃការគាំទ្រ និងអភិវឌ្ឍសហគមន៍កសិកម្ម។

**ស្ថាប័នពាក់ព័ន្ធចំពោះសហគមន៍កសិកម្ម៖** ក្រសួង ស្ថាប័នរដ្ឋដែលពាក់ព័ន្ធមានភារកិច្ចជួយគាំទ្រក្នុងដែនសមត្ថកិច្ចរបស់ខ្លួនចំពោះរាល់សកម្មភាព និងប្រតិបត្តិការរបស់សហគមន៍កសិកម្ម តាម គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។

**៣.៨.២.៣ ការចូលរួមពីស្ថាប័នពាក់ព័ន្ធនានា**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ៖** ឯកសារអនុវត្តន៍គោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ក្រសួងបានចេញនូវវិធានគោលនយោបាយ និងសកម្មភាពដូចខាងក្រោម៖

១. រៀបចំគម្រោងផែនការ ដើម្បីគាំទ្រការរៀបចំរចនាសម្ព័ន្ធអង្គការកសិករ និងពង្រឹងតួនាទីរបស់រចនាសម្ព័ន្ធអង្គការកសិករ ដើម្បីធ្វើការសម្របសម្រួលដោះស្រាយបញ្ហាផលិតកម្ម តម្រូវការ និងកង្វល់នានាៗរបស់កសិករ ដោយ៖

- ចងក្រងក្រុមកសិករឱ្យទៅជាសហគមន៍កសិកម្ម។ សហគមន៍កសិកម្ម១៣០ត្រូវបង្កើតឡើងនៅតាមខេត្តគោលដៅ។
- ធ្វើសិក្ខាសាលាផ្សព្វផ្សាយគោលនយោបាយនៃស្រូវចេញរបស់រាជរដ្ឋាភិបាល ដល់សហគន៍កសិកម្ម។ សហគមន៍កសិកម្មចំនួន១៣០នៅក្នុងខេត្តគោលដៅទាំង១០ នឹងយល់ដឹងអំពីគោលនយោបាយនាំស្រូវចេញរបស់រាជរដ្ឋាភិបាល។
- រៀបចំចងក្រងបណ្តាញសហគមន៍កសិកម្ម។
- រៀបចំសហគមន៍កសិកម្មចំនួន១៣០ទៅតាមខេត្តគោលដៅចំនួន១០។
- រៀបចំធ្វើសិក្ខាសាលាបំពាក់បំប៉នអំពីជំនួញស្រូវអង្ករដល់សហគមន៍កសិកម្មចំនួន១៣០។
- រៀបចំចងក្រងបណ្តាញធុរកិច្ចសហគមន៍កសិកម្មនៅថ្នាក់ជាតិ និងតាមខេត្តគោលដៅគោលដៅចំនួន១៣បណ្តាញ។

២. លើកកម្ពស់សមត្ថភាពរបស់កសិករ និងសហគមន៍កសិកម្ម ក្នុងការខ្ចី និងការប្រើប្រាស់ឱ្យមានប្រសិទ្ធភាព នូវឥណទានស្តីពីស្ថាប័នហិរញ្ញវត្ថុផ្សេងៗ ដោយ៖

- ពង្រឹងសមត្ថភាពសហគមន៍កសិកម្មលើការងារដឹកនាំ រដ្ឋបាល ការគ្រប់គ្រងបញ្ជីគណនេយ្យសហគមន៍ និងផែនការមុខជំនួញ។ ថ្នាក់ដឹកនាំសហគមន៍ និងហិរញ្ញិកចំនួន៨០០នាក់យល់ដឹងអំពីការគ្រប់គ្រងគណនេយ្យ ភាពជាអ្នកដឹកនាំ និងការងាររដ្ឋបាល។ ថ្នាក់ដឹកនាំ និងកសិករសហគមន៍កសិកម្មចំនួន១,៦០០នាក់

យល់ដឹងអំពីផែនការមុខជំនួញ និងក្រុមសន្សំប្រាក់ចំនួន៦០របស់សហាគមន៍កសិកម្មត្រូវបានបង្កើតឡើង។

- ពង្រឹងហេដ្ឋារចនាសម្ព័ន្ធសហាគមន៍ ដើម្បីគាំទ្រដល់សហាគមន៍កសិកម្ម។ សហាគមន៍ចំនួន២០ នឹងទទួលបានសេវាគាំទ្រលើការសម្ងួត និងឃ្លាំងស្តុកស្រូវ។
- ពង្រឹងសហាគមន៍កសិកម្មលើការងារគ្រប់គ្រងបញ្ជីបេឡា និងការធ្វើជំនួញកសិកម្ម។ អ្នកដឹកនាំ និងបេឡាសហាគមន៍កសិកម្មចំនួន៩១០នាក់នឹងបង្កើតបានសមត្ថភាពគ្រប់គ្រងការងារបេឡា និងការធ្វើផែនការជំនួញ
- កសាងឡសម្ងួត បិងឃ្លាំងស្តុកកសិផល(ស្រូវ)ដល់សហាគមន៍ចំនួន២០។

**សហាគមន៍ស្រូវអង្ករ៖** សាររបស់ប្រធានសហាគមន៍ស្រូវអង្ករកម្ពុជា "ដើម្បីជួយជំរុញការចូលរួមពីសហាគន៍កសិកម្ម សហព័ន្ធស្រូវអង្ករកម្ពុជានឹងជួយធានាទីផ្សារជូនសហាគមន៍ដែលមានបំណងចូលរួមជួយជំរុញកូតារបស់សហព័ន្ធស្រូវអង្ករកម្ពុជា ក្នុងការនាំចេញមានគុណភាពខ្ពស់ទៅកាន់ទីផ្សារក្នុងស្រុក និងអន្តរជាតិ"។ សហព័ន្ធស្រូវអង្ករនឹងជួយជំរុញការធ្វើស្រែតាមកិច្ចសន្យាដើម្បីអភិវឌ្ឍន៍ស្តង់ដាល្អៗក្នុងការជួយធ្វើទំនើបកម្មវិស័យស្រូវនៅក្នុងពេលខាងមុខ។

**គម្រោងបង្កើតសហាគមន៍គំរូតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC) ៖** សម្តៅពង្រឹងសមត្ថភាពរបស់សហាគមន៍កសិកម្ម (AC) ដែលជាក្រុមកសិករទ្រង់ទ្រាយតូចៗដើម្បីឱ្យគាត់មានការយល់ដឹងអំពីទីផ្សារ និងការធ្វើជំនួញ។ គោលបំណងរបស់គម្រោង គឺដើម្បីផ្តល់ព័ត៌មានទីផ្សារទាក់ទងនឹងស្រូវ ទំនិញប្រើប្រាស់ ផលិតផល និងធាតុចូលកសិកម្ម ដល់សហាគមន៍កសិកម្ម និងសមាជិក សហាគមន៍កសិកម្ម។ បន្ទាប់មក សហាគមន៍កសិកម្មអាចបង្កើតជាសេវាកម្មមួយចំនួនដូចជាទីផ្សាររួមគ្នា អាជីវកម្មទំនិញរួមគ្នាក្នុងចំណោមសមាជិករបស់ខ្លួន ហើយសហាគមន៍កសិកម្មអាចចូលរួមនៅក្នុងសង្វាក់ទីផ្សារនៃការនាំចូល ឬការនាំចេញផលិតផលកសិកម្មរវាងប្រទេសវៀតណាម និងកម្ពុជាផងដែរ។

# ជំពូកទី៤
# វិភាគពីភាពខ្លាំង បញ្ហាប្រឈម និងដំណោះស្រាយ

## ៤.១ ភាពខ្លាំង

តាមរយៈការរីកចម្រើននៃផលិតកម្ម និងការធ្វើពាណិជ្ជកម្មក្នុងវិស័យស្រូវអង្ករបានបង្ហាញឱ្យឃើញថា វិស័យនេះបានទទួលការយកចិត្តទុកដាក់ និងជំរុញពីរាជរដ្ឋាភិបាលដែលជាសមិទ្ធផលនៃការអនុវត្តនូវគោលយោបាយនានា។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏បានយកចិត្តទុកដាក់ខ្ពស់ដល់ការអភិវឌ្ឍវិស័យកសិកម្ម តាមរយៈការបង្កើនការវិនិយោគ ទៅលើការស្តារ និងកសាងហេដ្ឋា-រចនាសម្ព័ន្ធ ដើម្បីបម្រើឱ្យវិស័យកសិ-ឧស្សាហកម្មជាពិសេស ប្រព័ន្ធធារាសាស្ត្រ ផ្លូវជនបទ ព្រមទាំងបង្កើនសមត្ថភាព ការផ្តល់សេវាបច្ចេកទេស ការប្រើប្រាស់ធាតុចូលឱ្យបានសមស្រប ការគ្រប់គ្រង ដីធ្លី ឥណទានជនបទ ការអភិវឌ្ឍសហគមន៍ និងទីផ្សារកសិកម្ម។ វិស័យកសិកម្មត្រូវបានគិតគូរ ដោយចាប់ផ្តើមពីការកែទម្រង់ដីធ្លី ការផ្តល់កម្មសិទ្ធដីធ្លីជូនប្រជាជនតាំងពីទសវត្សន៍ឆ្នាំ៨០ ដោយមិនយកពន្ធ លើដីស្រែ និងកសិផល រហូតមកដល់បច្ចុប្បន្ន ដោយកសិករខ្មែរបានកែប្រែទម្លាប់ពីការផលិតដើម្បីតម្រូវការផ្ទាល់ខ្លួនមកផលិតដើម្បីពាណិជ្ជកម្ម ។

កម្ពុជាបានក្លាយជាប្រទេសមួយក្នុងចំណោមប្រទេស ដែលនាំអង្ករធំៗទាំង១០ ក្នុងឆ្នាំ២០១៧បាននាំអង្ករប្រមាណ៦៣៥ពាន់លានតោន កើនឡើងជិតពីរដងធៀបនឹងឆ្នាំ២០១៣។ ក្នុងន័យនេះកម្ពុជាសម្រេចបានកំណើនវិជ្ជមានក្នុងវិស័យកសិកម្ម ទោះបីវិស័យនេះទទួលរងផលប៉ះពាល់ដោយសារថ្លៃទាបលើទីផ្សារអន្តរជាតិ ការបាត់បង់កម្លាំងពលកម្ម និងភាពងាយរងគ្រោះនៃបាតុភូតធម្មជាតិ។[35]

សក្តានុពលផ្នែកផលិតកម្មកសិកម្ម ពិសេសធនធានដី និងទឹកនៅមានលទ្ធភាពគ្រប់គ្រាន់ ដែលជាមូលដ្ឋានគ្រឹះ សំដៅលើការធានាដល់រីកលូតលាស់ផ្នែកផលិតកម្មកសិកម្ម។

[35]រាជរដ្ឋាភិបាលកម្ពុជា, យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ (កញ្ញា ,២០១៨), ទំព័រ៥។

គោលនយោបាយ និងយុទ្ធសាស្ត្រនានា បានតម្រង់ទិសដាក់ឱ្យអនុវត្តច្បាស់លាស់ក្នុងការអភិវឌ្ឍក្នុង វិស័យកសិកម្មកម្ពុជា ជាពិសេសគឺដំណាំស្រូវ ហើយអ្នកពាក់ព័ន្ធទាំងអស់មានការប្តេជ្ញាចិត្ត និងទទួលស្គាល់នូវសារៈសំខាន់នៃវិស័យនេះ ទាំងផ្នែកឯកជន ដៃគូរអភិវឌ្ឍន៍ អង្គការក្រៅរាជរដ្ឋាភិបាល និងប្រជាកសិករ។

ខាងក្រោមនេះជាកត្តា ដែលមានបង្ហាញពីភាពជោគជ័យនាពេលកន្លងមក និងសក្តានុពលក្នុងការចូលរួមទាក់ទាញ និងការជួយសម្រួលដល់ការវិនិយោគលើវិស័យស្រូវអង្ករ។

### ៤.១.១ ការបង្កើតសហព័ន្ធស្រូវអង្ករ

សហព័ន្ធស្រូវអង្ករកម្ពុជា (ស.អ.ក) ជាស្ថាបន័ឯកជនដែលមានសំឡេងតែមួយគត់នៃឧស្សាហកម្មស្រូវអង្ករកម្ពុជាដោយបានបង្កើតឡើងតាមរយៈការបោះឆ្នោតនៅថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០១៤ ដោយសមាជិកស្ថាបនិកចំនួន២១៣រូប តំណាងឱ្យសហព័ន្ធអ្នកនាំចេញអង្ករសហគមន៍កសិករ សមាគមន៍ម្ចាស់រោងម៉ាស៊ីនកិនស្រូវ របស់ក្រុមហ៊ុននាំចេញអង្ករ ក្រុមហ៊ុនដឹកជញ្ជូន។ ក្នុងរយៈពេលចុងក្រោយនេះក៏មានក្រុមហ៊ុនថ្មីៗចូលសមាជិកស.អ.កបន្ថែម ដែលបច្ចុប្បន្នមានចំនួនសរុប២៩២ (មើលបន្ថែមក្នុងឧបសម្ព័ន្ធទី៨) ក្នុងទស្សនៈវិស័យផ្តល់នូវអង្ករដែលមានតម្លៃប្រកួតប្រជែង និងគុណភាពខ្ពស់បំផុតដល់ពិភពលោក។

សមិទ្ធផលធំៗជាច្រើនដែលសហព័ន្ធ អ្នកនាំចេញអង្ករកម្ពុជាសម្រេចបានដើម្បីភាពរីកចម្រើនរបស់វិស័យស្រូវអង្ករកម្ពុជា តែអ្វីដែលពិសេសនោះពេលថ្មីៗនេះសមិទ្ធផល២ដែលសហព័ន្ធស្រូវអង្ករកម្ពុជា សម្រេចបានជួយ កាត់បន្ថយការចំណាយយ៉ាងច្រើនរបស់អ្នកវិនិយោគលើវិស័យស្រូវអង្ករ។

ទី១-រាជរដ្ឋាភិបាលប្រកាស លុបចោល ការបង់ពន្ធលើ អង្ករបន្ថែម (VAT) សម្រាប់រោងម៉ាស៊ីនកិនស្រូវ និងសហគ្រាសកែច្នៃអង្ករ សម្រាប់ផ្គត់ផ្គង់ដល់ក្រុមហ៊ុននាំចេញ បន្ទាប់ពីមានការស្នើសុំពី សហព័ន្ធអ្នកនាំចេញអង្ករកម្ពុជា។

ទី២-រាជរដ្ឋាភិបាលតាមរយៈនាយករដ្ឋានគយ និងរដ្ឋាករ កាលពីថ្ងៃទី២ ខែមេសា បានប្រកាសលុបចោលកម្រៃបែបបទគយ (Customs Processing Fee-CPS) លើការនាំចេញអង្ករ

ដែលមានតម្លៃ១៥ដុល្លារអាមេរិកក្នុង១កុងតឺន័រ ដោយចាប់អនុវត្តន៍នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៤ តទៅ។

ជារៀងរាល់ឆ្នាំ សហព័ន្ធស្រូវអង្ករ ក៏ជាអ្នកបង្កើត "វេទិការស្រូវអង្ករកម្ពុជា" ក្នុងគោលបំណង ដើម្បីធ្វើបច្ចុប្បន្នភាពលើវិស័យស្រូវអង្ករ ស្វែងរកពីបញ្ហា និងដំណោះស្រាយផ្សេងៗ និងជាពិសេស ដើម្បីធ្វើទំនើបកម្មវិស័យស្រូវអង្ករកម្ពុជា ឱ្យស្របទៅនឹងនិន្នាការទីផ្សារពិភពលោកទាំងសមត្ថភាពប្រកួតប្រជែងខាងតម្លៃ កំណើនផលិតភាព និងការលើកកម្ពស់ការនាំចេញ។ ឆ្នាំ២០១៨ពិសេសជាងរាល់ឆ្នាំ ដោយសារតែ សហព័ន្ធស្រូវអង្ករ បានដាក់សម្ភោធនូវសមិទ្ធផលថ្មីមួយជូន វិស័យស្រូវអង្ករនោះគឺ ម៉ាកសញ្ញាវិញ្ញាតិកម្មអន្តរជាតិដែលមានឈ្មោះថា "ម្លិះអង្គរ" (MALYS ANGKOR)។ "ម្លិះអង្គរ" (MALYS ANGKOR) ជាម៉ាកអង្ករក្រអូបប្រណិតរបស់កម្ពុជា ដែលនឹងផ្តល់ការបញ្ជាក់ទៅលើប្រភេទអង្ករក្រអូបប្រណិតនានា ដែលកម្ពុជាផលិតបាន រួចកិនកែច្នៃ សម្រាប់នាំចេញ ឬចែកចាយក្នុងស្រុក។ រាល់ការប្រើប្រាស់ម៉ាក«ម្លិះអង្គរ» «MALYS ANGKOR» គឺជាការធានាចំពោះមុខច្បាប់ថាអង្ករនោះជាផលិតផលកម្ពុជាយ៉ាងពិតប្រាកដ។

### ៤.១.២ ការធ្វើទំនើបកម្មកសិកម្ម

ការធ្វើទំនើបកម្មនេះ គឺជាកត្តាដែលចូលរួមជួយជំរុញវិស័យស្រូវអង្ករកម្ពុជា ដើម្បីបង្កើនទិន្នផលស្រូវ កាត់បន្ថយថ្លៃដើម និងបង្កើនការនាំចេញ។ កាលពីរយៈពេលប៉ុន្មានឆ្នាំមុន ការដាំដុះស្រូវតាមបែបបុរាណ ទទួលបានផលត្រឹមតែ ២-៣តោន ក្នុង១ហិកតាប៉ុណ្ណោះ ប៉ុន្តែប្រសិនបើធ្វើតាមបែបទំនើបកម្មវិញ អាចទទួលបានផលរហូតដល់ ៥តោន ឬច្រើនជាងនេះ ក្នុង១ហិកតា។ ការធ្វើទំនើបកម្មនេះធ្វើបានតាមរយៈ ការជំរុញឱ្យ កសិករ ឬសហគមន៍ ម្ចាស់រោងម៉ាស៊ីនកិនស្រូវ ឬអ្នកវិនិយោគិនស្រូវអង្ករនានា ឱ្យប្រើប្រាស់នូវគ្រឿងចក្រ គ្រឿងយន្ត ឬឧបករណ៍ ក្នុងការដាំដុះ និងកែច្នៃស្រូវអង្ករ។ នៅពេលដែលមានការប្រើប្រាស់ទំនើបកម្មបែបនេះ នឹងបានជួយកាត់បន្ថយ កម្លាំងពលកម្ម ការចំណេញពេលវេលា និងទទួលបានទិន្នផលខ្ពស់ ដើម្បីឆ្លើយតបក្នុងទីផ្សារ នាំចេញស្រូវអង្ករកម្ពុជា។ ជាបទពិសោធន៍ ប្រទេសជិតខាងក៏គេទទួលបានអត្ថប្រយោជន៍ជាច្រើនពីការធ្វើទំនើបកម្មនេះដែរ ដូចជាប្រទេសថៃជាដើម។

តាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាលនាឆ្នាំ២០៣០ វិស័យកសិកម្មនឹងឆ្ពោះទៅរកការធ្វើទំនើបកម្មកសិកម្ម មានលក្ខណៈប្រកួតប្រជែងទីផ្សារ និងមាននិរន្តរភាព ដើម្បីរួមចំណែកក្នុងការធានាបាននូវសន្តិសុខស្បៀង សុវត្ថិភាពអាហារូបត្ថម្ភសម្រាប់សុខុមាលភាពនៃប្រជាជនកម្ពុជា។ ការធ្វើទំនើបកម្មនេះបានកំពុងធ្វើឱ្យមានការចូលរួមអភិវឌ្ឍន៍ ក្នុងវិស័យស្រូវអង្ករជាខ្លាំងក្នុងនោះសម្រាប់វិស័យឯកជន គឺជាកត្តាលីករដ៏សំខាន់ក្នុងការចូលរួមសម្រេចឱ្យបាននូវទំនើបកម្មក្នុង វិស័យស្រូវអង្ករនេះ។

### ៤.១.៣ ការបង្កើតឡសម្ងួតស្រូវស្នាដៃកូនខ្មែរលើកដំបូង

ឡសម្ងួតស្រូវស្នាដៃកូនខ្មែរលើកដំបូងបានទទួលការចាប់អារម្មណ៍ខ្លាំង ពីអ្នកវិនិយោគលើវិស័យស្រូវអង្ករ ជាពិសេសម្ចាស់រោងម៉ាស៊ីនកិនស្រូវនៅក្នុងប្រទេសផ្ទាល់តែម្តង។ ឡសម្ងួតដែលជាស្នាដៃកូនខ្មែរ ត្រូវបានបង្កើតឡើងដោយក្រុមហ៊ុនមុំវ៉ារិន អ៊ីនវេសមែន **(Mom Varin investment)**។

ឡសម្ងួតស្វ័យប្រវត្តិប្រើដោយថាមពលហ្គាស គឺជាការវិនិយោគរបស់កូនខ្មែរលើកដំបូងយីហោខ្មែរ **V-Camtech** ដែលនឹងដាក់អោយដំណើរការជាផ្លូវការនៅថ្ងៃទី១ ខែកក្កដា ២០១៧ ហើយឡសម្ងួតនេះ អាចសម្ងួតបាននូវកសិផលច្រើនប្រភេទដូចជា ស្រូវ ម្រេច ដំឡូង កាហ្វេ និងពោតជាដើម។ មូលហេតុចំបងៗ ក្នុងការផលិតឡសម្ងួតនេះ ដោយមើលឃើញពីការព្រួយបារម្ភរបស់ប្រជាពលរដ្ឋ ខ្វះឡសម្ងួតសម្រាប់សម្ងួតស្រូវ ដែលទិសដៅរបស់ក្រុមហ៊ុនគឺចង់កាត់បន្ថយការនាំចូលឡសម្ងួតពីក្រៅប្រទេស ដែលពីមុនធ្លាប់ដុត ដោយអង្កាម ហើយពេលនេះនឹងជួយសម្រួលដល់ការប្រើប្រាស់នូវឡសម្ងួតកែច្នៃថ្មីប្រើ ដោយស្វ័យប្រព័ន្ធប្រវត្តិវិញ។ ឡសម្ងួតដែលត្រូវបានផលិតឡើងមានបទដ្ឋានបច្ចេកទេសខ្ពស់ខ្ពស់ មានតំលៃចន្លោះពី ២ម៉ឺនដុល្លារ ទៅ ៣ម៉ឺនដុល្លារ ខណៈឡសម្ងួតនាំចូលមានតំលៃជាង៥ម៉ឺនដុល្លារ។ ក្រុមហ៊ុនរបស់លោកនឹងព្យាយាមផលិតឡសម្ងួតខ្នាតតូចចន្លោះ ៣ ពាន់ដុល្លារទៅ ៤ ពាន់ដុល្លារអាមេរិកអាចចល័តបាន សម្រាប់ប្រជាកសិករប្រើប្រាស់ និងកាត់បន្ថយការចំណាយ។

ឡសម្ងួតបានផ្តល់នូវអត្ថប្រយោជន៍ដូចជា ៖

១. កាត់បន្ថយចំណាយរបស់កសិករបានមួយផ្នែក

២. រក្សាបាននូវគុណភាពរបស់កសិផលខ្មែរយើង

៣. កាត់បន្ថយចំណាយរបស់អ្នកវិនិយោគក្នុងស្រុកទៅលើដំណាំស្រូវ ដូចជាម្ចាស់រោងម៉ាស៊ីនកិនស្រូវ កសិករ ឬសហគមន៍នានា យ៉ាងហោចណាស់ក៏បាន ៥០% នៃថ្លៃដើមដែរ

៩. កាត់បន្ថយពេលវេលាសម្ងួត ឬរក្សាទុក ស្រូវអង្ករ របស់កសិករ ឬម្ចាស់រោងម៉ាស៊ីនកិនស្រូវ នានាពីការប្រើប្រាសឡសម្ងួតដោយអង្គាម មកជាឡដែលមានរយៈពេលសម្ងួតលឿនជាង និងគុណភាពល្អជាង ដូចជាឡសម្ងួតនេះជាដើម។

សមិទ្ធផលនេះបាននឹងជួយសម្រួលច្រើនដល់ប្រជាកសិករ ជាពិសេសរោងម៉ាស៊ីនកិនស្រូវ និងការកាត់បន្ថយថ្លៃដើមផលិតកម្មផងដែរ។

## ៤.២ បញ្ហាប្រឈម

ទោះបីជាវិស័យស្រូវអង្ករត្រូវបានលើកកម្ពស់ និងមានការរីកចម្រើនតាមរយៈការដាក់ចេញគោលនយោបាយ ផែនការ និងយន្តការនានាក៏ពិតមែន ប៉ុន្តែវិស័យស្រូវអង្ករនៅកម្ពុជាក៏នៅតែជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម ៖

### ៤.២.១ ទីផ្សារ និងតម្លៃក្នុងវិស័យស្រូវអង្ករ

ការធានាអត្ថប្រយោជន៍កាន់តែប្រសើរសម្រាប់ទីផ្សារលក់ផលិតផល គឺជាបញ្ហាដែលត្រូវអនុវត្តបន្ថែមទៀត ពីព្រោះកសិករ និងអ្នកវិនិយោគនៅមានភាពលំបាកនៅក្នុងការស្វែងរកទីផ្សារលក់ផលិតផល និងពិបាកក្នុងការប្រកួតប្រជែងនៅលើទីផ្សារក្នុងបរិបទទីផ្សារសេរី ក្នុងនោះដែរ សេវាពត៌មានចំពោះទីផ្សារកសិកម្មគួរតែពង្រឹងបន្ថែមដើម្បីជួយដល់កសិករ និងអ្នកវិនិយោគលើវិស័យស្រូវអង្ករ។

ការនាំចេញអង្កររបស់ប្រទេសកម្ពុជា ត្រូវបានមើលឃើញថាមានការប្រែប្រួលបន្តិចបន្តួច ក្នុងអំឡុងរយៈពេល៣ឆ្នាំចុងក្រោយគិតត្រឹមឆ្នាំ២០១៨ ខណៈវិស័យនេះពេលនេះហាក់ដូចជាចូលទៅក្នុងបញ្ហាប្រឈមបន្ថែមទៀត ដែលរាជរដ្ឋាភិបាល និងវិស័យឯកជន ត្រូវធ្វើចូលរួមកាន់តែខ្លាំង ដើម្បីរក្សាវិស័យនេះឱ្យមានស្ថានភាពកាន់តែប្រសើរ។ បញ្ហាប្រឈមទាំងនេះផ្តោតលើទីផ្សារសហភាពអឺរ៉ុប ខណៈដែលប្លុកនេះបានសម្រេចយកពន្ធនាំចូលលើអង្ករកម្ពុជា ដែលបានបន្ថែមលើបញ្ហាដែលមានស្រាប់ដូចជា តម្លៃផលិតកម្មខ្ពស់ និងកង្វះហេដ្ឋារចនាសម្ព័ន្ធ នៅក្នុងវិស័យនេះជាដើម។

ថ្លៃជាកត្តាដ៏មានសារៈសំខាន់ក្នុងធានានូវទំនុកចិត្ត និងអត្ថប្រយោជន៍ដល់អ្នកវិនិយោគលើវិស័យស្រូវអង្ករតាំងពីកសិករនៅមូលដ្ឋាន រហូតដល់អ្នកនាំចេញ។ ទោះបីថ្លៃនៅក្នុងវិស័យស្រូវអង្ករមានភាពល្អប្រសើរជាងមុន

ប៉ុន្តែតម្លៃស្រូវអង្ករនៅតែមានអស្ថិរភាព ដូច្នេះទាមទារឱ្យ រាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធត្រូវយកចិត្តទុកដាក់ និងបន្តរកវិធានការដើម្បីដោះស្រាយ។ បញ្ហាទីផ្សារអន្តរជាតិមានការកើតឡើង ដោយសារការប្រកួតប្រជែងច្រើនជាមួយប្រទេសជិតខាង មួយវិញទៀតលំហូរនៃការនាំចូលអង្ករពីបរទេស បានធ្វើឱ្យរោងម៉ាស៊ីនកិនស្រូវក្នុងស្រុកមួយចំនួនក្ស័យធន ដោយសារខ្វះទុនបង្វិល និងមិនអាចលក់អង្ករចេញបាន ដោយសារតម្លៃនាំចូលមានតម្លៃថោកជាង ឬមានគុណភាពខ្ពស់ជាងក្នុងស្រុក។

ក្រៅពីបញ្ហាទាំងនេះ កសិករជាច្រើន មិនមានកុងត្រាច្បាស់លាស់ជាមួយនឹងក្រុមហ៊ុនណាទេ ដូច្នេះហើយនៅពេលទទួលបានផលមក កសិករត្រូវប្រឈមជាមួយនឹងការកកកុញស្រូវ មិនដឹងត្រូវលក់ឱ្យអ្នកណា តម្រូវការលុយដើម្បីបង្វិលថ្លៃដើម និងពុំមានលទ្ធភាពសម្ងួតរក្សាទុកស្រូវបានយូរទៀត ដែលមិនអាចរងចាំលក់ឱ្យទីផ្សាររបស់រោងម៉ាស៊ីនកិនស្រូវ និងនាំចេញបានទើបត្រូវតែបង្ខំចិត្តលក់ តាមតែតម្លៃរបស់ឈ្មួញកណ្ដាលក្រឡុកតាមតែមាត់គេ។ ការក្រឡុកតម្លៃនេះក៏ជាផ្នែកមួយប៉ះពាល់ដល់រោងម៉ាស៊ីនកិនស្រូវ និងនាំចេញអង្ករផងដែរ ព្រោះតែពួកគេត្រូវទិញស្រូវពីកសិករក្នុងតម្លៃខ្ពស់ ហើយប្រើប្រាស់ថ្លៃដើមក្នុងការកែច្នៃបន្តខ្ពស់ជាងឈ្មួញកណ្ដាល និងពេលខ្លះចាំបាច់ត្រូវទិញស្រូវបន្តពីឈ្មួញកណ្ដាលក្នុងតម្លៃថ្លៃជាងទិញដោយផ្ទាល់ពីកសិករថែមទៀត ។

### ៤.២.២ ថ្លៃដើមក្នុងផលិតកម្ម

ថ្លៃក្នុងផលិតកម្មគឺ គិតទាំងពីការចំណាយលើវត្ថុធាតុដើម និងដំណើរការនៃការដាំដុះនៅតាមមូលដ្ឋាន ក្នុងរោងម៉ាស៊ីន រហូតដល់ការដឹកជញ្ជូនដល់ទីផ្សារលក់។ កសិករ និងវិនិយោគិនលើវិស័យស្រូវអង្ករមានបញ្ហាជាមួយថ្លៃដើមនៅក្នុងផលិតកម្មដូចជា ពូជស្រូវ ជីកសិកម្ម អគ្គិសនី កម្ចីក្នុងអាត្រាការប្រាក់ខ្ពស់ តម្លៃនៃមធ្យោបាយនៃការដឹកជញ្ជូនជាដើម។

- ពូជស្រូវ៖ ការផ្គត់ផ្គង់ពូជស្រូវនៅកម្ពុជាមានកម្រិតទាប និងផ្ដាច់មុខ បច្ចុប្បន្នកសិករជាច្រើនបានប្រើប្រាស់ពូជរាប់រយប្រភេទ ដែលមិនត្រូវនឹងតម្រូវការទីផ្សារ។ ក្រុមហ៊ុនផ្គត់ផ្គង់ពូជស្រូវនៅកម្ពុជាមានចំនួនតិច

និងការចែកចាយពូជ មានលក្ខណៈផ្តាច់មុខ ឬរួមគ្នាផ្តាច់មុខ និងកំណត់ថ្លៃខ្ពស់ចំពោះទិន្នផលដែលទទួលបាននៅមានកម្រិតទាបបើធៀបនឹងប្រទេសដទៃដែលមានលក្ខខណ្ឌអាកាសធាតុ

- ជីកសិកម្មៈ
  - ជីកសិកម្មមួយចំនួននៅតែនាំចូលមកពីប្រទេសជិតខាងដោយខុសច្បាប់ និងបានចរាចរនៅលើទីផ្សារដោយគ្មានការធានាគុណភាព និងគ្មានស្លាកសញ្ញាពត៌មានជាភាសាខ្មែរ ឬមានភាសាបរទេសលើសំបកវេចខ្ចប់។
  - ជីកសិម្មមួយចំនួនត្រូវបានបានអាជីវករដែលធ្វើការផ្គត់ផ្គង់ចែកចាយបន្តពីក្រុមហ៊ុននាំចូល ឬអាជីវករលក់ដុំ លក់រាយផ្ទាល់មានការក្លែងបន្លំដោយលាយផ្សំក្លែងគុណភាព
  - ជីកសិកម្មមួយចំនួន ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានអនុញ្ញាតស្របច្បាប់ឱ្យចុះបញ្ជីការ និងនាំចូលមិនអាចប្រកួតប្រជែងជាមួយផលិតផលក្លែងគុណភាព ឬជីខុសច្បាប់បានឡើយ។
  - រាជរដ្ឋាភិបាលបានផ្តល់គោលនយោបាយអនុគ្រោះពន្ធចំពោះការនាំចូលជីកសិកម្មនានា ដើម្បីធានា ស្ថិរភាព ឬកាត់បន្ថយថ្លៃដើមផលិតកម្មកសិផលរបស់កសិករប៉ុន្តែផ្ទុយទៅវិញ កសិករត្រូវចំណាយ ឬបុលប្រាក់ ដើម្បីទិញជីកសិកម្មដែលក្លែងគុណភាពគ្មានប្រសិទ្ធិភាព និងមិនអាចយល់ច្បាស់លើសេចក្តីប្រើប្រាស់ជីបានព្រោះនៅលើសំបកជាភាសាបរទេស។
  - សកម្មភាពអប់រំផ្សព្វផ្សាយការយល់ដឹងអំពីការប្រើប្រាស់ និងលក់ដូរជីកសិកម្មនៅមានកម្រិត ព្រោះវាជាការលំបាក និងទាមទារពេលវេលា។
- តម្លៃអគ្គិសនីៈ នៅមានកម្រិតខ្ពស់ បើធៀបនឹងតម្លៃប្រទេសក្នុងតំបន់ដោយសារតែវិស័យថាមពលនៅមានបញ្ហាចម្បងៗដូចខាងក្រោមៈ
  - ផលិតកម្មអគ្គិសនីពីប្រភពអគ្គិសនី ផលិតបានតែនៅរដូវវស្សាដោយឡែកនៅរដូវប្រាំងផលិតកម្មថាមពលអគ្គិសនីផលិតបានកម្រិតទាបប៉ុណ្ណោះ

- ការពង្រីកបណ្ដោយចែកចាយដល់ជនបទនៅមានកម្រិត
- គម្លាតរវាងថ្លៃលក់អគ្គិសនីនៅក្នុងទីក្រុង និងជនបទ

- កង្វះទុនបង្វិលះ កសិករ និងម្ចាស់រោងម៉ាស៊ីនកិនស្រូវខ្វះទុនបង្វិល ដោយទុនមួយចំនួនត្រូវដាក់ដោយឡែកសម្រាប់សងទៅម្ចាស់បំណុលវិញ និងបង្កឱ្យកកស្ទះដល់ការប្រមូលទិញស្រូវ នៅរដូវប្រមូលផល។ បន្ថែមពីនេះទៀតនោះគឺ នៅពេលរោងម៉ាស៊ីនកិនស្រូវ ឬ អ្នកវិនិយោគក្នុងស្រុក ចង់ទិញស្រូវស្តុកទុកក្នុងឃ្លាំង គឺក្រុមហ៊ុនពុំមានលទ្ធភាពទិញ ហើយក៏មិនអាចខ្ចីលុយពីធនាគារបានទៀត។ ធនាគារលើកឡើងថា លុយនៅក្នុងធនាគារសល់ ចំណែករោងម៉ាស៊ីនកិនស្រូវ ឬក្រុមហ៊ុនវិនិយោគផ្សេងៗខ្វះ នេះគឺដោយសារតែរាល់ការខ្ចីលុយពីធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុនានា នៅពឹងផ្អែកលើរបស់បញ្ចាំ ទើបអាចខ្ចីបាន ដែលខុសពីប្រទេសគេជឿនលឿន គេមិនចាំបាច់ត្រូវពឹងលើទ្រព្យរបស់បញ្ចាំទេ គឺគេបន្ធូរបន្ថយ ដោយគ្រាន់តែត្រួតពិនិត្យត្រឹមតែល័ក្ខខណ្ឌចាំបាច់មួយចំនួនដូចជា ផែនការនៃការខ្ចីប្រាក់ និងស្ថានភាពនៃរោងម៉ាស៊ីនកិនស្រូវ ឬឃ្លាំងស្តុក។

### ៤.២.៣ ហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធធារាសាស្ត្រ

ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តក្នុងប្រទេសទាមទារឱ្យមានការអភិវឌ្ឍ និងវិនិយោគបន្ថែម ដើម្បីកាត់បន្ថយចំណាយប្រតិបត្តិការនៃផលិតកម្ម ក៏ដូចជាដើម្បីធានាបាននូវខ្សែសង្វាក់នៃការផ្គត់ផ្គង់ដែលអាចទុកយកបាន និងទាន់ពេលវេលា។ ប្រព័ន្ធធារាសាស្ត្រសម្រាប់ស្រោចស្រព នៅត្រូវការអភិវឌ្ឍបន្ថែម ដើម្បីកាត់បន្ថយការពឹងផ្អែកលើអាកាសធាតុដែលកន្លងមកបានកម្រិតកំណើនផលិតកម្មក្នុងវិស័យនេះ។

ប្រព័ន្ធធារាសាស្ត្រ និងការគ្រប់គ្រងទឹកមានសារៈសំខាន់ណាស់សម្រាប់ផលិតកម្មដំណាំស្រូវរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ យើងសង្កេតឃើញថាហេដ្ឋារចនាសម្ព័ន្ធត្រូវបានយកចិត្តទុកដាក់ក្នុងស្តារ និងកសាងបន្ថែម ដោយបានដាក់បញ្ចូលទៅក្នុងផែនការ និងគោលនយោបាយជាតិផងដែរ។ ទន្ទឹមនឹងនេះដែរ ហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធធារាសាស្ត្រនៅកម្ពុជានៅតែមានបញ្ហាប្រឈម និងកង្វះខាតដូចជា

នៅពេលមានអាកាសធាតុប្រែប្រួលប្រជាកសិករជួបប្រទះនឹងបញ្ហាកង្វះខាតទឹកនៅពេលមានគ្រោះរាំងស្ងួត និងទឹកជំនន់ជន់លិចដំណាំពីព្រោះដោយសារប្រព័ន្ធ រំដោះទឹកនៅមានកម្រិត។

រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកប្រព័ន្ធធារាសាស្ត្រ ជាផ្នែកមួយសំខាន់សម្រាប់ការកាត់បន្ថយភាពក្រីក្រ និងកំណើនសេដ្ឋកិច្ចសម្រាប់ទាំងអស់គ្នា។ ដើម្បីធានាឱ្យប្រព័ន្ធធារាសាស្ត្រមាននិរន្តរភាព និងការគ្រប់គ្រងវិស័យធនធានទឹកប្រកបដោយប្រសិទ្ធភាពចាំបាច់ត្រូវដោះស្រាយបញ្ហាប្រឈមជាច្រើនពាក់ព័ន្ធជាមួយស្ថាប័នរាជរដ្ឋាភិបាល ដែលកំពុងប្រឈមមុខនឹងគម្លាតជំនាញគ្រប់គ្រងវិស័យធនធានទឹក ហើយលទ្ធភាពផ្គត់ផ្គង់ទឹកមិនគ្រប់គ្រាន់អាចជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ផលិតភាពកសិកម្មសំខាន់ៗ។

បញ្ហាប្រឈមសម្រាប់ការគ្រប់គ្រងទឹក និងប្រព័ន្ធធារាសាស្ត្រ ៖

- ការផ្តល់ថវិកាលើការងារស្តារ និងសាងសង់ប្រព័ន្ធធារាសាស្ត្រមានការយឺតយ៉ាវ និងនៅមានកម្រិតដែលពុំអាចឆ្លើយតបតាមតម្រូវការជាក់ស្តែង
- ការចូលរួមរបស់កសិករលើការងារសាងសង់ ការគ្រប់គ្រង ការប្រើប្រាស់ និងថែទាំប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធរំដោះទឹក ទំនប់ការពារទឹកជំនន់នៅមានកម្រិតនៅឡើយ
- ការគ្រប់គ្រងហេដ្ឋាសម្ព័ន្ធប្រជាសាស្ត្រនៅមានកម្រិត។

## ៤.៣ ដំណោះស្រាយ

ដើម្បីឆ្លើយតប និងកែលម្អបញ្ហាមួយចំនួនដែលជាកត្តារាំងស្ទះ និងប៉ះពាល់ដល់កសិករ និងវិនិយោគិន ក្នុងវិស័យស្រូវអង្កររាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធបាន និងកំពុងស្វែងរកវិធានការនានាក្នុងការកាត់បន្ថយ និងសម្រួលឱ្យមានភាពល្អប្រសើរ។ ខាងក្រោមនេះជាវិធានការរបស់ដែលរាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធ ព្រមទាំងដំណោះស្រាយតាមរយៈការសិក្សាស្រាវជ្រាវពីប្រទេសដទៃផងដែរ៖

### ៤.៣.១ ការឆ្លើយតបនឹងបញ្ហាទីផ្សារ និងតម្លៃ

រាជរដ្ឋាភិបាល ត្រូវធានាទីផ្សារ និងតម្លៃសមរម្យសម្រាប់កសិផលក្នុងស្រុក តាមរយៈការគ្រប់គ្រងយ៉ាងតឹងរឹងចំពោះការនាំចូលនូវផលិតផលកសិកម្មទាំងអស់ពីបរទេស រួមបញ្ចូលទាំងប្រទេសជិតខាង ជាមួយគ្នានេះរាជរដ្ឋាភិបាលត្រូវតែធ្វើការបង្កើនមូលនិធិជំនួយសង្គមសម្រាប់ធ្វើការគាំទ្រដល់កសិករ និងធ្វើការបង្កើតទីផ្សារសហគមន៍តាមឃុំ

សង្កាត់ដល់កសិករលក់ផលិតផលកសិកម្មបែបគោលការណ៍ធម្មជាតិ។ រាជរដ្ឋាភិបាលត្រូវតែរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រលើកកម្ពស់ទីផ្សារកសិកម្ម ច្បាស់លាស់ដោយមានការចូលរួមពីសំណាក់កសិករខ្នាតតូចឱ្យបានទូលំទូលាយរួមទាំងការដាក់ បញ្ចូលលើដំណើរការវេចខ្ចប់ និងលំហូរនៃការនាំចេញផលិតផល។ រាជរដ្ឋាភិបាលគួរពង្រឹងការអនុវត្តវិធានការពន្ធដា និងមានវិធានការរឹងមាំដោយឡែកក្នុងការគ្រប់គ្រងឈ្មួញ និងក្រុមហ៊ុនដែលបានបង្កកដីទំហំធំអោយនៅទំនេរចោល។

### ៤.៣.១.១ ការស្វែងរក និងពង្រីកទីផ្សារសម្រាប់វិស័យស្រូវអង្ករ

ដើម្បីឆ្លើយតបនឹងបញ្ហាទីផ្សារ រាជរដ្ឋាភិបាល និងក្រសួងដែលពាក់ព័ន្ធគួរបន្តពង្រីកទីផ្សារឱ្យតាមទូលំទូលាយ ទាំងនៅក្នុងតំបន់ និងប្រទេសដទៃទៀតនៅលើពិភពលោកដែលមានតម្រូវការអង្ករ និងគួរបន្តផ្សព្វផ្សាយពត៌មានតម្លៃស្រូវអង្ករក្នុងស្រុក និងទីផ្សារអន្តរជាតិតាមប្រព័ន្ធផ្សព្វផ្សាយដូចជា តាមវិទ្យុ ទូរទស្សន៍ សារជាអក្សរ ព្រឹត្តិបត្រ គេហទំព័រទីផ្សារកសិកម្ម ធ្វើអង្កេតពីលំហូរពាណិជ្ជកម្ម និងចរាចរស្រូវអង្ករ និងវិភាគអំពីស្ថានការក្នុងតំបន់ និងអន្តរជាតិ។

**កូតានាំចេញអង្ករពីកម្ពុជា ទៅកាន់ប្រទេសចិន ៤០ម៉ឺនតោន**

ការនាំចេញអង្កររបស់កម្ពុជាក្នុងកូតាបន្ថែមដល់ ៤០ ម៉ឺនតោន ដែលផ្តល់ដោយប្រទេសចិន នឹងចាប់ផ្តើមនៅខែសីហា ២០១៨ បន្ទាប់ពីមានការចុះអនុស្សរណៈនៃការយោគយល់គ្នា (MoU) លើកូតាបន្ថែមនេះរវាងរាជរដ្ឋាភិបាលកម្ពុជា និងចិន នេះបើតាមសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងពាណិជ្ជកម្ម។ នេះជាឱកាសដ៏ល្អសម្រាប់វិស័យស្រូវអង្ករកម្ពុជា ក្នុងការបង្កើនសមត្ថភាពនាំចេញអង្ករទៅកាន់ទីផ្សារអន្តរជាតិ ខណៈការនាំចេញអង្ករទៅទីផ្សារអឺរ៉ុបបច្ចុប្បន្នត្រូវបានជាប់ពន្ធ។

សេចក្តីប្រកាសព័ត៌មាន បានឱ្យដឹងថា ដើម្បីជំរុញការនាំចេញអង្ករកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ ស្របទៅតាមគោលនយោបាយរាជរដ្ឋាភិបាល និងពង្រឹងកិច្ចសហប្រតិបត្តិការពាណិជ្ជ-កម្មទ្វេភាគីកម្ពុជា-ចិន ក្រសួងពាណិជ្ជកម្មកម្ពុជា តាមរយៈក្រុមហ៊ុន ហ្គ្រីន ត្រេដ បានធ្វើការពិភាក្សាជាមួយក្រុមហ៊ុនសាជីវកម្ម COFCO នៃសាធារណរដ្ឋប្រជាមានិតចិន កាលពីថ្ងៃទី ១២ ខែមេសា ឆ្នាំ ២០១៩ លើការរៀបចំអនុស្សរណៈនៃការយោគយល់គ្នា សម្រាប់ពាណិជ្ជកម្មទំនិញអង្ករកម្ពុជា ចូលទៅកាន់ទីផ្សារប្រទេស ចិន។សេចក្តីប្រកាសឱ្យដឹងទៀតថា កិច្ចព្រមព្រៀងដែលគ្រោង

នឹងចុះហត្ថលេខានៅថ្ងៃសៅរ៍ ទី ២៧ ខែ មេសា នេះ គឺភាគីចិនយល់ព្រមទិញអង្ករផ្កាម្លិះ អង្ករក្រអូប អង្ករស និងចុងអង្ករ ពីកម្ពុជាក្នុងបរិមាណ ៤០ម៉ឺនតោន ចាប់ពីខែ សីហា ឆ្នាំ ២០១៩ ដល់ចុងខែ ធ្នូ ឆ្នាំ ២០២០។

កម្ពុជាទទួលបានកូតានាំចេញអង្ករ ៣០ម៉ឺនតោនទៅប្រទេស ចិន ដែលការផ្តល់ជូននេះនឹងបញ្ចប់នៅចុងឆ្នាំ ២០១៩។ ចិនបានផ្តល់កូតាបន្ថែមចំនួន ១០ម៉ឺនតោនទៀតដល់កម្ពុជា ដែលធ្វើឱ្យចំនួននេះកើនដល់ ៤០ម៉ឺនតោន ហើយការអនុវត្តកូតាថ្មីនេះនឹងចូលជាធរមានភ្លាម បន្ទាប់ពីគូភាគីទាំង២ បានអនុវត្តបញ្ចប់ដោយជោគជ័យនូវអនុស្សរណៈដំបូងដែលបានចុះហត្ថលេខាកាលពីដើមខែមករាឆ្នាំ ២០១៨ ស្តីពីការនាំចូលអង្ករចំនួន ៣០ម៉ឺនតោន។ របាយការណ៍របស់លេខាធិការដ្ឋាន សេវាច្រកចេញចូលតែមួយសម្រាប់ការបំពេញបែបបទការនាំចេញអង្ករ បានឱ្យដឹងថា ការនាំចេញអង្កររបស់កម្ពុជានៅក្នុងត្រីមាសទី១ ឆ្នាំ ២០១៩ នេះមានចំនួន ១៧០ ៨២១ តោនកើនឡើងចំនួន៦ ភាគរយពី ១៦១ ១១៥តោនកាលពីឆ្នាំមុន។

សហព័ន្ធស្រូវអង្ករកម្ពុជា គួរយកចិត្តទុកដាក់ជំរុញឱ្យសមាគមន៍ម៉ាស៊ីនកិនស្រូវខិតខំបង្កើនសមត្ថភាពកែច្នៃអង្ករ ឱ្យមានគុណភាពបន្ថែមទៀត សម្រាប់បម្រើឱ្យទីផ្សារអន្តរជាតិ ពិសេសទីផ្សារប្រទេសចិន ដែលមានរហូតដល់៤០ម៉ឺនតោន នាពេលបច្ចុប្បន្ននេះ។ លើសពីនេះទៀត សហព័ន្ធស្រូវអង្ករកម្ពុជា គួរពិគ្រោះយោបល់ជាមួយសមាជិករបស់ខ្លួន ដើម្បីពិនិត្យលើបញ្ហាប្រឈមពីផលប៉ះពាល់ នៃការដាក់វិធានការការពារទីផ្សារអង្កររបស់សហគមន៍អឺរ៉ុប រួចលើកសំណើ ឬសំណូមពរមកក្រុមការងារផ្នែកស្រូវ-អង្ករ នៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន ពិនិត្យ និងរកដំណោះស្រាយតាមការចាំបាច់។

**៤.៣.១.២ វិធានការសម្រាប់បញ្ហាតម្លៃ**

សេចក្តីណែនាំរបស់ក្រសួងកសិកម្មបានឱ្យដឹងថា ដើម្បីលើកកម្ពស់ធុរកិច្ចស្រូវអង្ករ ពិសេសការជួយអន្តរាគមន៍ ទប់ស្កាត់សភាពការណ៍នៃការធ្លាក់ចុះនៃតម្លៃស្រូវ ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ សម្រេចដាក់ចេញនូវវិធានការណែនាំចាំបាច់មួយចំនួនសម្រាប់អនុវត្តបន្ទាន់ដូចខាងក្រោម៖

- អង្គភាពជំនាញក្រោមឱវាទ ក្រសួងត្រូវបន្តការស្រាវជ្រាវបញ្ចេញប្រភេទពូជស្រូវក្រអូបប្រណិត និងផលិតកម្មគ្រាប់ពូជស្រូវក្រអូបសុទ្ធតាមរយៈការផលិតនៅថ្នាក់សហគមន៍ និងក្រុមកសិករផលិតគ្រាប់ពូជ

ធ្វើយ៉ាងណាឱ្យមានគ្រាប់ពូជគ្រប់គ្រាន់ និងតម្លៃសមរម្យ ដើម្បីពង្រីកផលិតកម្មស្រូវក្រអូប។ ជាមួយគ្នានេះស្នើវិស័យឯកជនចូលរួមដាក់ទុនវិនិយោគក្នុងការផលិតគ្រាប់ពូជស្រូវក្រអូប ដែលមានគុណភាពខ្ពស់ស្របតាមស្តង់ដារ និងតម្រូវការទីផ្សារ។

- ពាក់ព័ន្ធនឹងការកាត់បន្ថយថ្លៃដើមផលិតកម្ម ត្រូវជំរុញឱ្យបានខ្លាំងក្លាបន្ថែមទៀត នូវវិធានការបច្ចេកទេសផលិតកម្ម ដែលទទួលបានទិន្នផលខ្ពស់ និងចំណាយតិច រួមជាមួយនឹងការអនុវត្តទំនើបភាវូបនីយកម្មកសិកម្ម។ ជាមួយគ្នានេះ ត្រូវបានពិនិត្យកាត់បន្ថយថ្លៃចំណាយ លើការធ្វើធូបនកម្ម តាមរយៈការបង្កើនចំនួនក្រុមហ៊ុន ដែលមានសមត្ថភាពចូលរួមធ្វើការងារនេះឱ្យបានច្រើនមានការប្រកួតប្រជែង និងយកកម្រៃសេវាទាបជាងមុន។ ក្នុងន័យនេះ អគ្គនាយកដ្ឋានកសិកម្ម ត្រូវពិនិត្យសិក្សាឱ្យបានហ្មត់ចត់ និងជំរុញការងារនេះឱ្យបានឆាប់។
- អ្នកប្រមូលទិញស្រូវ ត្រូវបន្តធ្វើការទំនាក់ទំនងជាមួយធនាគារអភិវឌ្ឍន៍ជនបទ ដើម្បីទទួលបានឥណទាន ប្រមូលទិញស្រូវពីកសិករ សហគមន៍កសិកម្ម និងមិនត្រូវយកហេតុផលនៃការដាក់វិធានការការពារទីផ្សារ របស់សហគមន៍អឺរ៉ុបមកទម្លាក់ថ្លៃទិញស្រូវកសិករឡើយ។ ក្រុមហ៊ុននាំចេញអង្ករត្រូវពិនិត្យនិងធានាគុណភាពអង្ករក្រអូបឱ្យបានសុទ្ធល្អមិនត្រូវលាយបន្លំអង្ករប្រភេទផ្សេង ដែលនាំឱ្យអតិថិជនបាត់បង់ជំនឿលើគុណភាពអង្ករក្រអូបកម្ពុជា។

ក្រៅពីនេះកត្តាមួយចំនួនដែលបានចេញ ដើម្បីធ្វើអន្តរាគមន៍ដើម្បីដោះស្រាយបញ្ហាធ្លាក់ចុះនូវតម្លៃស្រូវអង្ករមានដូចជា៖

- ផ្តល់ហិរញ្ញប្បទានដល់អ្នកប្រមូលទិញស្រូវ និងម្ចាស់រោងម៉ាស៊ីនកិនស្រូវ ដោយពង្រីកកញ្ចប់ថវិកាសម្រាប់ឥណទានពិសេសរហូតដល់ ៥០លានដុល្លារសម្រាប់រដូវប្រមូលផលស្រូវនៅឆ្នាំ២០១៧-២០១៨។
- ជំរុញឱ្យមានមធ្យោបាយដឹកជញ្ជូនទិន្នផលស្រូវរបស់កសិករមកលក់ នៅលើទីផ្សារឱ្យកាន់តែមានភាពងាយស្រួល និងចំណាយតិច ដោយបានស្នើឱ្យមានកិច្ចសហការជាមួយអាជ្ញាធរចុះជួយសម្របសម្រួលផងដែរ។

- សម្រួលច្រកព្រំដែនឱ្យមានការនាំចេញកាន់តែងាយស្រួល និងបញ្ឈប់ការយកលុយតាមផ្លូវក្រៅផ្លូវការ។
- ជំរុញឱ្យមានទីផ្សារនាំចេញទៅក្រៅប្រទេសកាន់តែច្រើនឡើង ស្របទៅតាមស្តង់ដាគុណភាព និងការសម្រួលដល់ការរៀបចំនីតិវិធីដើម្បីនាំចេញជាដើម។
- ការពង្រឹងនីតិវិធី

  ក្នុងការនាំអង្ករចូលពីបរទេសដោយក្រសួងពាណិជ្ជកម្មចេញប្រកាសទាក់ទង នឹងរឹតបន្តឹងនិតិវិធីក្នុងការនាំចូល និងបានរឹតបន្ទឹងបន្ថែមចំពោះបទដ្ឋានច្បាប់ចំពោះក្រុមហ៊ុន ឫអ្នកនាំចូលអង្ករទាក់ទងនឹងអត្តសញ្ញាណនៃអង្ករដោយត្រូវបញ្ជាក់ពី ពតិមាននៅលើសំបកវេចខ្ចាប់ ព្រមទាំងកំណត់រយៈពេលនៃការនាំចូលត្រឹមរយៈពេល០៣ ខែគិតចាប់ពីកាលបរិច្ឆេទនៃការអនុញ្ញាតរបស់ក្រសួង។

### ៤.៣.២ ទិធានការពាក់ព័ន្ធនឹងថ្លៃដើមនៅក្នុងផលិតកម្មស្រូវអង្ករ

រាជរដ្ឋាភិបាល និងក្រសួងពាក់ព័ន្ធគួរបង្កើនយន្តការដើម្បីជួយសម្រួលដល់ការកាត់បន្ថយថ្លៃដើមនៅក្នុងផលិតកម្មស្រូវអង្ករទាក់ទងនឹង កាត់បន្ថយថ្លៃជី និងថ្នាំកសិកម្ម អគ្គិសនី កម្ចី និងថ្លៃមធ្យោបាយនៃការដឹកជញ្ជូន ដោយគួរពិចារណាលើ ៖

- ជំរុញបន្ថែមដល់ក្រុមហ៊ុនផលិតពូជស្រូវ ផលិតពូជស្រូវសុទ្ធដែលមានគុណភាពល្អ ដើម្បីឱ្យទិន្នផលដែលទទួលបានមានភាពល្អប្រសើរ ហើយរោងម៉ាស៊ីកិនស្រូវនឹងទទួលបាន ស្រូវដែលមានគុណភាពល្អដើម្បីកិនជាអង្ករនាំចេញ
- រាជរដ្ឋាភិបាលគួរបន្តផ្តល់ឥណទានពិសេស និងគាំទ្រដល់កសិករក្នុងការទិញពូជស្រូវ ពីព្រោះកន្លងមកឃើញថារាជរដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍ជនបទក៏បានជួយឧបត្ថម្ភទៅលើការទិញពូជស្រូវ ដើម្បីជួយកាត់បន្ថយការចំណាយទៅលើថ្លៃដើមរបស់ ប្រជាកសិករ ហេតុនេះអ្នកវិនិយោគលើរោងម៉ាស៊ីនក៏អាចទិញស្រូវក្នុងតម្លៃទាបជាងមុនផងដែរ
- បង្កើនអន្តរាគមន៍ដែលជួយបន្ថយតម្លៃថ្នាំ និងជីគីមីជាមួយនឹងសកម្មភាពផ្សព្វផ្សាយកសិកម្មនានាដល់កសិករ

ដោយផ្តោតលើការប្រើប្រាស់ជី និងថ្នាំគីមីតាមក្បួនខ្នាតឱ្យមានប្រសិទ្ធភាព និងចំណាយតិច ព្រមទាំងបន្តការមិនយកពន្ធដល់វត្ថុធាតុដើមកសិកម្ម ដើម្បីជួយឱ្យតម្លៃទាប

- សម្រួលដល់ការនាំចូលជីកសិកម្ម ថ្នាំកសិកម្មឱ្យបានលឿន និងមានប្រសិទ្ធភាពជាងមុន នាយកដ្ឋាននីតិកម្មកសិកម្ម ត្រូវសម្រួលបែបបទការនាំចូលជីកសិកម្មថ្នាំកសិកម្ម និងសម្ភារកសិកម្មដទៃទៀតឱ្យកាន់តែប្រសើរជាងមុន។ ជាមួយគ្នានេះ ត្រូវរៀបចំក្រុមការងារបច្ចេកទេសចម្រុះ ចុះពិនិត្យគុណភាពជីគីមីកសិកម្ម និងថ្នាំកសិកម្ម ដើម្បីធានាពីគុណភាពស្របតាមស្តង់ដារកំណត់
- ជំរុញឱ្យមានការដាំដុះ បែបការអនុវត្តកសិកម្មល្អ និងការដាំដុះស្រូវដោយមាននិរន្តរភាព សម្រាប់កសិករក្នុងការ ផ្គត់ផ្គង់ទៅផ្សារពិសេសដែលទទួលបានតម្លៃបន្ថែមខ្ពស់
- បន្តបញ្ចុះថ្លៃការផ្គត់ផ្គង់អគ្គិសនី និងពង្រឹងសមត្ថភាពការផ្គត់ផ្គង់នាវដូវប្រាំងបន្ថែមដើម្បីឆ្លើយតបនឹងតម្រូវការប្រើប្រាស់ តាមរយៈ
- ការឧបត្ថម្ភធន និងកម្ចីសម្រាប់កសិករខ្នាតតូច និងមធ្យម ៖ រាជរដ្ឋាភិបាល គួរពង្រឹងការឧបត្ថម្ភធន និងកម្ចីដល់កសិករខ្នាតតូច និងមធ្យម ដែលមានការប្រាក់ទាបបំផុត តាមរយៈការបង្កើននៃការវិភាជថវិកាជាតិមកដល់វិស័យកសិកម្ម ដើម្បីបង្កលក្ខណៈដល់កសិករក្នុងដាំដុះតាមបែបបច្ចេកទេសសមស្រប និងបន្តបង្កើនការផ្តល់កម្ចីដល់រោងម៉ាស៊ីន និងធ្វើឱ្យប្រសើរឡើងនូវការផ្គត់ផ្គង់ដែលមានតម្លៃទាប និង
- បង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ដើម្បីឱ្យមានការប្រកួតប្រជែង ដែលអាចជួយកាត់បន្ថយថ្លៃក្នុងដឹកជញ្ជូន។

**៤.៣.៣ វិធានការពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធធារាសាស្ត្រ**

ហេដ្ឋារចនាសម្ព័ន្ធ មានសារៈសំខាន់ក្នុងការជំរុញការធ្វើពាណិជ្ជកម្ម ការផលិត និងសក្តានុពលនៃបច្ចេកទេសផលិតកម្ម និងធានាដឹកសិកម្មប្រកបដោយនិរន្តភាព។ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពខ្ពស់

នឹងជួយកាត់បន្ថយចំណាយប្រតិបត្តិការក្នុងការដឹក ជញ្ជូនវត្ថុធាតុដើម និងទិន្នផលទៅកាន់រោងម៉ាស៊ីន និងផលិតផលសម្រេចទៅកាន់ទីផ្សារ។

ការគ្រប់គ្រងហេដ្ឋាសម្ព័ន្ធប្រជាសាស្ត្រចាំបាច់ត្រូវពង្រឹងបន្ថែមនូវ៖

- លើកទឹកចិត្តក្រុមប្រឹក្សាឃុំ ឱ្យចូលរួមគ្រប់គ្រង់បណ្ដាហេដ្ឋារចនាសម្ព័ន្ធប្រជាសាស្ត្ររបស់បណ្ដាឃុំ
- លើកទឹកចិត្តប្រជាកសិករ គ្រប់គ្រងធនធានទឹកដែលជាកាតព្វកិច្ចក៏សំខាន់ក្នុងការរួមចំណែកដល់ការបង្កើនផលិតកម្ម
- ការបង្កើនការចូលរួមរបស់កសិករ និងសហគមន៍កសិកម្មក្នុងការដោះស្រាយបញ្ហានានាដែលទាក់ទងនឹងការប្រើប្រាស់និងថែរក្សាប្រព័ន្ធស្រោចស្រព
- ការបន្តអនុវត្តការងារថវិកាសម្រាប់ការជុសជុលប្រព័ន្ធធារាសាស្ត្រ។

ក្រសួងធនធានទឹក និងឧតុនិយមត្រូវបង្កើនត្រូវបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ពីប្រភពទឹកដែលមានស្រាប់ និងត្រូវពង្រឹងសមត្ថភាពបច្ចេកទេសការរៀបចំ និងជ្រើសរើសគម្រោងវិនិយោគដោយដកស្រង់ពីប្រទេសជិតខាងដែលមានស្ថានភាពភូមិសាស្ត្រ និងលក្ខខណ្ឌអាកាស-ធាតុ ប្រហាក់ប្រហែលគ្នា។ លើសពីនេះទៀតគប្បីគួរពង្រឹងបន្ថែមទៀតនូវ៖

- ប្រើប្រាស់ឱ្យអស់លទ្ធភាពនូវធនធានទឹកដែលមានស្រាប់នៅក្នុងប្រព័ន្ធ និងយកទុកដាក់ដល់ប្រសិទ្ធភាពសេដ្ឋកិច្ចនៃគម្រោង និងធ្វើការវិនិយោគប្រលើឡាយស្រោចស្រពខ្នាតតូច ដើម្បីទាញ ពីទំនប់ និងប្រឡាយមេធំៗដែលមានស្រាប់ឬកំពុងសាងសង់
- លើកទឹកចិត្តដល់ស្ថាប័នមិនមែនរាជរដ្ឋាភិបាល និងសប្បុរសជននានាក្នុងការចូលរួមកសាងប្រឡាយខ្នាតតូច
- ពង្រឹងបន្ថែមសមត្ថភាពស្ថាប័ន របស់ក្រសួងធនធានទឹក និងឧតុនិយមពាក់ព័ន្ធ និងការថែទាំ និងដំណើរការសមាគមន៍អ្នកប្រើប្រាស់ទឹក។

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

បន្ទាប់ពីធ្វើការសិក្សាស្រាវជ្រាវលើប្រធាននេះ យើងខ្ញុំសង្កេតឃើញវិស័យស្រូវអង្ករនៅតែដើរតួនាទីសំខាន់ក្នុងសេដ្ឋកិច្ចកម្ពុជា ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រ អភិវឌ្ឍជនបទ និងលើកកម្ពស់ដល់ការនាំចេញទៅកាន់ទីផ្សារអន្តរជាតិ។ កន្លងមកការវិនិយោគលើវិស័យស្រូវអង្ករនៅក្នុងប្រទេសកម្ពុជាមានភាពខ្វះខាតច្រើន ដែលបណ្តាលឱ្យទិន្នផលស្រូវភាគច្រើនត្រូវនាំចេញទៅបរទេសដើម្បីកែច្នៃ កត្តានេះបង្ហាញពីការបាត់បង់នូវអត្ថប្រយោជន៍សេដ្ឋកិច្ច ជាពិសេសគឺឱកាសការងារជាច្រើននៅក្នុងស្រុក ហេតុនេះទើបរាជរដ្ឋាភិបាល និងដៃគូរអភិវឌ្ឍន៍នានាបាន និងកំពុងយកចិត្តដាក់ក្នុងការបង្កើនផលិតភាពផលិតកម្មស្រូវអង្ករ តាមរយៈការដាក់បញ្ចូលក្នុងគោលនយោបាយនានាដូចជា នយោបាយនាំចេញអង្ករ គោលគោលនយោបាយអភិវឌ្ឍន៍ជាតិ ផែនការអភិវឌ្ឍន៍កសិកម្ម យុទ្ធសាស្ត្រត្រីកោណ និងចតុកោណស្ទើរគ្រប់ដំណាក់កាល ជាមួយនឹងគោលបំណងលើកកម្ពស់ផលិតកម្ម និងជំរុញឱ្យមានការវិនិយោគបន្ថែមលើផលិតកម្មស្រូវអង្ករដូចជា ក្រុមហ៊ុនផលិតពូជស្រូវ រោងម៉ាស៊ីនកិនស្រូវ ឃ្លាំងស្តុក ឡសម្ងួត និងក្រុមហ៊ុននាំចេញជាដើម។

បន្ទាប់ពីមានការដាក់នូវគោលនយោបាយជាច្រើន ពាក់ព័ន្ធនឹងវិស័យស្រូវអង្ករួចមកកំណើនផលិតកម្មស្រូវអង្ករហាក់មានសន្ទុះកើនឡើងគួរឱ្យកត់សម្គាល់ តាមរយៈកំណើននៃការ វិនិយោគ និងកំណើនតម្រូវការនាំចេញផងដែរ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយបច្ចេកទេសកសិកម្មនៅក្នុងប្រទេសកម្ពុជានៅមានកម្រិតដោយសារតែការស្រាវជ្រាវ និងការអភិវឌ្ឍន៍កសិកម្មមិនទាន់ស៊ីជម្រៅ ជាហេតុធ្វើឱ្យឆ្នាំខ្លះកសិផលត្រូវរងផលប៉ះពាល់យ៉ាងខ្លាំងពីបញ្ហាប្រែប្រួលអាកាសធាតុ។ មួយវិញទៀតបញ្ហាហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធធារាសាស្ត្រ ធនធានមនុស្ស និងឱកាសទីផ្សារនៅតែមានកង្វះខាត និងបញ្ហាប្រឈមដែលទាមទារឱ្យរាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធបន្តយកចិត្តទុកដាក់ និងពង្រឹងបន្ថែម។ ទន្ទឹមជាមួយការរីកចម្រើនរបស់ទីផ្សារសាកល ទាមទារឱ្យកម្ពុជាត្រូវអភិវឌ្ឍន៍សមត្ថភាពឱ្យបានគ្រប់គ្រាន់

និងត្រៀមខ្លួនជានិច្ចដើម្បីប្រកួតប្រជែងជាមួយប្រទេសដទៃទៀតនៅក្នុងបរិបទទីផ្សារសេរី។ ក្រៅពីនេះបញ្ហា តម្លៃ ថ្លៃដើម និងហិរញ្ញវត្ថុក៏នៅទាន់អាចឆ្លើយតបនឹងតម្រូវការរបស់ភាគីពាក់ព័ន្ធនៅក្នុងវិស័យស្រូវអង្ករបានល្អប្រសើរនៅឡើយទេ ទោះបីមានការអន្តរាគមន៍ និងជួយជ្រោមជ្រែងពីសំណាក់រាជរដ្ឋាភិបាល និងស្ថាប័ននានាកន្លងមកហើយក្តី។ ការអភិវឌ្ឍធនធានមនុស្ស និងការស្រាវជ្រាវអភិវឌ្ឍន៍កសិកម្ម ស្របតាមទំនើបកម្មក៏ជាកត្តាចាំបាច់ផងដែរ ដើម្បីជួយផលិតកម្មស្រូវអង្ករធានាបាននូវភាពជោគ-ជ័យ។

សរុបសេចក្តីមក ដើម្បីឱ្យវិស័យស្រូវអង្ករនៅកម្ពុជាកាន់តែភាពរីកចម្រើន និងសម្រេចបាននូវការដោះស្រាយបញ្ហាប្រឈមនានា ចាំបាច់ត្រូវមានចូលរួមសហការពីគ្រប់ដៃគូរពាក់ព័ន្ធទាំងអស់ទាំងរាជរដ្ឋាភិបាល និងដៃគូរអភិវឌ្ឍន៍នានា ក្នុងការលើកទឹកចិត្ត និងជំរុញដល់ការវិនិយោគលើវិស័យនេះឱ្យកាន់តែច្រើន។ លទ្ធផលនៃការរីកចម្រើនវិស័យស្រូវអង្ករ ពិតជាបានចូលរួមចំណែកក្នុងកំណើនសេដ្ឋកិច្ចជាតិ ជាពិសេសបានចូលរួមកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពប្រជាជន បើទោះបីជានៅមានចំណុចខ្វះខាត និងឧបសគ្គមួយចំនួនក៏ដោយ។

## ២. អនុសាសន៍

ដើម្បីចូលរួមជំរុញដល់វិស័យស្រូវអង្ករ ដែលជាវិស័យមួយដ៏សំខាន់នៅក្នុងប្រទេសកម្ពុជា ក្នុងការចូលរួមលើកកម្ពស់កម្រិតជីវភាពប្រជាជន ធានាសន្តិសុខស្បៀងក្នុងប្រទេស និងការចូលរួមអភិវឌ្ឍន៍ សេដ្ឋកិច្ចជាតិ ការបង្កើនការវិនិយោគពីវិស័យឯកជនពិតជាមានសារៈសំខាន់ណាស់នៅក្នុងក្របខណ្ឌប្រទេសកំពុងអភិវឌ្ឍន៍ ហេតុនេះហើយទើបរាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធខិតខំយកចិត្តទុកដាក់បង្កើតនូវគោលនយោបាយ ផែនការ យន្តការនានា និងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការបង្កើនឱកាសវិនិយោគសម្រាប់អ្នកវិនិយោគក្នុង និងក្រៅស្រុកលើវិស័យនេះ។ ដោយផ្អែកលើទ្រឹស្តីដែលបានសិក្សា និងស្ថានភាពជាក់ស្តែងនៅក្នុងប្រទេសកម្ពុជាដើម្បីបង្កើនប្រសិទ្ធភាព នៃការអនុវត្តគោលនយោបាយនានាក្នុងការទាក់ទាញ និងជំរុញ

ការវិនិយោគលើវិស័យស្រូវអង្ករ

រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍នានាគួរពិចារណាទៅលើចំណុចមួយចំនួនដូចជា ៖

**គោលនយោបាយទាក់ទងនឹងការវិនិយោគ៖**

បន្តពង្រឹងការអនុវត្តលើគោលនយោបាយដែលអំណោយផលដល់ការវិនិយោគលើវិស័យស្រូវអង្ករ ដោយធានាតម្លាភាពក្នុងការប្រកួតប្រជែង និងការយកចិត្តទុកដាក់ខ្ពស់លើអ្នកវិនិយោគ។

**បន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ៖** ពង្រីកការតភ្ជាប់ផ្លូវទៅកាន់តំបន់សំខាន់ៗ ដើម្បីកាត់បន្ថយថ្លៃ និងពេលវេលាដឹកជញ្ជូន។ ស្តា និងពង្រីកប្រព័ន្ធធារាសាស្ត្រ ដោយធានាបានថាមានទឹកគ្រប់គ្រាន់សម្រាប់ស្រោចស្រព។ ជំរុញការផលិតអគ្គិសនី និងពង្រីកការតភ្ជាប់បណ្តាញអគ្គិសនី ទៅដល់ ទីជនបទដាច់ស្រយាលក្នុងតម្លៃសមស្រប ។

**ឥណទានហិរញ្ញវត្ថុ៖** រាជរដ្ឋាភិបាលគួរបន្តពង្រឹង និងអន្តរាគមន៍បន្ថែមលើវិស័យហិរញ្ញវត្ថុ ជាពិសេសគឺ ការផ្តល់ឥណទាន ដោយសម្រួលលក្ខខណ្ឌនានាក្នុងការផ្តល់កម្ចីជាមួយអត្រាការប្រាក់ទាប។ រាជរាដ្ឋាភិបាល ជាពិសេសធនាគារជាតិគួរបន្តពង្រឹងកិច្ចសហប្រតិបត្តិការ ជាមួយភ្នាក់ងារផ្តល់សេវាហិរញ្ញវត្ថុឱ្យកាន់តែមានប្រសិទ្ធភាព ក្នុងការជំរុញដល់ការផ្តល់កម្ចីជូនប្រជាកសិករ និងវិនិយោគិនក្នុងវិស័យស្រូវអង្ករ។

**ពង្រឹងការស្រាវជ្រាវ និងអភិវឌ្ឍធនធានមនុស្ស៖** ពង្រឹងការស្រាវជ្រាវបច្ចេកទេសកសិកម្មទំនើប និងបណ្តុះបណ្តាលធនធានមនុស្សលើវិស័យកសិកម្ម ក៏ដូចជាសិក្សាពីបទពិសោធន៍របស់ប្រទេសនានាដែលមានភាពជោគជ័យលើការវិនិយោគវិស័យកសិកម្ម ជាពិសេសគឺស្រូវអង្ករ។ ស្ថាប័នរដ្ឋ និងឯកជននានាដែលដើរតួនាទីជាបណ្តុះបណ្តាលធនធានមនុស្ស គួរតែបន្តបន្ថែមការពង្រីក និងពង្រឹងមុខវិជ្ជាលើវិស័យស្រូវអង្ករនេះឱ្យកាន់តែផុសផុលឡើងដូចជា មុខវិជ្ជាSupply Chainជាដើម។ ជំរុញ និងលើកទឹកចិត្តខ្ពស់ លើការបង្កើតក្រុមស្រាវជ្រាវ និងសិក្សាលើវិស័យស្រូវអង្ករដូចជា គម្រោង បច្ចេកទេស និងការអនុវត្តឱ្យចំគោលដៅដើម្បីឆ្លើយតបនឹងការប្រកួតប្រជែងនាពេលអនាគត និងបង្កើនទំនាក់ទំនងជាមួយអ្នកបច្ចេកទេសជាតិ និងអន្តរជាតិ។

**ការគ្រប់គ្រងហានិភ័យ៖** ធានាដល់ការអនុវត្តផែនការ និងយន្តការនានាពាក់ព័ន្ធនឹងវិស័យស្រូវអង្ករឱ្យបានខ្ជាប់ខ្ជួន ប្រកបដោយប្រសិទ្ធិភាព ក៏ដូចជាពង្រឹងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃចំពោះការអនុវត្តលើផែនការទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

រាជរដ្ឋាភិបាលគួរមានការឧបត្ថម្ភធនធានារ៉ាប់រ៉ងករណីមានការបរាជ័យទីផ្សារ និងជំរុញឱ្យមានបង្កើតកិច្ចសន្យាច្បាស់លាស់រវាងកសិករ និងក្រុមហ៊ុនដើម្បីជៀសវាងហានិភ័យពាក់ព័ន្ធនឹងតម្លៃ គុណភាព បរិមាណ និងពេលវេលានៃការដោះដូរ។ លើសពីនេះ គួរបន្តបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការស្វែងរក និងពង្រីកទីផ្សារ រួមទាំងវិភាគពីទំហំថ្លៃដើម និងឱកាសសម្រាប់បរិយាកាសនៃការធ្វើពាណិជ្ជកម្មវិស័យស្រូវអង្ករដើម្បីធានាទំនុកចិត្តសម្រាប់អ្នកវិនិយោគ។ ជាក់ស្តែង ដើម្បីឆ្លើយតបនឹងកាប្រែប្រួលរបស់ទីផ្សារអឺរ៉ុប កម្ពុជាគួរត្រៀមខ្លួនដោយពង្រឹងស្ថិរភាពនៃការផលិត ការផ្គត់ផ្គង់ការបង្កើនទំនើបកម្មក្នុងផលិតកម្មនិងស្វែងរកឱកាសទីផ្សារបន្ថែម។

# ឯកសារយោង

## ឯកសារជាភាសាខ្មែរ


១. ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, ឯកសារគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ អនុម័តដោយគណៈរដ្ឋមន្ត្រីនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០

២. រាជរដ្ឋាភិបាលកម្ពុជា, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ អនុម័តដោយរដ្ឋសភា ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៤

៣. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្ម២០១៤-២០១៨, មិថុនា ២០១៥

៤. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, គោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា, ២០១៥

៥. ច្បាប់ស្តីពីសហគមន៍កសិកម្ម, លេខ នស/រកម/០៦១៣/០០៨, ៩ ឧសភា ២០១៣

៦. សហព័ន្ធស្រូវអង្ករកម្ពុជា, ប្រតិបត្តិពត៌មានលេខ៦, ២០១៧

៧. វិសោធនកម្មច្បាប់ស្តីពីការវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ(១៩៩៤ និង ២០០៣) អនុម័តដោយរដ្ឋសភាថ្ងៃទី ខែកុម្ភៈ ឆ្នាំ២០០៣

៨. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ផែនការសកម្មភាពសម្រាប់អនុវត្តឯកសារគោលនយោបាយស្តីពី ការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ, មេសា ២០១១

៩. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, គោលយោបាយដីធ្លី , សីហា ២០១៥

១០. រាជរដ្ឋាភិបាលកម្ពុជា, យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ , កញ្ញា ២០១៨

១១. លេខាធិការដ្ឋានច្រកចេញចូលតែមួយសម្រាប់បំពេញបែបបទនាំចេញអង្ករ, របាយការណ៍ស្ថានភាពនៃការនាំចេញអង្ករកម្ពុជា, ២០១៣, ២០១៥, ២០១៧

១២. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ព្រឹត្តិបត្រស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រចាំត្រីមាសទី៤ ឆ្នាំ២០១៨, មីនា ២០១៩

១៣. ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, ព្រឹត្តិបត្រតាមដានវិស័យស្រូវអង្ករកម្ពុជាលេខ២, មីនា ២០១៨

១៤. ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ,វេទិកាស្តិពីពាណិជ្ជកម្មស្រូវ , ២៥ កញ្ញា ២០១៧

១៥. វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា, របាយការណ៍សង្ខេបសមិទ្ធផលនៃការស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាកសិកម្ម ឆ្នាំ២០១៥ និងទិសដៅសម្រាប់ឆ្នាំ ២០១៦-២០១៨, ២៥ មីនា ២០១៦

១៦. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១៥-២០១៦ និងទិសដៅការងារសម្រាប់ឆ្នាំ ២០១៦-២០១៧, ឧសភា ២០១៦

១៧. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, របាយការណ៍ស្តីពីសភាពការណ៍កសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ ប្រចាំខែឧសភា ឆ្នាំ២០១៩ និងទិសដៅអនុវត្តបន្ត, ២០១៩

## ឯកសារជាភាសាបរទេស

១៨. OECD, Policy Framework for Investment in Agriculture, 2014

១៩. IFC and SNEC, Cambodia Rice Export Potential and Strategies, 2015

២០. IISD, Finanacing for Agriculture, September 2015

២១. FOA, Agricultural Investment Funs for Developing Countries, 2010

២២. Mohammad S.ANWER and R.K. Sompath, Investment and economic growth, July 1999

២៣. Robyn Johston, Thuon Try and Sanjiv De Silva, AWM in Cambodia, June 2013

២៤. Saifullah Syed and Masahiro Miyazaho, Promoting Investment In Agriculture For increased production and productivity, 2013

## ឯកសារពីគេហទំព័រ

២៥. http://www.crf.org.kh

២៦. http://web.maff.gov.kh

២៧. https://www.mef.gov.kh

២៨. https://www.adb.org

២៩. https://www.investopedia.com

៣០. https://www.intelligenteconomist.com

៣១. https://www.economicshelp.org

៣២. https://www.iisd.org

៣៣. https://wmc.org.kh

៣៤. https://futurism.media

៣៥. https://www.rdb.com.kh

៣៦. https://amis.org.kh

៣៧. https://www.tradingeconomic.com

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ ទស្សនទាននៃការស្រាវជ្រាវលើយន្តការទាក់ទាញការវិនិយោគលើដំណាំស្រូវ



ឧបសម្ព័ន្ធទី២៖ ផ្ទៃដីដាំដុះ និងបរិមាណប្រមូលផលស្រូវសរុបចន្លោះឆ្នាំ ២០០៩-២០១៨




ឧបសម្ព័ន្ធទី៣៖ ផ្ទៃដីដាំដុះ បរិមាណអង្ករ និងស្រូវសល់របស់កម្ពុជាចន្លោះឆ្នាំ ២០០៨-២០១៥



ឧបសម្ព័ន្ធទី៤៖ ទិសដៅនៃការនាំចេញស្រូវអង្ករកម្ពុជាក្នុងរយៈពេល៦ខែដើមឆ្នាំ២០១៧

| ល.រ | ប្រទេសទិសដៅ | បរិមាណនាំចេញសរុប(គិតជាតោន) |
|---|---|---|
| | សមាជិកសហគមន៍អឺរ៉ុប(EUROPEAN UNION) | |
| ១ | France | ៣៧,៣២១ |
| ២ | Poland | ២៥,៦៣៩ |
| ៣ | United Kingdom | ២១,២៦៩ |
| ៤ | Netherland | ១៤,៨៩៤ |
| ៥ | BelGium | ១១,៤៣២ |
| ៦ | Czech Republic | ៩,៩០៧ |
| ៧ | Italy | ៧,០៩៩ |
| ៨ | Germany | ៥,៩០៩ |
| ៩ | Spain | ៤,១១០ |
| ១០ | Sweeden | ២,៩៣១ |
| ១១ | Portugal | ២,៨៣៧ |
| ១២ | Lativia | ២,២៧៥ |
| ១៣ | Denmark | ១,៨៩២ |
| ១៤ | Greece | ១,៤១៦ |
| ១៥ | Croatia | ១,០២៥ |
| ១៦ | Lithuania | ៩៤១ |
| ១៧ | Austria | ៦៦៧ |
| ១៨ | Hungary | ៦៦៦ |
| ១៩ | Slovenia | ៤៨០ |
| ២០ | Romnia | ៤២៥ |
| ២១ | Cyprus | ៣៩៦ |
| ២២ | Estonia | ២៧៥ |
| ២៣ | Finland | ២៥០ |
| ២៤ | Ireland | ៨២ |
| ២៥ | Malta | ៧២ |
| | **Sub-Total** | **១៦៤,២១១=៤៤%** |
| | សមាជិកអាស៊ាន(ASIAN MEMBER STATE) | |
| ១ | Malaysia | ៨,១៣០ |

| | | |
|---|---|---|
| ២ | Brunie | ៤,៥៧៨ |
| ៣ | Vietnam | ២,២២០ |
| ៤ | Singapore | ១,៨៥០ |
| | **Sub-Total:** | **១៤, ៥៥៨=៥.០៥%** |
| ទិសដៅផ្សេងទៀត (OTHER DESTINATIONS) | | |
| ១ | China | ៩៤,៧២០ |
| ២ | Gabon | ៨,៨៨២ |
| ៣ | South Africa | ៣,០២៥ |
| ៤ | Turkey | ២,៥០២ |
| ៥ | Hong Kong | ១,៦៧៩ |
| ៦ | Russian Fed | ១,២៨៩ |
| ៧ | Bulgaria | ១,១៥០ |
| ៨ | Senegal | ៧០០ |
| ៩ | USA | ៦០២ |
| ១០ | Iraq | ៥៣៧ |
| ១១ | Mayotte | ៥១៧ |
| ១២ | Newzealand | ៤៤៨ |
| ១៣ | Australia | ២៧៤ |
| ១៤ | Saudi Arabia | ២៦៨ |
| ១៥ | Congo | ២៤០ |
| ១៦ | Canada | ១៨៩ |
| ១៧ | Taiwan | ១២០ |
| ១៨ | Macau | ១០៥ |
| ១៩ | Kenya | ១០០ |
| ២០ | UKraine | ៤៩ |
| ២១ | Camaroon | ៤៨ |
| ២២ | Madacascar | ២៥ |
| ២៣ | Namibia | ២៥ |
| ២៤ | Ghana | ២៥ |
| ២៥ | Reunion | ២៤ |
| ២៦ | Moldova | ២៤ |
| ២៧ | Korea | ៦ |

| | |
|---|---|
| Sub-Total: | ១១៩, ៧៩៣=៤១.៥១% |
| Grand-Total: | ២៨៨,៥៦២=១០០% |

ឧបសម្ព័ន្ធទី៥៖ ក្រុមហ៊ុន និងបរិមាណដែលបាននាំចេញអង្ករពីកម្ពុជា៦ខែដើមឆ្នាំ២០១៧, គិតជាតោន

| ល.រ | ក្រុមហ៊ុននាំចេញងង្ករ | បរិមាណនាំចេញអង្ករ | |
|---|---|---|---|
| | | (គិតជាតោន) | (គិតជា%) |
| ១ | Cristal Rice (Kampuchea) Co., Ltd. | ៣០,៩៦១ | ១០.៧៣ |
| ២ | Baitang Kampuchea) Co., Ltd. | ២៧,៤១៥ | ៩.៥០ |
| ៣ | Apsara Rice (Cambodia) Co., Ltd. | ២៣,៧៣៤ | ៨.២២ |
| ៤ | Khmer Foods Group Co., Ltd. | ២១,៨៣១ | ៧.៥៧ |
| ៥ | Amru Rice (Cambodia) Co., Ltd. | ១៩,៦៦៣ | ៦.៨១ |
| ៦ | Golden Rice (Cambodia) Co., Ltd. | ១៦,៧៧៤ | ៥.៨១ |
| ៧ | City Rice Import Co.,Ltd. | ១៥,០៤៦ | ៥.២១ |
| ៨ | Nikolin Investment Co., Ltd. | ១៤,៣៧៥ | ៤.៩៨ |
| ៩ | Kol Veasna Investment Co., Ltd. | ១១,៦៧៥ | ៤.០៥ |
| ១០ | Signatures of Asia Co., Ltd. | ៩,៩៥៧ | ៣.៤៥ |
| ១១ | Primalis Corporation Ltd. | ៨,៨៨៤ | ៣.០៨ |
| ១២ | Green Trade Company | ៨,២០០ | ២.៨៤ |
| ១៣ | International Rice Trading (Cambodia) Co., Ltd | ៧,៩៩២ | ២.៧៧ |
| ១៤ | Golden Daun Keo Rice Mill Co., Ltd | ៦,៦៣៨ | ២.២៧ |
| ១៥ | W.K.R Trading Co., Ltd. | ៦,៥៣៩ | ២.២៦ |
| ១៦ | T.O.T (Trust Our Trade) Co., Ltd. | ៦,៥០៧ | ២.២៥ |
| ១៧ | Indochina Rice Mill Limited | ៥,៦៩៣ | ១.៩៧ |
| ១៨ | Sscorp(Cambodia) Co., Ltd. | ៤,៥១១ | ១.៥៦ |
| ១៩ | Lor Eak Heng Sek Meas Rice Co., Ltd. | ៤,២១៩ | ១.៤៦ |
| ២០ | Soma Trading Company Limited. | ៤,០២៤ | ១.៣៩ |
| ២១ | Herba (Cambodia) Co., Ltd. | ៣,៧០៩ | ១.២៩ |
| ២២ | Battambang Rice Investment Co., Ltd. | ២,៧២២ | ០.៩៤ |
| ២៣ | Thmor Korl Rice Import Export Co., Ltd. | ២,៥៦៩ | ០.៨៩ |
| ២៤ | White Gold Import Export Co., Ltd. | ២,០៤៤ | ០.៧១ |

| | | | |
|---|---|---|---|
| ២៥ | Pheng Leang Seng Import Export | ២,០២៣ | ០.៧០ |
| ២៦ | Hung Hiep (Cambodia) Co., Ltd. | ១,៨៥៥ | ០.៦៤ |
| ២៧ | CK Rice Trading Co., Ltd. | ១,៨០២ | ០.៦២ |
| ២៨ | Golden Star Rice Mill and Import Export Co., Ltd. | ១,៦៣៥ | ០.៥៧ |
| ២៩ | Sary Kunthea | ១,៥០០ | ០.៥២ |
| ៣០ | Mekong Oryza Trading Co., Ltd. | ១,៣០២ | ០.៤៥ |
| ៣១ | Amru and Hanwha International Co., Ltd. | ១,២៣១ | ០.៤៣ |
| ៣២ | Commodity In Focus Co., Ltd. | ១,១២៥ | ០.៣៩ |
| ៣៣ | Boost Rice Battambang Ltd. | ១,១២៣ | ០.៣៩ |
| ៣៤ | Fed Rice Battambang Ltd. | ៩៥៧ | ០.៣៣ |
| ៣៥ | Lim Kheang Hout Import Export Co., Ltd. | ៨២៧ | ០.២៩ |
| ៣៦ | Oversea Foods Import Export Co., Ltd. | ៧៤៣ | ០.២៦ |
| ៣៧ | Clobal Ecological Rice (Cambodia) Co., Ltd | ៥៨០ | ០.២០ |
| ៣៨ | Capital Food Investment Import Export Co., Ltd. | ៥៤៨ | ០.១៩ |
| ៣៩ | Ou Tong Development (Cambodia) Co., Ltd. | ៤៧៥ | ០.១៦ |
| ៤០ | Phou Poy Development Import Export Co., Ltd. | ៤៦៩ | ០.១៦ |
| ៤១ | Cam-Grain Development Co., Ltd. | ៤៦៥ | ០.១៦ |
| ៤២ | Cambodia Diamand Seafood and Agriculture Co., Ltd. | ៤៤៨ | ០.១៦ |
| ៤៣ | Cambodian II Shine International Trade Co., Ltd. | ៣៥៥ | ០.១២ |
| ៤៤ | Angkor Kasekam RoongRoeung Co., Ltd. | ៣៣៥ | ០.១២ |
| ៤៥ | Domnak Teuk Group Co., Ltd. | ៣១៥ | ០.១១ |
| ៤៦ | Kampong Thom Rice Mill Limited | ៣០១ | ០.១០ |
| ៤៧ | Palm Rice Co., Ltd. | ២៨៤ | ០.១០ |
| ៤៨ | Chhun Thom Rice Mill | ២៥០ | ០.១០ |
| ៤៩ | Cambodian Organic Farm Enterprise (c.o.f.e) Co., Ltd. | ២៤៤ | ០.០៩ |
| ៥០ | Avic Enegy (Cambodia) Co., Ltd. | ២២០ | ០.០៨ |
| ៥១ | Jasmine Rice Mill Factory Co., Ltd. | ១៩៨ | ០.០៨ |
| ៥២ | Aromarice Import Export Co., Ltd. | ១៤០ | ០.០៧ |
| ៥៣ | T.M.K Investment Co., Ltd. | ១២១ | ០.០៥ |
| ៥៤ | Vong Bunheng Import Export Co., Ltd. | ១១៤ | ០.០៤ |
| ៥៥ | Mufavor International (Cambodia) INC. | ១១១ | ០.០៤ |
| ៥៦ | V-Lotte Trading Co., Ltd. | ១០០ | ០.០៤ |

| | | | |
|---|---|---|---|
| ៥៧ | Uni-Natral Co., Ltd. | ៨៨ | ០.០៣ |
| ៥៨ | Bayon Jasmine Rice Co., Ltd. | ៧២ | ០.០២ |
| ៥៩ | Eang Heang Import Export Co., Ltd. | ៧២ | ០.០២ |
| ៦០ | Tech Soon Agro Industry Co., Ltd. | ៧២ | ០.០២ |
| ៦១ | LK International Group Plc. | ៦៧ | ០.០២ |
| ៦២ | Xiangshan Rice (Cambodia) Co., Ltd. | ៥៧ | ០.០២ |
| ៦៣ | Hua Feng Yuan Rice Vermicelli (Cambodia) | ៥៤ | ០.០២ |
| ៦៤ | LBN Angkar (Kampuchea) Co., Ltd. | ៥០ | ០.០២ |
| ៦៥ | Ngy Heng Droup Co., Ltd. | ៤៨ | ០.០២ |
| ៦៦ | Great Green & Gre Ment Asia Pacific (Cam) Co., Ltd | ៤៦ | ០.០២ |
| ៦៧ | Khun Ngoun Rice Export Co., Ltd. | ៤០ | ០.០១ |
| ៦៨ | Milin Rice (Cambodia) Import Export Co., Ltd. | ៣០ | ០.០១ |
| ៦៩ | Bayond Cereal Co., Ltd. | ២៥ | ០.០១ |
| ៧០ | Cerebrum Trading Co., Ltd. | ២៥ | ០.០១ |
| ៧១ | Rice Paddy Fields (Cambodia) Co., Ltd. | ២៥ | ០.០១ |
| ៧២ | M.S.C.K Trading Limited | ២៣ | ០.០១ |

ឧបសម្ព័ន្ធទី៦៖ រោងម៉ាស៊ីនកិនស្រូវ និងកែច្នៃអង្កររបស់កម្ពុជាចំនួន២៦
ដែលត្រូវបានអនុញ្ញាតិឱ្យនាំចេញទៅប្រទេសចិន (ថ្ងៃទី០៨ មករា ២០១៧)

| ល.រ | ឈ្មោះរោងម៉ាស៊ីនកិនស្រូវ និងកែច្នៃអង្ករកម្ពុជា |
|---|---|
| ១ | Amru Rice Cambodia Co.,LTD |
| ២ | ក្រុមហ៊ុន Apsara Rice Cambodia Co.,LTD |
| ៣ | Baitnag (Kampuchea) Plc |
| ៤ | Battambang Rice Investment Co., Ltd |
| ៥ | Capital Food Investment Imp-Exp Co.,ltd |
| ៦ | City Rice Import Export Co.,Ltd |
| ៧ | Crystal Rice (Kampuchea) Co.,Ltd,Chhum Thom Rice Mill |
| ៨ | Chhum Thom Rice Mill |
| ៩ | Eang Heng Import Export Co.,Ltd |
| ១០ | Golden DaunKeo Rice Mill Co.,Ltd |

| | |
|---|---|
| ១១ | Golden Rice Cambodia Co.,Ltd |
| ១២ | Golden Star Rice Mill & Im-Exp Co.,Ltd |
| ១៣ | Great Grain &Garment Asia Pacifice Cambodia Co.,Ltd |
| ១៤ | Green Trade Company |
| ១៥ | Guohoung Cambodia Industry Co., Ltd |
| ១៦ | Indo China Rice mill Limited |
| ១៧ | Khmer Food Group Co.,Ltd |
| ១៨ | LorEakHeng SekMeas Rice Co.,Ltd |
| ១៩ | Nicoline Investment Co.,Ltd |
| ២០ | Plam Rice Co.,Ltd, Sarykunthear |
| ២១ | Sarykunthear |
| ២២ | Sokkeo import Export Co.,Ltd |
| ២៣ | Thmorkot Rice Import Export Co.,Ltd |
| ២៤ | TOT (Trust Our Trade) Co.,Ltd |
| ២៥ | Vong Bun Heng Import Co.,Ltd |
| ២៦ | White Golde Import Export Co.,Ltd |

ឧបសម្ព័ន្ធទី៧៖ ចំនួនសហគមន៍កសិកម្មដែលត្រូវបានបង្កើតនៅតាមបណ្តាឆ្នាំ គិតត្រឹមឆ្នាំ២០១៨






ឧបសម្ព័ន្ធទី៨៖ សមាជិកសរុបរបស់សហព័ន្ធស្រូវអង្ករកម្ពុជា (ស.អ.ក) គិតត្រឹមឆ្នាំ២០១៩

| ល.រ | ឈ្មោះសមាជិក |
|---|---|
| ១ | 365 Moving Co.,Ltd |
| ២ | 7NG Union Rice Co.,Ltd |
| ៣ | AGRIBUDDY Co.,Ltd |
| ៤ | Amru Rice (Cambodia) Co., Ltd |
| ៥ | Amtak Thebtey Angricultural Cooporation |
| ៦ | Angkor Kasekam Roong Roeung Co.,Ltd |
| ៧ | ANZ Royal Bank (Cambodia)., Ltd |
| ៨ | Apsara Rice (Cambodia) Co.,Ltd |
| ៩ | AQIP SEED Co.,Ltd |
| ១០ | ASIA COMMERCE VERTS (CAMBODIA) CO.,LTD |
| ១១ | Asia Diamond Rice Import Export Co., Ltd |
| ១២ | Baitang (Kampuchea) Plc. |
| ១៣ | Battambang Rice Investment Co.,Ltd |
| ១៤ | Bayon Cereal Co.,Ltd |
| ១៥ | Boost Riche(Cambodia)Co.,Ltd |
| ១៦ | Boromey Vuthy Rice Miller |
| ១៧ | Bou Sokha Rice Mill |
| ១៨ | Bou Sokkhai Rice Mill |
| ១៩ | Bred Bank (Cambodia) PLC |
| ២០ | Brightway Group Co.,Ltd |
| ២១ | Buhler (CAMBODIA) Co.,Ltd |
| ២២ | Bun Hor Rice Mill |
| ២៣ | Bureau Veritas (Cambodia) Limited |
| ២៤ | CAM MJ AGRICULTURAL PARK Co.,Ltd |

| | |
|---|---|
| ២៥ | CAMBODIA LI SHINE INTERNATIONAL TRADE |
| ២៦ | Cambodian Federation Association of Rice Producer |
| ២៧ | Cambodian Organic Farm Enterprise (C.O.F.E) Co.,Ltd |
| ២៨ | Capital Food Investment Import Export Co.,Ltd |
| ២៩ | CaviFoods Company Co.,Ltd |
| ៣០ | CCIC (Cambodia) |
| ៣១ | Champa Preyphdoa Agricultural Cooperative( CPAC) |
| ៣២ | Chamroeun Chey Agriculture Community |
| ៣៣ | Chamroeun Meanchey Agricultural Cooperative |
| ៣៤ | Chamroeun Phal Rang Kesey Agriculture Cooperation |
| ៣៥ | Chan Kok Lun rice Mill |
| ៣៦ | Chang Korn Meng Rice Mill |
| ៣៧ | Chao Lor Suong Rice Mill |
| ៣៨ | Chao Seav Rice Mill |
| ៣៩ | Chea Hap Rice Mill |
| ៤០ | Cheav Khouy Rice Mill |
| ៤១ | Cherng Koun Chorkchey Angricultural Cooperation |
| ៤២ | Chheang Heng Rice Mill |
| ៤៣ | Chheung Bun Ham Rice Mill |
| ៤៤ | Chhith Bounthan Rice Mill |
| ៤៥ | Chhnal Mom Samki Rongroeun Agriculture cooperation |
| ៤៦ | Chhorng Din Rice Mill |
| ៤៧ | Chhueng Born Rice Mill |
| ៤៨ | Chhun Thom Rice Mill |
| ៤៩ | Chhuon Vorn Rice Mill |
| ៥០ | CHIEF (Cambodia) Specialized Bank Plc |

| | |
|---|---|
| ៥១ | Chin Van Rice Mill |
| ៥២ | Chouk Tep Rice Mill |
| ៥៣ | Chrou  Thol Rice Mill |
| ៥៤ | Chum Lay Rice Mill |
| ៥៥ | Chuoy Sam Rice Mill |
| ៥៦ | ChyKraeng Sammky Agriculture Development Community |
| ៦៧ | City Rice Import Export Co.,Ltd |
| ៥៨ | CK Rice Trading Co., Ltd |
| ៥៩ | CMA CGM Cambodia Co.,Ltd |
| ៦០ | Control Union (Cambodia) Co.,Ltd |
| ៦១ | Cool Transportation & Logistic Co.,Ltd |
| ៦២ | Crystal Rice (Kampuchea) Co., Ltd |
| ៦៣ | CWT Commodities (Cambodia) Co.,Ltd |
| ៦៤ | Domnak Teuk Group Co., Ltd |
| ៦៥ | Dy Chhay Rice Mill |
| ៦៦ | Eang Heang Import Export Co., Ltd |
| ៦៧ | Ear Chhaiy Yin Rice Mill |
| ៦៨ | Eath LeangKheng Rice Mill |
| ៦៩ | Eath Leangseng Rice Mill |
| ៧០ | E-Freight Solution Inc |
| ៧១ | Eng Dypo Aphivath Co.,Ltd |
| ៧២ | Eng Hok Rice Mill |
| ៧៣ | Eng Sorng Rice Mill |
| ៧៤ | Eng Sour Rice Mill |
| ៧៥ | Eng Van Mao Rice Mill |
| ៧៦ | Export Trading Commodities (Cambodia) Limited |

| | |
|---|---|
| ៧៧ | Fang Ly Rice Mill |
| ៧៨ | Fang Vun Rice Mill |
| ៧៩ | Fang Vy Rice Mill |
| ៨០ | Farmer and Natural Networking Association |
| ៨១ | Farmer and Natural Networking Federation |
| ៨២ | Fed Rcie Battambang Ltd |
| ៨៣ | Federal of Associations For Small and Medium Enterprises of Cambodia |
| ៨៤ | First Packaging Partner Co., Ltd |
| ៨៥ | Global Ecological Rice (Cambodia) Co.,Ltd |
| ៨៦ | Golden Daun Keo Rice Mill Co.,Ltd |
| ៨៧ | Golden Rice (Cambodia) Co.,Ltd |
| ៨៨ | Golden Star Rice Mill and Import Export Co.,Ltd (Pkay Meas Rice Mill) |
| ៨៩ | Great & Grain Garment Asia Pacific (Cambodia) Co.,Ltd |
| ៩០ | Green Rice Agriculture Development |
| ៩១ | Green Trade Company |
| ៩២ | Guohong (Cambodia) Industry Co.,Ltd |
| ៩៣ | Hang Pi Phally Sokha Rice Mill |
| ៩៤ | Hay Chuong Rice Mill |
| ៩៥ | Heng Heang Rice Mill |
| ៩៦ | Heng Horm Rice Mill |
| ៩៧ | Heng Huch Rice Mill |
| ៩៨ | Heng Lay Rice Mill |
| ៩៩ | Heng Seang Hak Rice Mill |
| ១០០ | Herba (Cambodia) Co.,Ltd |
| ១០១ | High Level Logistics (Cambodia) C.,Ltd |
| ១០២ | Hoeng Siva Rice Mill |

| | |
|---|---|
| ១០៣ | Hong Ly Rice Mill |
| ១០៤ | Hout Chheng  Ngoun Rrice Mill |
| ១០៥ | HS Rice Co.,Ltd |
| ១០៦ | Hung Hiep (Cambodia) Co.,Ltd |
| ១០៧ | Huong Leng Rice Mill |
| ១០៨ | Huong Long Rice Mill |
| ១០៩ | Huot Ching Rice Mill |
| ១១០ | Huy Eang Rice Mill |
| ១១១ | Idemitsu Saison Microfinance (Cambodia) Plc |
| ១១២ | Im Eangkry Co.,LTD |
| ១១៣ | Indochina Rice Mill Limited |
| ១១៤ | International Rice Trading (Cambodia)Co.,LTD |
| ១១៥ | Jasmine Rice  Mill Factory Co., Ltd |
| ១១៦ | Jing Mi Rice Mill Co.,Ltd |
| ១១៧ | Ka Vannara Rice Mill |
| ១១៨ | Kakoh Agriculture Cooperative (KKAC) |
| ១១៩ | Kampeng Soksen Sambo Agricultural Cooperative |
| ១២០ | Kampongthom Rice Mill Limited |
| ១២១ | Kao My Rice Mill |
| ១២២ | Kao Nget Rice Mill |
| ១២៣ | Kasikor Samki Rongroeung Agricultural Cooperative |
| ១២៤ | Keat Sothea Rice Mill |
| ១២៥ | Keopor Samki Chamroeu Phal Agricultural Cooperative |
| ១២៦ | Khean Kav Rice Mill |
| ១២៧ | Kheng  Hout Rice Mill |
| ១២៨ | Khieu Techsreang Rice Mill |

| | |
|---|---|
| ១២៩ | Khiev Khea Rice Mill |
| ១៣០ | Khiev Khean Rice Mill |
| ១៣១ | Khmer Foods Group Co., Ltd |
| ១៣២ | Khum Wat Tamem Angricultural Cooporation |
| ១៣៣ | Khun Nguon Rice Export Co.,Ltd |
| ១៣៤ | Khuth Thanh Rice Mill |
| ១៣៥ | Khy Thay Corperation Co., Ltd |
| ១៣៦ | Kim Se Rice Mill |
| ១៣៧ | Kim Sun Rice Mill |
| ១៣៨ | Kim Ty Rice Mill |
| ១៣៩ | Klakrahoem Meanchey Agricultural Cooperative |
| ១៤០ | Kol Veasna Investment Co.,Ltd |
| ១៤១ | Kong Hour Rice Mill import export Co., Ltd |
| ១៤២ | Kor 1 (Hort Ngun Hong) Rice Mill |
| ១៤៣ | Kors krlor Pheakdey reaksmey Rongroeun Angricultural Cooporation |
| ១៤៤ | Krabao Promtep Agriculture Development Community |
| ១៤៥ | Laov Fak Rice Mill |
| ១៤៦ | LBN Angkar (Kampuchea) Co.,Ltd |
| ១៤៧ | Lerk Kompos Kasikor Agricultural Cooperative |
| ១៤៨ | Ley Chhinh Rice Mill |
| ១៤៩ | Lim Chhunly Rice Mill |
| ១៥០ | Lim Heng Leap Trading Co.,Ltd |
| ១៥១ | Lim Kheang  Hout Import Eport Co.,Ltd |
| ១៥២ | Loeung Chhoy Rice Mill |
| ១៥៣ | Long Chhengmeng Rice Mill |
| ១៥៤ | Lor Eak  Heng Sek Meas Rice Co.,Ltd |

| | |
|---|---|
| ១៥៥ | Loran Group (Plc) |
| ១៥៦ | Loun Cheng Leang Rice Mill |
| ១៥៧ | Luon Kun Rice Mill |
| ១៥៨ | Ly Chhean Rice Mill |
| ១៥៩ | Mao Kuch Rice Mill |
| ១៦០ | Mao Siphorn Rice Mill |
| ១៦១ | Meas Chheng Rice Mill |
| ១៦២ | Meas Sor (Kampuchea) Co.,Ltd |
| ១៦៣ | Mei Jing Rice (Cambodia) Co.,Ltd |
| ១៦៤ | Mekong Agro (KH) Industries Limited |
| ១៦៥ | Mekong Oryza Trading Co.,Ltd |
| ១៦៦ | Men Sarun Import Export & Construction Co.,Ltd |
| ១៦៧ | Milin Rice (Cambodia) Import Export Co.,Ltd |
| ១៦៨ | Mom Sophal Rice Mill |
| ១៦៩ | Mongkol Phum SalaTrav Angricultural Cooporation |
| ១៧០ | Muoy Leang  Rice Mill |
| ១៧១ | Neng Po Rice Mill |
| ១៧២ | Ngauv Huong Rice Mill |
| ១៧៣ | Ngeap Chiv Rice Mill |
| ១៧៤ | Ngin Beang Rice Mill |
| ១៧៥ | Ngov Meng Rice Mill |
| ១៧៦ | Nguon Hong Rice Mill |
| ១៧៧ | Nhek Sarith Rice Mill |
| ១៧៨ | Nikoline Investment Co.,Ltd |
| ១៧៩ | Norm Srim Rice Mill |
| ១៨០ | Noyakong Group Co., Ltd |

| | |
|---|---|
| ១៨១ | Om Seth Than Rice Mill |
| ១៨២ | OMIC (Cambodia) Ltd |
| ១៨៣ | Palm Rice Co.,Ltd |
| ១៨៤ | Pen Narom Rice Mill |
| ១៨៥ | Pheak Chhuoy Rice Mill |
| ១៨៦ | Phnom Bayang Agricultural Cooperative (PBAC) |
| ១៨៧ | Phou Poy Develpment Import Export Co.,Ltd |
| ១៨៨ | Phour Kok Ky Rice Mill |
| ១៨៩ | Phouv Thouv Rice Mill |
| ១៩០ | Phrahpos Ponleu Thmey Agricultural Cooperative |
| ១៩១ | Phum Yerng Agriculture Development Community |
| ១៩២ | Pidor Ta Ung Agriculture Development Community |
| ១៩៣ | Pisda Aphivath Co.,Ltd |
| ១៩៤ | Pomleu Samki Angricultural Cooporation |
| ១៩៥ | Pon Loeu Kasekor Agricutural Cooperative |
| ១៩៦ | Ponleu Beng Krapom Chhouk Agricultural Cooperative |
| ១៩៧ | Ponleu Thmey Phaong Agricultural Cooperative |
| ១៩៨ | Ponlok Thmey Angricultural Cooporation |
| ១៩៩ | Por Samroung Angrilcultural Cooporation |
| ២០០ | Pov Kea Import Eport Co.,Ltd |
| ២០១ | Pracheachun Prey Romdeng Agricultural Cooperative(PPRAC) |
| ២០២ | Prasat Soksenchey Agricultural Cooperative (PAKC) |
| ២០៣ | Preah Sihanouk Agriculture Development community |
| ២០៤ | Prey Yuthka Agricultural Cooperative (PYTAC) |
| ២០៥ | Primalis Corporation Co.,Ltd |
| ២០៦ | R.L Co.,Ltd |

| | |
|---|---|
| ២០៧ | Ram Sar Steung Traeng Rice  Development |
| ២០៨ | Reak Chamroeun Agriculture Development Community |
| ២០៩ | Reaksmey Dombok Khpos Meanchey |
| ២១០ | Reaksmey Prey Pnhors Angricultural Cooporation |
| ២១១ | Roluos Meanchey Raksmey Satrey Angkor Agricultural Cooperative |
| ២១២ | Roluos Meas Agricultural Cooperative(RLMAC) |
| ២១៣ | Romdoul Seryreang tareach Angricultural Cooporation |
| ២១៤ | Ros Hour Rice Mill |
| ២១៥ | Royal Rallway Co.,Ltd |
| ២១៦ | Ruos Neng Rice Mill |
| ២១៧ | SAMBATHVATHANAK C.,Ltd |
| ២១៨ | Samki Amtak Angricultural Cooporation |
| ២១៩ | Samor Leu Agricultural Cooperative (SALAC) |
| ២២០ | Samply Angkor Reangsei Agriculture Cooprative (RLMAG) |
| ២២១ | Sann & Khan Rice Mill |
| ២២២ | Sann Ty Rice Mill |
| ២២៣ | Sao Hak Se Rice Mill |
| ២២៤ | Sary KuntheaInternational trading Co.,Ltd |
| ២២៥ | Satrey Haong Samnam Agriculture Development Community |
| ២២៦ | Scafco Corporation (DBA Scafco Grain Systems Company) |
| ២២៧ | Se Chamroeun Rice Mill |
| ២២៨ | Se Khun Rice Mill |
| ២២៩ | Sen Rith Rice Mill |
| ២៣០ | Seng Bunsor Rice Mill |
| ២៣១ | Senh Chhinh Rice Mill |
| ២៣២ | SGS (Cambodia) Limited |

| | |
|---|---|
| ២៣៣ | Siev Heng Rice Mill |
| ២៣៤ | Siev Lay Rice Mill |
| ២៣៥ | Signatures of Asia Co.,Ltd |
| ២៣៦ | Smach Kompong Ror Agriculture Development Community |
| ២៣៧ | Sok Keo Import Export Co.,Ltd |
| ២៣៨ | Soma Trading Co., Ltd |
| ២៣៩ | Sombo Meanchey Agriculture Community |
| ២៤០ | Sombo Rice Co.,Ltd |
| ២៤១ | Song Heng Rice Mill |
| ២៤២ | Sor Kimsuong Rice Mill |
| ២៤៣ | Speed Logistics & Transportation Co.,Ltd |
| ២៤៤ | Sramor Sreboeng Agricultural Cooperative (SSAC) |
| ២៤៥ | SSCORP (Cambodia) Ltd |
| ២៤៦ | Suon Sophal Rice Mill |
| ២៤៧ | Suy Vanni Rice Mill |
| ២៤៨ | Svay Meanhey Satrey Sammaky Community |
| ២៤៩ | T.M.K Investment Co.,Ltd |
| ២៥០ | T.O.T (Trust Our Trade) Co.,LTD |
| ២៥១ | Ta Kol Yiv Pov Rice Mill |
| ២៥២ | Taing Cheng Rice Mill |
| ២៥៣ | Takbey Lay Kongveng Rice Mill |
| ២៥៤ | Tangkrsao Kasikor Chok Chey Agriculture Coorporation |
| ២៥៥ | Teav Heu Rice Mill |
| ២៥៦ | Teav Eang Rice Mill |
| ២៥៧ | Tech Soon Agro- Industry Co.,Ltd |
| ២៥៨ | Teng Lay Import Export and Transportation Co.,Ltd |

| | |
|---|---|
| ២៥៩ | Thean Kong IMPEX |
| ២៦០ | Thmor Korl Rice Import Export Co.,Ltd |
| ២៦១ | Thol Sam At Rice Mill |
| ២៦២ | Thorn Chea Rice Mill |
| ២៦៣ | Tong Pheap Rice Mill |
| ២៦៤ | Tong Pheap Rice Mill |
| ២៦៥ | Touch Sarom Rice Mill |
| ២៦៦ | Trapaing Russey Agriculture Development Community |
| ២៦៧ | Tuol Prasvihear Agricultural Cooperative (TPVAC) |
| ២៦៨ | TUV Rheinland (Cambodia) Co.,Ltd |
| ២៦៩ | Ty Chay Rice Mill |
| ២៧០ | Udom Sorya Agricultural Community |
| ២៧១ | Ung Simon Rice Mill |
| ២៧២ | UNI – Natural Co.,Ltd |
| ២៧៣ | Vann Linh Vou Rice Mill |
| ២៧៤ | Vibol Dara Rice Mill |
| ២៧៥ | Vinh Cheang Medium Enterprise of Rice Mill |
| ២៧៦ | Vong Bun Heng Import Export Co., Ltd |
| ២៧៧ | Vong Sambath  Rice Co.,Ltd |
| ២៧៨ | W.K.R. Trading Co., Ltd |
| ២៧៩ | Wat Kor Chamroeun Phal Angricultural Cooporation |
| ២៨០ | White Gold Import Export Co., Ltd |
| ២៨១ | Xiang Shan Rice (Cambodia) Co.,Ltd |
| ២៨២ | Ya Rina Rice Mill |
| ២៨៣ | Yam Bunsong Rice Mill |
| ២៨៤ | Yam Chanray Rice Mill |

| | |
|---|---|
| ២៨៥ | Yam Kinh Rice Mill |
| ២៨៧ | Yam Sann Rice Mill |
| ២៨៨ | Yeung Shi Group Co., Ltd |
| ២៨៩ | Yin Khuong Rice Mill |
| ២៩០ | Yin Mann Rice Mill |
| ២៩១ | Yin Pou Rice Mill |
| ២៩២ | You Khim Rice Mill |